ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# វិទ្យាសាស្ត្រ

# រូបវិទ្យា

៩




គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# វិទ្យាសាស្ត្រ

## ថ្នាក់ទី ៩

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៩៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក សូ គន្ធី | លោក ហែម សាលី |
| | លោក សួន សុជាតិ | លោកស្រី យិម យីហ៊ុប |
| | លោកស្រី ហ៊ុយ ចន្ធូ | លោក នី ពុទ្ធី |
| **អ្នកខាយអត្ថបទ** | លោក ហៃ វីរៈ | លោក ផ៉ាន់ ជាតិ |
| **វិចិត្រករ** | លោក តន់ ជាតិ | |
| **អ្នករៀបរៀង** | លោក ស៊ុម ចាន់ធី | លោក ចាន់ ខេង |
| | លោក វ៉ា វុទ្ធី | លោក ជួន វណ្ណា |
| **អ្នករចនាទំព័រ** | លោក គង់ ចិត្រា | |
| **អ្នកឯកទេស** | លោក អ៊ឹង ហេង | |
| **គណៈកម្មការពិនិត្យ** | លោកស្រី អៀម ចាន់ឌី | លោកស្រី អន កិត្យាស៊ី |
| | លោកស្រី អ៊ាន សាវិន | លោកស្រី ណារ៉េត ប៉ូលីវីន |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ២១៣ អយក.ប្រក. ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពផ្សាយ ឆ្នាំ ២០១៨

ISBN 9-789-995-001-346

# អារម្ភកថា

សៀវភៅវិទ្យាសាស្ត្រថ្នាក់ទី១ នេះ គណៈកម្មការនិពន្ធបានរៀបចំចងក្រងឡើងដោយផ្អែកលើកម្មវិធីសិក្សាថ្មី (2006) របស់ក្រសួងអប់រំ យុវជន និងកីឡា ។ នៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ មានមុខវិជ្ជារងចំនួនបួន រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ។

រាល់ខ្លឹមសារមេរៀនដែលមានក្នុងសៀវភៅនេះ អ្នកនិពន្ធបានរៀបចំពីកម្រិតងាយទៅកម្រិតលំបាក ហើយស្របតាមកម្មវិធីសិក្សាថ្មីនិងស្របតាមវិធីវិទ្យាសាស្ត្រ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅវិទ្យាសាស្ត្រថ្នាក់ទី១នេះនឹងក្លាយជាមិត្តដ៏ល្អរបស់ប្អូនៗសិស្សានុសិស្សជាក់ជាមិនខាន ។ ទន្ទឹមគ្នានោះដែរគណៈកម្មការនិពន្ធរីករាយនឹងទទួលយកមតិកែលំអពីសំណាក់ លោកគ្រូ អ្នកគ្រូ និងគ្រប់មជ្ឈដ្ឋាន ។

គណៈកម្មការនិពន្ធ

ជំពូក 1 : ផលរង្វិលនៃកម្លាំង (រូបវិទ្យា)

1. បង្គុំនិងបំបែកកម្លាំង 2
2. ម៉ូម៉ង់នៃកម្លាំង 6
3. ទីប្រជុំទម្ងន់ 12

ជំពូក 2 : ម៉ាស៊ីនងាយ

1. ឃ្នាស់ 20
2. ប្លង់ទេរ 26
3. កង់យោងនិងស្ពី 30
4. រ៉កនិងត្រីយ 34
5. ទិន្នផលម៉ាស៊ីនងាយ 40

ជំពូក 3 : អគ្គិសនី

1. ថាមពលអគ្គិសនី 44
2. ការប្រើប្រាស់ចរន្តអគ្គិសនីក្នុងគេហដ្ឋាន 50

ជំពូក 4 : អេឡិចត្រូម៉ាញេទិច

1. ដែនម៉ាញេទិចបង្កើតដោយចរន្តអគ្គិសនី 58
2. អេឡិចត្រូមេដែក 62
3. កម្លាំងម៉ាញេទិចលើចរន្តអគ្គិសនី 66
4. អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច 70
5. ត្រង់ស្វូម៉ាទ័រឬត្រង់ស្វូ 74

ជំពូក 5 : អុបទិច

1. ដំណាលត្រង់នៃពន្លឺ 82
2. ចំណាំងផ្លាតនៃពន្លឺ 88
3. ចំណាំងបែរនៃពន្លឺ 94
4. ឡង់ទី 98

# ជំពូកទី 1 ផលបង្វិលនៃកម្លាំង




យើងបានសិក្សារួចមកហើយអំពីកម្លាំង កម្លាំងគឺជាបុព្វហេតុដែលធ្វើឱ្យអង្គធាតុមានចលនាឬបញ្ឈប់ចលនា ឬផ្លាស់ប្ដូរទិស ទិសដៅចលនា និងធ្វើឱ្យអង្គធាតុខូចទ្រង់ទ្រាយ ។

ក្នុងជំពូកនេះ យើងនឹងសិក្សាអំពីបង្គុំនិងបំបែកកម្លាំង ម៉ូម៉ង់នៃកម្លាំង ៉ និងទីប្រជុំទម្ងន់នៃកម្លាំង ។

មេរៀនទី

# 1 បង្គុំនិងបំបែកកម្លាំង

**ចប់មេរៀននេះ សិស្សអាច**

- ផ្គុំកម្លាំងពីរស្របគ្នា
- បំបែកកម្លាំងមួយជាកម្លាំងពីរស្របគ្នា
- អនុវត្តច្បាប់ប្រលេឡូក្រាម ក្នុងការបំបែកកម្លាំង ។

## 1. បង្គុំកម្លាំងពីរស្របគ្នាជាកម្លាំងផ្គួបមួយ

### 1.1. ពិសោធន៍

យើងព្យួរបន្ទាត់ក្រិតមួយដោយភ្ជាប់កៅស៊ូពីរ ហើយយើងផ្តក់កូនទម្ងន់ $\vec{F}_1$ និង $\vec{F}_2$ ត្រង់ចំណុច $O_1$ និង $O_2$ (ដូចរូប) ។ បន្ទាត់ក្រិតនោះរងនូវកម្លាំងពីរគឺ $\vec{F}_1$ និង $\vec{F}_2$ ហើយឋិតនៅទីតាំងលំនឹងមួយ $O_1O_2$ ។ យើងយកកូនទម្ងន់មួយដែលមានទម្ងន់ $\vec{R} = \vec{F}_1 + \vec{F}_2$ មកជំនួសកូនទម្ងន់ $\vec{F}_1$ និង $\vec{F}_2$ ។




យើងរកចំណុច O មួយនៅលើបន្ទាត់ក្រិតដើម្បីព្យួរកូនទម្ងន់ R ដែលធ្វើឱ្យបន្ទាត់ក្រិតឋិតនៅទីតាំងលំនឹងដដែល ។ ផលនៃកម្លាំង $\vec{R}$ មានអំពើលើបន្ទាត់ក្រិតដូចគ្នានឹងកម្លាំង $\vec{F}_1$ និង $\vec{F}_2$ ដែលធ្វើអំពើព្រមគ្នា ។ ដូចនេះ $\vec{R}$ ជាកម្លាំងផ្គួបនៃកម្លាំង $\vec{F}_1$ និង $\vec{F}_2$ ។

ឧបមាថា $OO_1 = d_1$ , $OO_2 = d_2$ ។ បន្ទាប់មកយើងវាស់ប្រវែង $d_1$ និង $d_2$ ។ យើងសង្កេតឃើញថាផលធៀប $\frac{d_2}{d_1}$ ច្រាសសមាមាត្រនឹងកម្លាំង $\vec{F}_1$ និង $\vec{F}_2$ : $\boxed{\frac{d_2}{d_1} = \frac{F_1}{F_2}}$ ។

### 1.2. សន្និដ្ឋាន

- បើកម្លាំងពីរស្របគ្នា និងមានទិសដៅដូចគ្នា គេអាចកំណត់កម្លាំងផ្តួបមួយស្របនឹងកម្លាំងទាំងពីរ ហើយមានទិសដៅដូចទិសដៅនៃកម្លាំងទាំងពីរ ចំណែកអាំងតង់ស៊ីតេរបស់វាស្មើនឹងផលបូកអាំងតង់ស៊ីតេកម្លាំងទាំងពីរ $R = F_1 + F_2$ ។
- ចំណុចចាប់នៃកម្លាំងផ្តួប ចែកចម្ងាយរវាងចំណុចចាប់នៃកម្លាំងផ្ទុំជាភាគច្រាសសមាមាត្រនឹងអាំងតង់ស៊ីតេកម្លាំងផ្ទុំ : $\frac{d_2}{d_1} = \frac{F_1}{F_2}$ ។
- បើអង្គធាតុមួយរងនូវកម្លាំងច្រើនស្របគ្នា គេអនុវត្តវិធានដូចមុនដោយដំបូងគេផ្តុំកម្លាំងជួបពីររួចគេយកកម្លាំងផ្តួបនោះទៅផ្តុំកម្លាំងផ្ទុំទីបី ហើយបន្តបន្ទាប់លុះត្រាតែអស់កម្លាំងផ្ទុំ ។ អាំងតង់ស៊ីតេកម្លាំងសម្រេចស្មើនឹងផលបូកនៃអាំងតង់ស៊ីតេកម្លាំងផ្ទុំទាំងអស់ ។

## 2. បំបែកកម្លាំងមួយជាកម្លាំងផ្ទុំពីរស្របគ្នា




ក្នុងករណីជាច្រើន យើងត្រូវបំបែកកម្លាំងមួយជាកម្លាំងពីរស្របគ្នា ។ *ឧទាហរណ៍* រថយន្តមួយឋិតនៅលើស្ពាន(ដូចរូប) វារងនូវទម្ងន់ P = 32 000N ទៅលើស្ពាន ។ យើងអាចកំណត់កម្លាំង ដែលមានអំពើលើទម្រ A និង B របស់ស្ពាន ។ យើងតាងកម្លាំង P = 32 000N ដោយវ៉ិចទ័រ $\vec{P}$ និង O ជាចំណុចចាប់នៃកម្លាំង ។ ឥឡូវយើងបំបែកកម្លាំង $\vec{P}$ ជាកម្លាំងផ្ទុំស្របគ្នា $\vec{F}$ និង $\vec{Q}$ ហើយចំណុចនៃកម្លាំងទាំងពីរឋិតនៅត្រង់ចំណុច A និង B ។

យើងបានចំណុច O ដោយចែកអង្កត់ [AB] ជាចំណែកដែលច្រាសសមាមាត្រនឹងកម្លាំង $\vec{F}$ និង $\vec{Q}$ $\frac{OB}{OA} = \frac{Q}{F}$ ។

ឧបមាថា OB = 6m និង OA = 4m យើងបាន $\frac{Q}{F} = \frac{6}{4} = \frac{3}{2}$ ឬ $Q = \frac{3F}{2}$ (1)

ប៉ុន្តែ F + Q = 32 000N ដូចនេះយើងបាន : $\frac{3F}{2} + F = 32\ 000N$ (2) ។

ដោះស្រាយសមីការ (1) និង (2) យើងបាន : Q = 19200N និង F = 12800N ។

## 3. បំបែកកម្លាំងមួយជាកម្លាំងផ្គុំជួចពីរ

### 3.1. ឧទាហរណ៍

មនុស្សម្នាក់អូសរទេះ ។ ឧបមាកម្លាំងទាញរទេះបង្កើតបានមុំ θ ធៀបនឹងខ្សែដេក(ដូចរូប) ។ រទេះផ្លាស់ទីតាមខ្សែដេក គឺមិនផ្លាស់ទីតាមទិសនៃកម្លាំងទេ ។



*បំបែកកម្លាំងមួយជាកម្លាំងផ្គុំជួបពីរ*

ដើម្បីកំណត់អាំងតង់ស៊ីតេកម្លាំងដែលមានអំពើលើរទេះតាមទិសដៅនៃចលនារបស់វា យើងបំបែកកម្លាំងទាញជាកម្លាំងផ្គុំពីរដែលកម្លាំងទីមួយតាមខ្សែដេក និងកម្លាំងទីពីរតាមខ្សែឈរ ។ ពីគល់វ៉ិចទ័រ $\vec{F}$ ដែលតាងកម្លាំងទាញ យើងគូសបន្ទាត់ស្របនឹងទិសទាំងពីរខាងលើ ។ ជ្រុង P និង Q ជាប្រលេឡូក្រាមដែលបានមក តាងកម្លាំងផ្គុំដែលយើងត្រូវកំណត់ គឺកម្លាំងផ្គុំ $\vec{Q}$ ដែលមានទិសឈរអូសរទេះនិងកម្លាំងផ្គុំ $\vec{P}$ មានទិសដេកដែលគ្រាន់តែបន្ថយកម្លាំងសង្កត់នៃរទេះលើក្តារបុំណ្ណោះ ។

អំពើព្រមគ្នានៃកម្លាំង $\vec{P}$ និង $\vec{Q}$ សមមូលកម្លាំងតែមួយគឺ $\vec{F}$ ។

### 3.2. និយមន័យ

ច្បាប់ប្រលេឡូក្រាមអាចឱ្យយើងជំនួសកម្លាំងជួបពីរដែលមានអំពើលើអង្គធាតុតែមួយដោយកម្លាំងមួយ ។ ផ្ទុយមកវិញដោយប្រើច្បាប់ដដែលយើងអាចជំនួសកម្លាំងមួយដោយកម្លាំងជួបពីរដែរ ។

"បំបែកកម្លាំងមួយជាកម្លាំងផ្គុំពីរ គឺជំនួសកម្លាំងទោលនោះដោយកម្លាំងពីរដែលផ្តល់ផលដូចគ្នា ។"



## មេរៀនសង្ខេប

- បើកម្លាំងពីរស្របគ្នានិងមានទិសដៅដូចគ្នា គេអាចកំណត់កម្លាំងផ្គួបមួយស្របនឹងកម្លាំងទាំងពីរ ហើយមានទិសដៅដូចទិសដៅនៃកម្លាំងទាំងពីរ ចំណែកអាំងតង់ស៊ីតេរបស់វាស្មើនឹងផលបូកអាំងតង់ស៊ីតេកម្លាំងទាំងពីរ: $\vec{R} = \vec{F_1} + \vec{F_2}$ ឬ $R = F_1 + F_2$
- ដើម្បីកំណត់ចំណុចចាប់នៃកម្លាំងផ្គួប គេចែកចម្ងាយរវាងចំណុចចាប់នៃកម្លាំងផ្ដុំជាភាគច្រាសសមាមាត្រនិងអាំងតង់ស៊ីតេកម្លាំងផ្ដុំ : $\frac{d_2}{d_1} = \frac{F_1}{F_2}$ ។
- បើអង្គធាតុមួយរងនូវកម្លាំងច្រើនស្របគ្នា គេអនុវត្តវិធានដូចមុនដោយផ្ដុំកម្លាំងជួបពីរ រួចគេយកកម្លាំងផ្គួបនោះទៅផ្ដុំកម្លាំងផ្ដុំទីបី ហើយបន្តបន្ទាប់លុះត្រាតែអស់កម្លាំងផ្ដុំ ។ អាំងតង់ស៊ីតេកម្លាំងសម្រេចស្មើនឹងផលបូកនៃអាំងតង់ស៊ីតេកម្លាំងផ្ដុំទាំងអស់ ។
- បំបែកកម្លាំងមួយជាកម្លាំងផ្ដុំពីរ គឺជំនួសកម្លាំងទោលនោះដោយកម្លាំងពីរដែលផ្ដល់ផលដូចគ្នា ។

## សំណួរនិងលំហាត់

1. បន្ទាត់ស្មើសាច់មួយមានប្រវែង 50cm ចុងទាំងសងខាងនៃបន្ទាត់រងនូវកម្លាំងពីរស្របគ្នានិងមានទិសដៅដូចគ្នា ។ កម្លាំងទីមួយស្មើនឹង 600N និងកម្លាំងទីពីរស្មើនឹង 400N ។ កំណត់កម្លាំងផ្គួបរបស់វា ។
2. បន្ទាត់ស្មើសាច់មួយមានប្រវែង 100cm រងនូវកម្លាំងបីស្របគ្នា និងមានទិសដៅដូចគ្នា ។ ចុងខាងស្ដាំរងនូវកម្លាំងមួយស្មើនឹង 20N និងចុងខាងឆ្វេងរងនូវកម្លាំងមួយស្មើនឹង 90N ហើយនៅកណ្ដាលរងនូវកម្លាំងស្មើនឹង 30N ។ កំណត់កម្លាំងផ្គួបរបស់វា ។
3. របារមួយទ្រដោយទម្រ A និង B ដែលមានចម្ងាយពីគ្នា 5m ។ របារទ្រទម្ងន់មួយស្មើនឹង 40 000N ត្រង់ចំណុចចាប់មួយដែលមានចម្ងាយពី A ប្រវែង 2.6m ។ កំណត់កម្លាំងដែលមានអំពើទៅលើទម្រ A និង B ។ (ទម្ងន់របារអាចចោលបាន) ។
4. កម្លាំងពីរ $\vec{F}_1$ និង $\vec{F}_2$ កែងគ្នា មានអាំងតង់ស៊ីតេរៀងគ្នា 3N និង 4N ហើយមានចំណុចចាប់រួម O ។ គូសវ៉ិចទ័រតាងកម្លាំងជួបទាំងពីរ (កម្លាំងផ្គួប)របស់វា ហើយរកអាំងតង់ស៊ីតេកម្លាំងផ្គួបដោយប្រើមាត្រដ្ឋាន 1cm = 1N ។
5. កម្លាំងមួយ 50N មានទិសបង្កើតបានមុំ 45° ធៀបនិងទិសដេក ។ រកកម្លាំងផ្ដុំឈរនិងផ្ដុំដេករបស់វា ។

# 2 ម៉ូម៉ង់នៃកម្លាំង

**ចប់មេរៀននេះ សិស្សអាច**

- ❑ បង្ហាញពីសញ្ញាណម៉ូម៉ង់នៃកម្លាំង
- ❑ គណនាម៉ូម៉ង់នៃកម្លាំងតាមរូបមន្ត : $M = F \times d$
- ❑ បញ្ជាក់ពីលក្ខខណ្ឌលំនឹងនៃអង្គធាតុមួយដែលវិលជុំវិញតាមអ័ក្សរង្វិល
- ❑ អនុវត្តម៉ូម៉ង់នៃកម្លាំងក្នុងជីវភាពរស់នៅ ។

ហេតុអ្វីបានជាគេប្រើឃ្នាស់គាស់គម្របដបងាយគាស់ជាងដៃទទេ ? ហេតុអ្វីបានជាគេប្រើសោដែលមានដងវែងសម្រាប់មួលរិតឬបន្ធូរខ្ចៅ(ប៊ូឡុង) ?

## 1. សញ្ញាណម៉ូម៉ង់កម្លាំង




យើងយកទ្វារមួយមកពិនិត្យ ។ ចលនាតែមួយដែលទ្វារមានគឺចលនារង្វិលជុំវិញអ័ក្សឈរនៃត្រចៀក ។

យើងរុញឬទាញទ្វារដោយកម្លាំងមួយកែងនឹងទ្វារ ទ្វារនោះវិល ។ យើងសង្កេតឃើញថា ប្រសិនបើជាខ្សែសកម្មនៃកម្លាំងឋិតនៅជិតអ័ក្សរង្វិល យើងត្រូវបញ្ចេញកម្លាំងខ្លាំងទើបទ្វារវិល ។ ប៉ុន្តែប្រសិនបើខ្សែសកម្មនៃកម្លាំងនៅកាន់តែឆ្ងាយពីអ័ក្សរង្វិលកម្លាំងដែលយើងត្រូវបញ្ចេញដើម្បីឱ្យទ្វារវិលក៏កាន់តែតូចទៅៗដែរ ។ ការណ៍នេះបញ្ជាក់ថា ផលរង្វិលនៃកម្លាំងមួយមិនត្រឹមតែអាស្រ័យនឹងអាំងតង់ស៊ីតេកម្លាំង(រុញ ឬទាញ) ប៉ុណ្ណោះទេ គឺអាស្រ័យនឹងចម្ងាយរវាងកម្លាំងទៅនឹងអ័ក្សរង្វិលផងដែរ ។

ចម្ងាយរវាងអ័ក្សរង្វិលទៅនឹងចំណុចចាប់នៃកម្លាំងឬខ្សែសកម្មនៃកម្លាំងហៅថា ប្រវែងដៃឃ្នាស់ ។

ប្រសិនបើយើងរុញឬទាញទ្វារដោយកម្លាំងមួយស្របនិងផ្ទៃទ្វារ ទ្វារនោះមិនវិលទេ ពីព្រោះខ្សែសកម្មនៃកម្លាំងស្របនិងអ័ក្សរង្វិល ។

## 2. ម៉ូម៉ង់នៃកម្លាំង




អ្នកកាន់បន្ទាត់ក្រិតមួយដាក់តាមទិសដេក ហើយព្យួរកូនទម្ងន់មួយនៅក្បែរដៃរបស់អ្នក។ បន្ទាប់មកអ្នកផ្លាស់ទីកូនទម្ងន់នោះបន្តិចម្តងៗឱ្យកាន់តែឆ្ងាយពីដៃរបស់អ្នក ដោយរក្សាបន្ទាត់ក្រិតតាមទិសដេកដដែល។ តើអ្នកមានអារម្មណ៍ដូចម្តេច ?

ឥឡូវនេះ អ្នកធ្វើសកម្មភាពដូចខាងលើដែរ ប៉ុន្តែអ្នកគ្រាន់តែប្តូរកូនទម្ងន់ចាស់ចេញ ហើយដាក់កូនទម្ងន់ថ្មីដែលធ្ងន់ជាងមុនជំនួសវិញ។ តើអ្នកមានអារម្មណ៍ខុសពីមុនដូចម្តេចដែរ ?

តាមពិសោធន៍បង្ហាញថា ប្រសិនបើអាំងតង់ស៊ីតេកម្លាំងនិងប្រវែងដៃឃ្នាស់នៃកម្លាំងកាន់តែធំ ផលរង្វិលនៃកម្លាំងក៏កាន់តែធំដែរ។ ផលរង្វិលនៃកម្លាំងនេះ សមាមាត្រនឹងអាំងតង់ស៊ីតេកម្លាំងនិងប្រវែងដៃឃ្នាស់នៃកម្លាំង។

ទំហំកំណត់ដោយ ផលគុណរវាងកម្លាំងនិងប្រវែងដៃឃ្នាស់ហៅថា **ម៉ូម៉ង់នៃកម្លាំង**។

ម៉ូម៉ង់កម្លាំង = កម្លាំង × ប្រវែងដៃឃ្នាស់ ឬ $M = Fd$

ក្នុងប្រព័ន្ធខ្នាតអន្តរជាតិ (SI) កម្លាំង $F$ គិតជាញូតុន (N) ប្រវែងដៃឃ្នាស់ $d$ គិតជាម៉ែត្រ (m) និងម៉ូម៉ង់កម្លាំង $M$ គិតជាញូតុនម៉ែត្រ ($N \cdot m$) ។

ញូតុនម៉ែត្រ ($N \cdot m$) ជាម៉ូម៉ង់នៃកម្លាំងមួយដែលមានអាំងតង់ស៊ីតេកម្លាំងស្មើនឹង 1N និងមានប្រវែងដៃឃ្នាស់ស្មើនឹង 1m ។




រូបនេះបង្ហាញពីម៉ូម៉ង់កម្លាំងដែលមានអំពើលើសោធៀបនឹងអ័ក្សនៃប៊ូឡុង។ តាមទិសរង្វិលនៃសោ យើងអាចរឹតឬបន្ធូរប៊ូឡុងបាន។ ដើម្បីកំណត់ទិសរង្វិលនៃអង្គធាតុមួយ គេប្រដូចវាទៅនឹងទិសដៅនៃទ្រនិចនាឡិកាមួយ។ ម៉ូម៉ង់ដែលធ្វើឱ្យអង្គធាតុវិលតាមទិសដៅរង្វិលនៃទ្រនិចនាឡិកាជា **ម៉ូម៉ង់អវិជ្ជមាន**។ ម៉ូម៉ង់ដែលធ្វើឱ្យអង្គធាតុវិលតាមទិសដៅច្រាសនឹងរង្វិលនៃទ្រនិចនាឡិកាជា **ម៉ូម៉ង់វិជ្ជមាន**។

***ឧទាហរណ៍ :*** ដើម្បីរឹតប៊ូឡុងមួយ គេប្រើសោមួយដែលមានប្រវែង $OA = 0.2m$ ។ កម្លាំងដែលត្រូវបញ្ចេញនៅត្រង់ A មានអាំងតង់ស៊ីតេស្មើនឹង 10N ហើយមានទិសកែងនឹង OA ។ គណនាម៉ូម៉ង់នៃកម្លាំងនេះ។

✍ ដំណោះស្រាយ

ម៉ូម៉ង់កម្លាំងគឺ

តាមរូបមន្ត : $M = F \times d$ ដោយ $F = 10N$ , $d = 0A = 0.2m$

$M = 10N \times 0.2m = 2N \cdot m$

$M = 2N \cdot m$ ។

## 3. លក្ខខណ្ឌលំនឹងនៃអង្គធាតុមួយចល័តជុំវិញអ័ក្សមួយ

យើងកំណត់លក្ខខណ្ឌលំនឹងនៃអង្គធាតុមួយចល័តជុំវិញអ័ក្សដោយប្រើថាសស្មើសាច់មួយដែលអាចវិលជុំវិញអ័ក្សមួយកាត់តាមផ្ចិតរបស់វា ។

ដើម្បីងាយវាស់ប្រវែងដៃឃ្នាស់ គេគូសរង្វង់រួមផ្ចិតលើថាសនោះដែលចន្លោះពីមួយទៅមួយស្មើៗគ្នា ។ គេកំណត់កាំរង្វង់ទីមួយស្មើនិង 1cm រង្វង់ទីពីរស្មើនិង 2cm រង្វង់ទីបីស្មើនិង 3cm ។ល។ គេដំដែកគោលតូចៗនៅលើរង្វង់មួយចំនួន(ដូចរូប) ដើម្បីផ្គក់កូនទម្ងន់ ។ ម៉ាសនៃកូនទម្ងន់នីមួយៗស្មើនិង 50g ។

ក្នុងករណីដូចរូបនេះ យើងឃើញថា ថាសរងនូវកម្លាំងបីគឺ

$F_1 = 0.05kg \times 10m/s^2 = 0.5N$

$F_2 = 0.05kg \times 4 \times 10m/s^2 = 2N$

$F_3 = 0.05kg \times 2 \times 10m/s^2 = 1N$




កម្លាំងទាំងបីមានប្រវែងដៃឃ្នាស់គឺ

$d_1 = 4cm = 0.04m$

$d_2 = 2cm = 0.02m$

$d_3 = 6cm = 0.06m$

ម៉ូម៉ង់នៃកម្លាំងទាំងបីគឺ

$M_1 = 0.5N \times 0.04m = 0.02N \cdot m$

$M_2 = 2N \times 0.02m = 0.04N \cdot m$

$M_3 = 1N \times 0.06m = 0.06N \cdot m$

យើងសង្កេតឃើញថា ម៉ូម៉ង់ $M_1$ និង $M_2$ ជាម៉ូម៉ង់អវិជ្ជមាន ( – ) ព្រោះវាបង្វិលថាសតាមទិសដៅនៃទ្រនិចនាឡិកា រីឯម៉ូម៉ង់ $M_3$ ជាម៉ូម៉ង់វិជ្ជមាន ( + ) ព្រោះវាបង្វិលថាសតាមទិសដៅផ្ទុយពី

រង្វិលទ្រនិចនាឡិកា ។ តាមពិសោធន៍នេះបង្ហាញថា ក្រោមអំពើនៃកម្លាំងទាំងបី ថាសមានលំនឹងហើយផលបូកម៉ូម៉ង់នៃកម្លាំងទាំងបីស្មើនឹងសូន្យ :

$$M_1 + M_2 + M_3 = -0.02N\ m + (-0.04N\ m) + 0.06N\ m$$

ដូចនេះយើងសន្និដ្ឋានថា អង្គធាតុមួយចល័តជុំវិញអ័ក្សមួយមានលំនឹង កាលណាផលបូកម៉ូម៉ង់នៃកម្លាំងដែលមានអំពើលើអង្គធាតុនោះស្មើនឹងសូន្យ ឬម៉ូម៉ង់វិជ្ជមាន ( + ) នៃអ័ក្សរង្វិលខាងឆ្វេងស្មើនឹងម៉ូម៉ង់អវិជ្ជមាន ( – ) នៃអ័ក្សរង្វិលខាងស្តាំនៃអ័ក្ស ។

*ឧទាហរណ៍ :* គេចោះម៉ែត្របន្ទាត់ឈើស្មើសាច់មួយត្រង់ចំណុចកណ្តាល រួចចងវាភ្ជាប់ទៅនឹងបង្គោលមួយ ។ ម៉ែត្របន្ទាត់នោះអាចចល័តជុំវិញអ័ក្សរង្វិល(ដែកគោល)នេះបាន ។ នៅពេលបន្ទាត់មានលំនឹងតាមខ្សែដេក គេព្យួរអង្គធាតុមួយមានម៉ាស $m_1 = 200g$ ចម្ងាយ 40cm ខាងស្តាំអ័ក្សរង្វិល ។ តើគេត្រូវព្យួរកូនទម្ងន់ដែលមានម៉ាស $m_2$ ប៉ុន្មានញូតុន ដើម្បីធ្វើឱ្យបន្ទាត់មានលំនឹងឡើងវិញ បើគេដាក់វានៅចម្ងាយ 20cm ខាងឆ្វេងអ័ក្សរង្វិល ?

## ដំណោះស្រាយ




ម៉ាស $m_2$ នៃកូនទម្ងន់

ម៉ូម៉ង់ខាងស្តាំនៃអ័ក្សរង្វិល

$M_1 = F_1 \times d_1$ ដោយ $m_1 = 200g = 0.2kg$ , $d_1 = 40cm = 0.40m$

$M_1 = 0.2kg \times 0.40m \times 10m/s^2 = 0.80Nm$

ម៉ូម៉ង់ខាងឆ្វេងនៃអ័ក្សរង្វិល

$M_2 = F_2 \times d_2$ ដោយ $d_2 = 20cm = 0.20m$ , $F_2 = m_2 \times 10m/s^2$

$M_2 = m_2 \times 0.20m \times 10m/s^2 = 0.2m \times F_2$

ដើម្បីធ្វើឱ្យបន្ទាត់មានលំនឹងឡើងវិញ លុះត្រាតែ

ម៉ូម៉ង់វិជ្ជមាន ( + ) ខាងស្តាំនៃអ័ក្សរង្វិលស្មើនិងម៉ូម៉ង់អវិជ្ជមាន ( – ) ខាងឆ្វេងនៃអ័ក្សរង្វិល $M_1 = M_2$

$$0.80Nm = 0.20m \times F_2 \quad \text{នាំឱ្យ } F_2 = \frac{0.80Nm}{0,20m} = 4N$$

ដូចនេះគេត្រូវព្យួរកូនទម្ងន់ $F_2 = 4N$ ខាងឆ្វេងអ័ក្សរង្វិល ។

## 4. អនុវត្តន៍ម៉ូម៉ង់កម្លាំង

គោលការណ៍ម៉ូម៉ង់កម្លាំងត្រូវបានគេយកទៅអនុវត្តក្នុងការធ្វើជញ្ជីង ។ ជញ្ជីងទាំងអស់ទោះបីមានរាងខុសគ្នាយ៉ាងណាក៏ដោយក៏តែងតែមានដងថ្លឹងជាដរាប(លើកលែងតែជញ្ជីងអេឡិចត្រូនិច) ។ ដងថ្លឹងនោះច្រើនចែកចេញជាពីរកំណាត់ស្មើគ្នា ។

*ឧទាហរណ៍ :* ជញ្ជីងសង្រែក ជញ្ជីងរ៉ូប៊ែរ៉ាល់ ...ជាដើម ។ល ។



**មេរៀនសង្ខេប**

- ទំហំកំណត់ដោយផលគុណរវាងកម្លាំងនិងប្រវែងដៃឃ្នាស់ហៅថា ម៉ូម៉ង់កម្លាំង

  គេសរសេរ : $M = F \times d$ ដែល F គិតជា N d គិតជា m M គិតជា Nm ។
- ម៉ូម៉ង់កម្លាំងដែលធ្វើឱ្យអង្គធាតុវិលតាមទិសដៅទ្រនិចនាឡិកាជា ម៉ូម៉ង់អវិជ្ជមាន ។
- ម៉ូម៉ង់កម្លាំងដែលធ្វើឱ្យអង្គធាតុវិលតាមទិសដៅច្រាសពីទ្រនិចនាឡិកាជា ម៉ូម៉ង់វិជ្ជមាន ។
- អង្គធាតុមួយចល័តជុំវិញអ័ក្សមួយមានលំនឹង កាលណាផលបូកម៉ូម៉ង់កម្លាំងដែលមានអំពើលើអង្គធាតុស្មើនិងសូន្យ ឬម៉ូម៉ង់វិជ្ជមាន ( + ) ខាងឆ្វេងនៃអ័ក្សរង្វិលស្មើនិងម៉ូម៉ង់អវិជ្ជមាន ( – ) ខាងស្តាំនៃអ័ក្សរង្វិល ។

## សំណួរនិងលំហាត់

1 ដូចម្ដេចហៅថា ម៉ូម៉ង់កម្លាំង ?

2. ចូរសរសេររូបមន្តម៉ូម៉ង់កម្លាំងនិងបញ្ជាក់ខ្នាតរបស់វា ។

3. ហេតុអ្វីបានជាគេយកដៃរុញទ្វារក្បែរត្រចៀកវាពិបាកបើកជាងយកដៃរុញត្រង់គែមទ្វារឬត្រង់សោទ្វារ ?

4. គេបញ្ចេញកម្លាំង 10N កែងនឹងសោមួយមានប្រវែង 0.2m ។ គណនាម៉ូម៉ង់កម្លាំងមានអំពើលើដងសោមួលខ្ចៅនោះ :



ក. ត្រង់ចំណុចកណ្ដាលនៃដងសោ

ខ. ត្រង់ចំណុចចុងនៃដងសោ ។

5. គណនាម៉ូម៉ង់កម្លាំងដូចរូបខាងក្រោម ។




6. មនុស្សម្នាក់មានទម្ងន់ 600N អង្គុយនៅលើចុងម្ខាងនៃដងថ្លឹងចម្ងាយ 1.5m ពីអ័ក្សរង្វិល ។ ដើម្បីឱ្យដងថ្លឹងមានលំនឹងស្ថិតតាមទិសដេក តើគេត្រូវដាក់មនុស្សម្នាក់ទៀតមានទម្ងន់ប៉ុន្មានអង្គុយនៅលើចុងម្ខាងទៀតនៃដងថ្លឹងដែលមានប្រវែង 2m ពីអ័ក្សរង្វិល ។

7. គេព្យួរអង្គធាតុពីរ ទម្ងន់ $F_1 = 400N$ និង $F_2 = 100N$ ទៅនឹងចុងសងខាងនៃរបារមួយទម្ងន់ $F_3 = 100N$ ប្រវែង $d = 40cm$ ។ តើគេត្រូវដាក់កំណាល់ត្រង់កន្លែងណានៃរបារ ដើម្បីឱ្យវាមានលំនឹង ?

# 3 ទីប្រជុំទម្ងន់

**ចប់មេរៀននេះ សិស្សអាច**

- ពោលនិយមន័យទីប្រជុំទម្ងន់
- កំណត់ទីប្រជុំទម្ងន់នៃអង្គធាតុរឹងដែលមិនមានរាងធរណីមាត្រងាយនិងមានរាងធរណីមាត្រងាយ
- កំណត់ទីតាំងលំនឹងនៃអង្គធាតុរឹង ។

## 1. ទីប្រជុំទម្ងន់

តើយើងត្រូវដាក់ម្រាមដៃត្រង់ទីតាំងណា ដើម្បីឱ្យចង្កឹះមានលំនឹង ?




*ទីប្រជុំទម្ងន់នៃចង្កឹះ*

យើងបានសិក្សារួចមកហើយថា គ្រប់អង្គធាតុមានទម្ងន់ដោយសារវារងនូវកម្លាំងទំនាញផែនដីដែលមានទិសនិងទិសដៅពីលើចុះក្រោម ។ ដូចនេះ យើងអាចចែកចង្កឹះទាំងមូលជាចំណែកតូចៗយ៉ាងច្រើនដែលចំណែកនីមួយៗរងនូវទម្ងន់មួយដែលមានទិសស្របៗគ្នា ។

នៅពេលចង្កឹះមានលំនឹងនៅលើចង្អុលដៃ ទម្ងន់របស់វាទាំងមូលហាក់បីដូចជាប្រមូលផ្តុំគ្នានៅត្រង់ចំណុចមួយ ។ ចំណុចនោះហៅថា ទីប្រជុំទម្ងន់ ។ ទីប្រជុំទម្ងន់នៃអង្គធាតុមួយ គឺជាចំណុចមួយដែលទម្ងន់ទាំងមូលនៃអង្គធាតុហាក់បីដូចជាមកផ្តុំគ្នាត្រង់ចំណុចនោះ ។

ចូរអ្នកសាកល្បងរកទីប្រជុំទម្ងន់នៃបន្ទាត់ក្រិត ខ្មៅដៃ សៀវភៅ ដោយផ្លាស់ទីតាំងរបស់វានៅលើចង្អុលដៃដោយលៃយ៉ាងណា ដើម្បីឱ្យវាមានលំនឹង ។

# 2. ការកំណត់ទីប្រជុំទម្ងន់នៃអង្គធាតុរឹង

## 2.1. អង្គធាតុរឹងស្មើសាច់មិនមានរាងធរណីមាត្រងាយ

### ក. ពិសោធន៍




យើងយកក្រដាសរឹងមួយបន្ទះ (មានរាងដូចម្ដេចក៏បាន) មកចងព្យួរត្រង់ប្រហោងតូចមួយ A នៅក្បែរគែម រួចយើងយកកូនប្រយោលមួយមកចងព្យួរជាមួយគ្នា ។ កាលណាវាសំយ៉ុងចុះនឹងថ្កល់ហើយ យើងយកខ្មៅដៃមកគូសបន្ទាត់ AA' តាមខ្សែកូនប្រយោល ។ បន្ទាប់មកទៀត យើងព្យួរវាម្ដងទៀតដោយចងត្រង់ប្រហោងតូច B ផ្សេងទៀតដែលនៅក្បែរគែម រួចគូសបន្ទាត់ BB' ដូចមុន ។

បន្ទាត់ AA' និង BB' កាត់គ្នាត្រង់ចំណុច G ។ ចំណុចនេះមានលក្ខណៈពិសេសមួយគឺ កាលណាយើងផ្តេកបន្ទះនោះដោយយកចុងម្រាមដៃមកទ្រចំណុច G នេះ បន្ទះនេះមិនធ្លាក់ឡើយ ។ ចំណុច G នេះហៅថា ទីប្រជុំទម្ងន់នៃបន្ទះ ។

### ខ. សន្និដ្ឋាន

ចំពោះអង្គធាតុរឹងស្មើសាច់មិនមានរាងធរណីមាត្រងាយ ទីប្រជុំទម្ងន់របស់វាមានតែមួយគត់ដែលឋិតនៅលើខ្សែឈរ ហើយកាត់តាមចំណុចប្រសព្វនៃខ្សែឈរដូចរូបខាងលើ ។

## 2.2. អង្គធាតុរឹងស្មើសាច់មានរាងធរណីមាត្រងាយ



ចំពោះអង្គធាតុរឹងស្មើសាច់និងមានរាងធរណីមាត្រងាយដូចជា ការេ ត្រីកោណ ចតុកោណកែង រង្វង់ យើងអាចរកទីប្រជុំទម្ងន់របស់វាដោយគ្រាន់តែគូសអង្កត់ទ្រូង ឬមេដ្យាន ឬមេដ្យានទ័ររបស់វាតែប៉ុណ្ណោះដោយមិនចាំបាច់ប្រើវិធីព្យួរទេ ។ ចំណុចប្រសព្វរវាងអង្កត់ទ្រូង ឬមេដ្យាន ឬមេដ្យានទ័រគឺជាទីប្រជុំទម្ងន់របស់វា ។ រីឯអង្គធាតុរឹងស្មើសាច់និងមានរាងធរណីមាត្រខ្លះទៀតដូចជា ស៊ីឡាំង ពីរ៉ាមីត ប្រលេពីប៉ែតកែង គូប ... ទីប្រជុំទម្ងន់របស់វាឋិតលើអ័ក្សអង្គធាតុនិងត្រួតស៊ីគ្នានិងផ្ចិតធរណីមាត្រ ។

## 3. លំនឹងរបស់អង្គធាតុមួយឋិតលើប្លង់

យើងលើកយកលំនឹងនៃអង្គធាតុមួយដែលឋិតលើប្លង់ដេកមកសិក្សា ។

អង្គធាតុមួយរងនូវកម្លាំងផ្សេងៗ វាអាចមានចលនាឬនៅស្ងៀម ។ បើកូនឃ្លីមួយកំពុងរមៀល គេថាវាមានចលនា បើវាឈប់ស្ងៀមមួយកន្លែង គេថាវាមានលំនឹង ។

### 3.1. លំនឹងរបស់អង្គធាតុមួយឋិតលើប្លង់ដេក

#### ក. ពិសោធន៍

យើងដាក់អង្គធាតុស្មើសាច់ដែលមានរាងប្រលេពីប៉ែតកែងមួយនៅលើតុ ។ បន្ទាប់មកយើងផ្លាស់ទីតាំងរបស់វា ដើម្បីសិក្សាពីលក្ខខណ្ឌលំនឹងរបស់វា ។ យើងទាញបង្ហើបតែម្ខាង រួចលែងវាវិញ ពេលនោះយើងឃើញវាវិលដោយខ្លួនឯងទៅរកទីតាំងលំនឹងរបស់វាវិញ ។ ប្រសិនបើយើងបន្តទាញវាឱ្យហើបដល់ទីតាំងកំណត់មួយ នោះយើងសង្កេតឃើញថា វាមិនត្រឡប់មកទីតាំងដើមវិញទេ គឺវាដួលដេកទៅជ្រុងម្ខាងទៀត ។




- នៅត្រង់ទីតាំងទី I ជាទីតាំងលំនឹងស៊ប់នៃអង្គធាតុ ។ ខ្សែឈរនៃទីប្រជុំទម្ងន់របស់វាកាត់កែងតាមចំណុចមួយដែលឋិតនៅក្នុងប្លង់បាតទម្រ ។
- នៅត្រង់ទីតាំងទី II អង្គធាតុផ្អៀងបន្តិច ។ ប៉ុន្តែខ្សែឈរនៃទីប្រជុំទម្ងន់របស់វាកាត់តាមចំណុចមួយដែលឋិតនៅក្នុងប្លង់បាតទម្រដដែល ។ នៅត្រង់ទីតាំងនេះ ម៉ូម៉ង់ទម្ងន់នៃអង្គធាតុទាញអង្គធាតុទៅរកទីតាំងលំនឹងដើមរបស់វាវិញ កាលណាគេដោះកំណាល់ចេញ ។

- នៅត្រង់ទីតាំងទី III ខ្សែឈរនៃទីប្រជុំទម្ងន់របស់វាកាត់តាមចំណុចមួយដែលឋិតនៅចំគែមខាងក្នុងនៃប្លង់បាតទម្រ ។ នៅត្រង់ទីតាំងនេះអង្គធាតុឋិតក្នុងស្ថានភាពលំនឹងមិនស៊ប់ ។
- នៅត្រង់ទីតាំងទី IV ខ្សែឈរនៃទីប្រជុំទម្ងន់របស់វាកាត់តាមចំណុចមួយដែលឋិតនៅខាងក្រៅប្លង់បាតទម្រ ។ នៅត្រង់ទីតាំងនេះ ម៉ូម៉ង់ទម្ងន់នៃអង្គធាតុទាញអង្គធាតុទៅរកទីតាំងថ្មីមួយទៀត ។

ខ. សន្និដ្ឋាន

អង្គធាតុរឹងមួយដាក់លើប្លង់ដេកមានលំនឹងស៊ប់ កាលណាខ្សែឈរនៃទីប្រជុំទម្ងន់របស់វាកាត់តាមចំណុចមួយដែលឋិតនៅក្នុងប្លង់បាតទម្រ ។

អង្គធាតុរឹងមួយដាក់លើប្លង់ដេកមានលំនឹងមិនស៊ប់ កាលណាខ្សែឈរនៃទីប្រជុំទម្ងន់របស់វាកាត់តាមចំណុចមួយដែលឋិតនៅក្បែរៗគែមខាងក្នុងឬខាងក្រៅនៃប្លង់បាតទម្រ ។

អង្គធាតុរឹងមួយដាក់លើប្លង់ដេកគ្មានលំនឹង កាលណាខ្សែឈរនៃទីប្រជុំទម្ងន់របស់វាកាត់តាមចំណុចមួយដែលឋិតនៅក្រៅប្លង់បាតទម្រ ។

### 3.2. លំនឹងរបស់អង្គធាតុមួយលើប្លង់ទេរ




ពេលនេះយើងមិនទាញអង្គធាតុនោះឱ្យផ្អៀងទៀតទេ តែយើងធ្វើប្លង់ដាក់ទ្រវាឱ្យផ្អៀងវិញម្តង ។ យើងសង្កេតឃើញថា ដរាបណាខ្សែឈរនៃទីប្រជុំទម្ងន់របស់វាកាត់តាមចំណុចមួយដែលឋិតនៅក្នុងប្លង់បាតទម្រ អង្គធាតុនោះនៅតែមានលំនឹងដដែល ។ ប៉ុន្តែបើខ្សែឈរនៃទីប្រជុំទំងន់របស់វាកាត់តាមចំណុចមួយដែលឋិតនៅក្រៅប្លង់បាតទម្រ អង្គធាតុនោះមិនឋិតក្នុងភាពលំនឹងដដែលទេ ។

## 4. វិធីបង្កើនភាពស៊ប់នៃលំនឹង

ប្រសិនបើទីប្រជុំទម្ងន់កាន់តែខ្ពស់ទៅហើយផ្ទៃបាតទម្រកាន់តែតូចទៅ ភាពស៊ប់នៃលំនឹងរបស់អង្គធាតុក៏កាន់តែតូចទៅដែរ ។ ដូចនេះដើម្បីបង្កើនភាពស៊ប់នៃលំនិងរបស់អង្គធាតុ គេត្រូវបន្ទាបទីប្រជុំទម្ងន់និងបង្កើនផ្ទៃនៃបាតទម្រ ។

ក្នុងការធ្វើវត្ថុប្រើប្រាស់ផ្សេងៗ គេត្រូវគិតពីភាពសិប់នៃលំនឹងរបស់វត្ថុនោះ ។ ឧទាហរណ៍ :

- មនុស្សរកន្ធែកជើង(បន្ទាបទីប្រជុំទម្ងន់និងបង្កើនផ្ទៃបាតទម្រ)ដើម្បីធ្វើឱ្យមានលំនឹងសិប់ ។
- ដបទឹកខ្មៅមានរាងទាបហើយមានបាតទម្រធំជានិច្ច ។ គេធ្វើយ៉ាងនេះដើម្បីឱ្យវាមានលំនឹងសិប់ ។
- កង្ហារអគ្គិសនីឬមីក្រូហ្វូនមានជើងទម្រធ្ងន់ដែលជាហេតុនាំឱ្យទីប្រជុំទម្ងន់ចុះក្រោមហើយបាតទម្រផ្ទៃធំ ។
- គេមិនត្រូវផ្ទុកអីវ៉ាន់ធ្ងន់ៗលើដំបូលរទេះឬដំបូលរថយន្តឱ្យខ្ពស់ពេកទេ ព្រោះវាបាត់ភាពលំនឹងសិប់ ដោយសារតែទីប្រជុំទម្ងន់ខិតខ្ពស់ឡើងលើ ។

## មេរៀនសង្ខេប

- ទីប្រជុំទម្ងន់នៃអង្គធាតុមួយ គឺជាចំណុចមួយដែលទម្ងន់ទាំងមូលនៃអង្គធាតុហាក់បីដូចមកផ្តុំគ្នាត្រង់ចំណុចនោះ ។
- ចំពោះអង្គធាតុរឹងស្មើសាច់និងមិនមានរាងធរណីមាត្រងាយ ដើម្បីរកទីប្រជុំទម្ងន់របស់វាគេប្រើវិធីព្យួរច្រើនដង ។
- ចំពោះអង្គធាតុរឹងស្មើសាច់និងមានរាងធរណីមាត្រងាយ ទីប្រជុំទម្ងន់របស់វាត្រួតស៊ីគ្នានិងផ្ចិតធរណីមាត្រ ។
- អង្គធាតុរឹងមួយដាក់លើប្លង់ដេកមានលំនឹង កាលណាខ្សែឈរនៃទីប្រជុំទម្ងន់របស់វាកាត់តាមចំណុចមួយដែលឋិតនៅក្នុងប្លង់បាតទម្រ ។ ប៉ុន្តែបើខ្សែឈរនៃទីប្រជុំទម្ងន់របស់វាកាត់តាមចំណុចមួយដែលឋិតនៅក្រៅប្លង់បាតទម្រ អង្គធាតុនោះមិនឋិតក្នុងភាពលំនឹងដដែលទេ ។

## ? សំណួរនិងលំហាត់

1. ដូចម្តេចហៅថា ទីប្រជុំទម្ងន់ ? តើវត្ថុ ឬអង្គធាតុមួយមានទីប្រជុំទម្ងន់ប៉ុន្មាន ?
2. តើគេប្រើវិធីអ្វី ដើម្បីរកទីប្រជុំទម្ងន់នៃអង្គធាតុរឹងស្មើសាច់មួយមិនមានរាងធរណីមាត្រងាយ ?
3. តើអ្នកអាចរកទីប្រជុំទម្ងន់នៃបន្ទាត់ក្រិតរបស់អ្នកបានដែរឬទេ ដោយមិនចាំបាច់ប្រើវិធីចងព្យួរ ?
4. ចូរកាត់ក្រដាសរឹងជារូបផែនទីប្រទេសកម្ពុជា ហើយរកទីប្រជុំទម្ងន់របស់វា ។ តើទីប្រជុំទម្ងន់នៃផែនទីប្រទេសកម្ពុជាស្ថិតនៅក្នុងខេត្តណា ?
5. ហេតុអ្វីបានជាយើងមិនត្រូវផ្ទុកអីវ៉ាន់ធ្ងន់ៗលើដំបូលរទេះឬដំបូលរថយន្តឱ្យខ្ពស់នៅពេលកំពុងបើកបរ ? ចូរពន្យល់ ។

## ? សំណួរបញ្ចប់ជំពូកទី១

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

1. ម៉ូម៉ង់កម្លាំងមួយជាទំហំដែលកំណត់ដោយ :

☐ ក. ផលចែករវាងកម្លាំងចាប់និងប្រវែងដៃឃ្នាស់ ។

☐ ខ. ផលគុណរវាងកម្លាំងចាប់និងប្រវែងដៃឃ្នាស់ ។

☐ គ. ផលដករវាងកម្លាំងចាប់និងប្រវែងដៃឃ្នាស់ ។

☐ ឃ. ផលបូករវាងកម្លាំងចាប់និងប្រវែងដៃឃ្នាស់ ។

2. អង្គធាតុមួយដែលអាចចល័តជុំវិញអ័ក្សមួយមានលំនឹងកាលណា :

☐ ក. ផលបូកម៉ូម៉ង់កម្លាំងចាប់លើអង្គធាតុនោះស្មើសូន្យ ។

☐ ខ. ផលដកម៉ូម៉ង់កម្លាំងចាប់លើអង្គធាតុនោះស្មើសូន្យ ។

☐ គ. ផលគុណម៉ូម៉ង់កម្លាំងចាប់លើអង្គធាតុនោះស្មើសូន្យ ។

☐ ឃ. ផលចែកម៉ូម៉ង់កម្លាំងចាប់លើអង្គធាតុនោះស្មើសូន្យ ។

3. ទីប្រជុំទម្ងន់របស់អង្គធាតុគឺ

☐ ក. ជាចំណុចកណ្ដាលនៃអង្គធាតុ ។

☐ ខ. ជាចំណុចមួយដែលធ្វើឱ្យអង្គធាតុមានលំនឹង ។

☐ គ. ជាចំណុចមួយដែលទម្ងន់ទាំងមូលនៃអង្គធាតុហាក់បីដូចមកផ្ដុំគ្នាត្រង់ចំណុចនោះ ។

☐ ឃ. ជាចំណុចមួយដែលស្ថិតនៅលើអង្កត់ទ្រូងរបស់អង្គធាតុ ។

4. ក្នុងបណ្ដារូបខាងក្រោម តើមួយណាដែលបង្ហាញពីលំនឹងគ្រប់ទិសនៃអង្គធាតុ ?




II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. ចម្ងាយរវាងអ័ក្សរង្វិលទៅនិងខ្សែសកម្មនៃកម្លាំងហៅថា .................... ។
2. ម៉ូម៉ង់ដែលធ្វើឱ្យអង្គធាតុវិលតាមទិសដៅរង្វិលនៃទ្រនិចនាឡិកាហៅថា .................... ។
3. ម៉ូម៉ង់ដែលធ្វើឱ្យអង្គធាតុវិលតាមទិសដៅច្រាសនឹងរង្វិលនៃទ្រនិចនាឡិកាហៅថា .................... ។

4. អង្គធាតុរឹងមួយចល័តជុំវិញអ័ក្សដេក កាលណាទីប្រជុំទម្ងន់របស់វាស្ថិតនៅខាងក្រោមអ័ក្សដែលកាត់តាមខ្សែឈរនៃអ័ក្សនោះ គេថាអង្គធាតុមានលំនឹង ................... ។

5. អង្គធាតុរឹងមួយដាក់លើប្លង់ដេក កាលណាទីប្រជុំទម្ងន់របស់វានៅខ្ពស់ ហើយចំណោលកែងរបស់វាស្ថិតនៅក្បែរបាតទម្រ គេថាអង្គធាតុនោះមានលំនឹង ................... ។

III. លំហាត់

1. ទ្វារមួយត្រូវការម៉ូម៉ង់អប្បបរមា 32.5N·m ដើម្បីបិទបើក។ តើគេត្រូវដាក់ដៃទ្វារនៅចម្ងាយប៉ុន្មានពីត្រចៀក បើគេដឹងថាដើម្បីបិទឬបើក គេត្រូវបញ្ចេញកម្លាំងមិនលើសពី 50N ?

2. ក្នុងចំណោមរូបខាងក្រោមតើមួយណាមានម៉ូម៉ង់កម្លាំងធំជាងគេ ? តូចជាងគេ ? និងមានម៉ូម៉ង់កម្លាំងស្មើគ្នា ?



# ជំពូកទី 2 ម៉ាស៊ីនងាយ



ក្នុងការបំពេញការងារខ្លះៗ ដូចជាយោងបន្ទុកឡើងលើ ផ្លាស់ទីកន្លែងវត្ថុធ្ងន់ៗ កាប់គាស់ជីកកាយ ... គេប្រើឧបករណ៍ច្រើនប្រភេទដូចជា ឃ្នាស់ រ៉ក ប្លង់ទេរ ស្ពី ត្រីយ ... ឧបករណ៍ទាំងនោះហៅថា ម៉ាស៊ីនងាយ ។

ដូចនេះម៉ាស៊ីនងាយជាឧបករណ៍ទាំងឡាយណាដែលអាចកែប្រែល្បឿន ប្ដូរទិសដៅកម្លាំងចលករ និងបង្កើនឬបន្ថយអាំងតង់ស៊ីតេកម្លាំងចលករ ។

# 1 ឃ្នាស់

**ចប់មេរៀននេះ សិស្សអាច**

- ❑ កំណត់និយមន័យឃ្នាស់
- ❑ រៀបរាប់គោលការណ៍រក្សាកម្មន្តនៃឃ្នាស់
- ❑ អនុវត្តការប្រើប្រាស់ឃ្នាស់ក្នុងជីវភាពរស់នៅនិងក្នុងបច្ចេកទេស ។

## 1. ឃ្នាស់

ឧបមាថាយើងចង់រំកិលថ្មមួយដុំយ៉ាងធំដែលយើងមិនអាចរុញឬលើកវារួច ។ ប៉ុន្តែបើយើងយករបាររឹងមួយមកដាក់(ដូចរូបខាងក្រោម)យើងគ្រាន់តែសង្កត់ចុង B នៃរបារនេះ ដុំថ្មនឹងរបើក ហើយផ្លាស់ទីទៅយ៉ាងស្រួល ។ របាររឹងដែលមានកំណាល់ហៅថា ឃ្នាស់ ។

ឃ្នាស់ជាអង្គធាតុរឹងមាំចល័តជុំវិញចំណុចនឹងមួយហៅថា ចំណុចទម្រ ឬចល័តជុំវិញអ័ក្សមួយហៅថា អ័ក្សទម្រ ។

បើយើងពិនិត្យឃ្នាស់នេះឱ្យម៉ត់ចត់(ដូចរូបខាងក្រោម) យើងឃើញថា របារ ឬអង្គធាតុរឹងរងនូវកម្លាំងពីរគឺ

- កម្លាំងមួយចាប់ត្រង់ A ដែលជាកម្លាំងត្រូវជំនះហៅថា កម្លាំងទប់ ឬបន្ទុក $F_R$ ។ រីឯចម្ងាយពីចំណុចទម្រឬអ័ក្សទម្រ (O) ទៅទិសនៃកម្លាំងទប់ ($F_R$) ជា ប្រវែងដៃឃ្នាស់បន្ទុក ($d_R$) ។
- កម្លាំងមួយទៀតចាប់ត្រង់ B ដែលជាកម្លាំងបញ្ចេញលើឃ្នាស់ជា កម្លាំងចលករ $F_E$ ។ រីឯចម្ងាយពីចំណុចទម្រឬអ័ក្សទម្រ (O) ទៅទិសនៃកម្លាំងចលករ ($F_E$) ជាប្រវែងដៃឃ្នាស់ចលករ ($d_E$) ។






ឧបមាថា ដុំថ្មខាងលើមានទម្ងន់ 1000N បើគេចង់លើកឬផ្លាស់ទីវា គេត្រូវចំណាយកម្លាំងស្មើឬធំជាង 1000N កាលណាគ្មានដៃឃ្នាស់ឬកាលណាប្រវែងដៃឃ្នាស់ OA = OB ។ ប៉ុន្តែ ប្រសិនបើគេប្រើឃ្នាស់ដែលមានប្រវែងដៃឃ្នាស់ OB វែងជាងដៃឃ្នាស់ OA 5 ដង តើគេត្រូវចំណាយកម្លាំងចលករប៉ុន្មាន ?

តាមគោលការណ៍ម៉ូម៉ង់ ដើម្បីឱ្យឃ្នាស់មានលំនឹងលុះត្រាតែ $F_E \times OB = F_R \times OA$

$$F_E = \frac{F_R \times OA}{OB} = \frac{F_R \times 1}{5} \text{ ឬ } F_E = \frac{1000N \times 1}{5} = 200N$$

$F_E = 200N$

ដូចនេះបើគេប្រើឃ្នាស់ គេចំណាយកម្លាំងតែ 200N ប៉ុណ្ណោះ ដើម្បីលើកឬផ្លាស់ទីវា ។ មានន័យថា បើគេប្រើឃ្នាស់ដែលមានបណ្តោយដៃឃ្នាស់ចលករ OB វែងជាងប្រវែងដៃឃ្នាស់បន្ទុក OA 5 ដង នោះគេចំណាយកម្លាំងចលករតិចជាងបន្ទុក 5 ដង ។

## 2. គោលការណ៍កម្មន្តនៃឃ្នាស់




ឧបមាថាយើងចង់លើកអង្គធាតុមួយទម្ងន់ 2N ត្រង់ឡើងលើឱ្យបានកម្ពស់ 0.1m ចាំបាច់យើងត្រូវធ្វើកម្មន្ត $W = 2N \times 0.1m = 0.2J$ ។

ឥឡូវនេះយើងធ្វើកម្មន្តដដែលដោយប្រើឃ្នាស់វិញម្តង ។ យើងដាក់អង្គធាតុទម្ងន់ 2N ដដែលនៅចុងម្ខាងនៃដៃឃ្នាស់ ហើយនៅលើដៃឃ្នាស់ម្ខាងទៀតយើងផ្លាស់ទីអង្គធាតុមួយទម្ងន់ 0.5N សន្សឹមៗឡើងលើ ។ នៅពេលយើងបង្ខិតអង្គធាតុដល់ត្រង់ B ឃ្នាស់ចាប់ផ្តើមបះហើយមានលំនឹងនៅពេលដែលចំណុច A ផ្លាស់ទីដល់ A' បានកម្ពស់ $h_1 = 10cm$ យើងទប់ឃ្នាស់ហើយវាស់ ឃើញ B ផ្លាស់ទីមក B' បានកម្ពស់ $h_2 = 40cm$ ។ ដូចនេះយើងសង្កេតឃើញថា

អង្គធាតុទម្ងន់ 2N ធ្វើកម្មន្តបាន $W_1 = P_1 \times h_1 = 2N \times 0.1m = 0.2J$

អង្គធាតុទម្ងន់ 0.5N ធ្វើកម្មន្តបាន $W_2 = P_2 \times h_2 = 0.5N \times 0.4m = 0.2J$

យើងបាន $W_1 = W_2 = 0.2J$ ។

## 3. អនុវត្តន៍ឃ្នាស់ក្នុងជីវភាពរស់នៅនិងក្នុងបច្ចេកទេស

ឃ្នាស់មានទម្រង់ខុសៗគ្នា ។ ប៉ុន្តែគេចែកចេញជាបីប្រភេទដោយផ្អែកលើទីតាំង ចំណុចទម្រឬអ័ក្សរង្វិល (O) កម្លាំងទប់ ($F_R$) និងកម្លាំងចលករ ($F_E$) ។

### 3.1. ប្រភេទឃ្នាស់ទី 1

ឃ្នាស់ទម្រកណ្ដាល ជាឃ្នាស់ដែលចំណុចទម្រឋិតនៅចន្លោះកម្លាំងចលករ ($F_E$) និងកម្លាំងទប់ ($F_R$) ។ *ឧទាហរណ៍ :* ឃ្នាស់គាស់ដែកគោល ដងថ្លឹង កន្ត្រៃ ដង្កាប់ ដែកស្បែង ត្បាល់ជាន់ ឈ្នាន់ប្រាំងរថយន្ត ។ល។



*ឃ្នាស់ទម្រកណ្ដាល*

ឃ្នាស់ចំណុចទម្រកណ្ដាលជាឧបករណ៍ងាយប្រើ ពីព្រោះនៅពេលគេគាស់ថ្មឬឈើធំៗ គេគ្រាន់ចំណាយកម្លាំងបន្តិចក៏អាចគាស់ថ្មឬឈើបានដែរ ។ គេអាចនិយាយម្យ៉ាងទៀតថា ឃ្នាស់ចំណុចទម្រកណ្ដាលជាឃ្នាស់បង្កើនកម្លាំង ។

### 3.2. ប្រភេទឃ្នាស់ទី 2



*ឃ្នាស់ទំនប់កណ្ដាល*

ឃ្នាស់ទំនប់កណ្ដាល ជាឃ្នាស់ដែលកម្លាំងទប់ឬបន្ទុកឋិតនៅចន្លោះកម្លាំងចលករ ($F_E$) និងចំណុចទម្រ (O) ។

*សំគាល់ :* ក្នុងការប្រើឃ្នាស់ប្រភេទទី 1 និង 2 គេត្រូវចំណាយកម្លាំងចលករតូចជាងកម្លាំងទប់ ។

### ៣.៣. ប្រភេទឃ្នាស់ទី ៣

ឃ្នាស់ចលករកណ្ដាល ជាឃ្នាស់ដែលកម្លាំងចលករ ($F_E$) ឋិតនៅចន្លោះចំណុចទម្រចលករ (O) និងកម្លាំងទប់ ($F_R$) ។






*ឃ្នាស់ចលករកណ្ដាល*

*សំគាល់ :* ក្នុងការប្រើឃ្នាស់ប្រភេទទី 3 គេត្រូវចំណាយកម្លាំងចលករធំជាងកម្លាំងទប់ ។

## 4. ផលមេកានិចនៃឃ្នាស់

បន្ទុកនេះមានទម្ងន់ 40N ។ ដូចនេះ ខ្ញុំត្រូវការកម្លាំងចលករ 40N ដើម្បីលើកឬផ្លាស់ទីវាដោយផ្ទាល់ ។




នៅពេលខ្ញុំប្រើឃ្នាស់ នោះកម្លាំងចលករដែលខ្ញុំត្រូវបញ្ចេញតូចជាង40N ។




បើគេធ្វើផលធៀបរវាងកម្លាំងទប់ឬបន្ទុក($F_R$) និងកម្លាំងចលករ($F_E$) ឬផលធៀបរវាងដៃឃ្នាស់ចលករ($d_E$) និងដៃឃ្នាស់បន្ទុក ($d_R$) នៃឃ្នាស់មួយ គេបានទំហំមួយហៅថា ផលមេកានិច (Mechanical Advantage) ឬ MA នៃឃ្នាស់ ។

គេសរសេរ : $MA = \frac{F_R}{F_E}$ ឬ $MA = \frac{d_E}{d_R}$ ។

ឧទាហរណ៍ : គណនាផលមេកានិចនៃឃ្នាស់មួយ បើគេបញ្ចេញកម្លាំងចលករ 10N គេអាចលើកបន្ទុកមួយទម្ងន់ 40N ។

ផលមេកានិចនៃឃ្នាស់ $MA = \frac{F_R}{F_E}$

ដោយ $F_E = 10N$ និង $F_R = 40N$

$MA = \frac{40N}{10N} = 4$ ផលមេកានិចស្មើនឹង 4 មានន័យថា បើប្រើឃ្នាស់ គេចំណេញកម្លាំងចលករ4 ដងធំជាងបន្ទុក ។

*សំគាល់* : ក្នុងការប្រើឃ្នាស់ដើម្បីលើកបន្ទុកដដែល បើប្រវែងដៃឃ្នាស់ចលករកាន់តែវែង នោះផលមេកានិចនៃឃ្នាស់ក៏កាន់តែធំដែរ ។

## មេរៀនសង្ខេប

- ឃ្នាស់ ជាអង្គធាតុរឹងមាំចល័តជុំវិញចំណុចនឹងមួយដែលហៅថា ចំណុចទម្រ ឬចល័តជុំវិញអ័ក្សមួយដែលហៅថា អ័ក្សទម្រ ។
- គេចែកឃ្នាស់ចេញជាបីប្រភេទដោយផ្អែកលើទីតាំង អ័ក្សទម្រឬចំណុចទម្រ (O) កម្លាំងទប់ ($F_R$) និងកម្លាំងចលករ ($F_E$) ។
  - ឃ្នាស់ទម្រកណ្តាលដែលចំណុចទម្រឋិតនៅចន្លោះកម្លាំងចលករ ($F_E$) និងកម្លាំងទប់ ($F_R$)
  - ឃ្នាស់ទំនប់កណ្តាលដែលកម្លាំងទប់ឬបន្ទុកឋិតនៅចន្លោះកម្លាំងចលករ ($F_E$) និងទម្រ(O)
  - ឃ្នាស់ចលករកណ្តាលដែលកម្លាំងចលករ ($F_E$) ឋិតនៅចន្លោះចំណុចទម្រចលករ (O) និងកម្លាំងទប់ ($F_R$) ។
- ផលមេកានិចនៃឃ្នាស់ : $MA = \frac{F_R}{F_E}$ ឬ $MA = \frac{d_E}{d_R}$ ។

## ? សំណួរនិងលំហាត់

1. ដូចម្តេចហៅថា ឃ្នាស់ ? តើផ្នែកសំខាន់ៗនៃឃ្នាស់មានអ្វីខ្លះ ?
2. តើគេចែកឃ្នាស់ជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
3. ដូចម្តេចហៅថា ឃ្នាស់ទម្រកណ្តាល ? ឃ្នាស់ទំនប់កណ្តាល ? និងឃ្នាស់ចលករកណ្តាល ?
4. ចូររកឧបករណ៍ដែលប្រើប្រាស់ឃ្នាស់ទម្រកណ្តាល ឃ្នាស់ទំនប់កណ្តាល និងឃ្នាស់ចលករកណ្តាល ។

5. ដូចម្ដេចហៅថា ផលមេកានិចនៃឃ្នាស់ ?

6. គេប្រើរបារដែកមួយមានប្រវែង 1.2m ធ្វើជាឃ្នាស់ដើម្បីគាស់បន្ទុកមួយមានម៉ាស 60kg ។ ចំណុចទម្រនៃឃ្នាស់ឋិតនៅចម្ងាយ 30cm ពីបន្ទុក ។ គណនាផលមេកានិចនៃឃ្នាស់និងកម្លាំងចលករ ។ (គេឱ្យ $g = 10m/s^2$ ) ។

7. បន្ទាត់មួយមានប្រវែង 50cm ចល័តជុំវិញអ័ក្សដេកមួយកាត់តាមទីប្រជុំទម្ងន់របស់វាដែលឋិតនៅចំកណ្ដាលបន្ទាត់ ។ គេព្យួរទម្ងន់ 3N នៅចុងម្ខាងនៃបន្ទាត់នោះ ។ តើគេព្យួរទម្ងន់ប៉ុន្មានញូតុននៅផ្នែកម្ខាងទៀតនៃអ័ក្សត្រង់ចំណុចមួយឋិតនៅចម្ងាយ 20cm ពីអ័ក្សនោះ ដើម្បីរក្សាបន្ទាត់ឱ្យមានលំនឹង ?

8. បន្ទុកមួយមានទម្ងន់ 40N នៅលើជញ្ជីង(ដូចរូប)ដែលស្ថិតនៅចម្ងាយ 0.3m ពីចំណុចទម្រ ។ តើគេត្រូវដាក់បន្ទុកមួយទៀតដែលមានទម្ងន់ 60N នៅចម្ងាយប៉ុន្មានពីចំណុចទម្រ ដើម្បីឱ្យជញ្ជីងមានលំនឹង ។

9. ជញ្ជីងមួយមានប្រវែង 40cm ។ នៅចុងសងខាងរបស់វាគេផ្ទុកទម្ងន់ 40N និង 80N ។ តើទីតាំងនៃចំណុចទម្រនៅត្រង់ណាដើម្បីឱ្យជញ្ជីងមានលំនឹងតាមទិសដេក ?

10. រូបខាងក្រោមនេះបង្ហាញពីបន្ទាត់ស្មើសាច់ព្យួរនឹងខ្សែមួយត្រង់ចំណុចកណ្ដាល ។ បន្ទាត់នេះផ្ទុកអង្គធាតុពីរហើយមានលំនឹង ។ តើអង្គធាតុ A មានទម្ងន់ប៉ុន្មាន ?




11 គេលើកអង្គធាតុមួយទម្ងន់ 60N ដោយប្រើឃ្នាស់ដូចរូបខាងក្រោម ។ គណនាផលមេកានិចនិងកម្លាំងចលករ ដើម្បីលើកអង្គធាតុនោះក្នុងករណីនីមួយៗ ។



មេរៀនទី

# 2 ប្លង់ទេរ

**ចប់មេរៀននេះ សិស្សអាច**

- កំណត់និយមន័យនៃប្លង់ទេរ
- ធ្វើពិសោធន៍បង្ហាញអំពីការលើក ឬដាក់វត្ថុមួយតាមប្លង់ទេរ ដោយបញ្ចេញកម្លាំងចលករតូចជាងបន្ទុកឬកម្លាំងទប់
- អនុវត្តប្លង់ទេរក្នុងជីវភាពរស់នៅ ។

ក្នុងការលើកដាក់វត្ថុធ្ងន់ៗ គេមិនសូវលើកវត្ថុមួយត្រង់ទៅលើទេ ។ គេច្រើនរុញឬប្រមៀលវាឡើងទៅលើតាមប្លង់ទេរ ។

## 1. និយមន័យ

ប្លង់ទេរ ជាផ្ទៃរាបមួយដែលភ្ជាប់ពីទីកន្លែងទាបទៅទីកន្លែងខ្ពស់ ។ បើគេលើកឬដាក់វត្ថុមួយតាមប្លង់ទេរ គេបញ្ចេញកម្លាំងចលករតូចជាងកម្លាំងទប់(បន្ទុក) ។ ប៉ុន្តែប្រវែងដែលបន្ទុកត្រូវផ្លាស់ទីវែងជាងប្រវែងដែលគេត្រូវលើកបន្ទុកឡើងត្រង់ទៅលើ ។




## 2. គោលការណ៍រក្សាកម្មន្តនៃប្លង់ទេរ

ប្លង់ទេរតាងដោយត្រីកោណកែងមួយ ABC ដែល BC ជាកម្ពស់និង AB ជាប្រវែងប្លង់ទេរ ។

តាង $F_R$ ជាទម្ងន់ឬបន្ទុកនៃវត្ថុដាក់លើប្លង់ទេរ និង $F_E$ ជាកម្លាំងចលករដែលធ្វើឱ្យវត្ថុឡើងទៅលើតាមបណ្តោយប្លង់ទេរ ដែលមានប្រវែង L និង h ជាកម្ពស់ប្លង់ទេរ ។

កម្មន្តដែលគេត្រូវធ្វើដើម្បីលើកវត្ថុមួយត្រង់ទៅលើគឺ $W_R = F_R \times h$

កម្មន្តដែលគេត្រូវធ្វើដើម្បីផ្លាស់ទីវត្ថុតាមប្លង់ទេរគឺ $W_E = F_E \times L$

តាមគោលការណ៍រក្សាកម្មន្ត គេសរសេរ $W_E = W_R$ ឬ $F_E \times L = F_R \times h$

$\boxed{F_E = F_R \times \frac{h}{L}}$ តាមទំនាក់ទំនងនេះ គេឃើញថា កាលណាប្រវែងប្លង់ទេរកាន់តែវែង នោះកម្លាំងចលករ ដើម្បីផ្លាស់ទីវត្ថុតាមប្លង់ទេរកាន់តែតូច(ប្រសិនបើគេមិនគិតកកិត) ។

***ឧទាហរណ៍ :*** កម្មករម្នាក់រុញរទេះមួយផ្ទុកទម្ងន់ 2400N ឡើងលើប្លង់ទេរមួយដែលមានប្រវែង 6m និងកម្ពស់ 1m ។ គណនាអាំងតង់ស៊ីតេកម្លាំងដែលកម្មករនោះត្រូវបញ្ចេញដើម្បីរុញរទេះ ។ (គេមិនគិតពីកម្លាំងកកិតរវាងកង់រទេះនិងប្លង់ទេរ)

អាំងតង់ស៊ីតេកម្លាំងដែលកម្មករនោះត្រូវបញ្ចេញដើម្បីរុញរទេះ

តាមរូបមន្ត : $F_E = F_R \times \frac{h}{L}$

ដោយទម្ងន់បន្ទុក $F_R = 2400N$ ប្រវែងប្លង់ទេរ $L = 6m$ និង កម្ពស់ $h = 1m$

$F_E = 2400N \times \frac{1}{6} = 400N$

ដូចនេះអាំងតង់ស៊ីតេកម្លាំងដែលកម្មករនោះត្រូវបញ្ចេញដើម្បីរុញរទេះគឺ $F_E = 400N$ ។

## 3. ផលមេកានិចនៃប្លង់ទេរ

បន្ទុកនេះមានទម្ងន់ 40N ។ ដូចនេះ ខ្ញុំត្រូវការកម្លាំងចលករ 40N ដើម្បីលើកឬផ្លាស់ទីវាឡើងត្រង់ទៅលើ ។




បើខ្ញុំប្រើប្លង់ទេរ នោះកម្លាំងចលករដែលខ្ញុំត្រូវបញ្ចេញតូចជាងទម្ងន់ ។




បើគេធ្វើផលធៀបរវាងកម្លាំងទប់(បន្ទុក)($F_R$) និងកម្លាំងចលករ($F_E$) ឬផលធៀបរវាងប្រវែង (L) និងកម្ពស់ (h) នៃប្លង់ទេរ គេបានទំហំមួយហៅថា ផលមេកានិច (MA) នៃប្លង់ទេរ ។

គេសរសេរ : $\boxed{MA = \frac{F_R}{F_E}}$ ឬ $\boxed{MA = \frac{L}{h}}$ ( $L > h$ ជានិច្ច) ។

*ឧទាហរណ៍* : ដើម្បីផ្លាស់ទីបន្ទុកមួយទម្ងន់ 200N ឡើងត្រង់ទៅលើ គេត្រូវបញ្ចេញកម្លាំង 200N ដែរ ។ បើគេប្រើប្លង់ទេរដែលមានប្រវែង 2m ដើម្បីផ្លាស់ទីបន្ទុកដដែលនេះឱ្យបានកម្ពស់ស្មើគ្នា គេត្រូវបញ្ចេញកម្លាំង 100N ប៉ុណ្ណោះ ។ តើផលមេកានិចនៃប្លង់ទេរស្មើនឹងប៉ុន្មាន ?

ផលមេកានិចនៃប្លង់ទេរ $MA = \frac{F_R}{F_E}$

ដោយ $F_E = 100N$ និង $F_R = 200N$

$MA = \frac{200N}{100N} = 2$ ផលមេកានិចស្មើនឹង 2 មានន័យថា បើប្រើប្លង់ទេរ គេចំណេញកម្លាំងចលករ 2 ដងធំជាងបន្ទុក ។

*សំគាល់* : ក្នុងការប្រើប្លង់ទេរ ប្រសិនបើប្រវែងប្លង់ទេរកាន់តែវែង នោះផលមេកានិចនៃប្លង់ទេរក៏កាន់តែធំដែរ ។

## 4. អនុវត្តន៍



*បំលាស់ទីស្នៀតក្នុងសាច់ឈើ*

ប្លង់ទេរត្រូវបានគេយកទៅធ្វើជាស្នៀតដើម្បីសៀតឬពុះបំបែកដុំវត្ថុមួយ ។ ស្នៀតមានរាងជាត្រីកោណដែលមានមុខខាងពីរជាប្លង់ទេរហើយធ្វើពីលោហៈ ថ្ម ឬឈើរឹង ។ គោលការណ៍របស់ស្នៀតមានលក្ខណៈស្រដៀងគ្នា និងប្លង់ទេរដែរ ។

នៅពេលគេប្រើស្នៀត ដុំឈើញែកចេញពីគ្នាធំជាងមុខកាត់ពុះ ហើយកម្លាំងចលករដើម្បីបំបែកឈើដោយប្រើស្នៀតតូចជាងកម្លាំងចលករដោយមិនប្រើស្នៀត ។

*ឧទាហរណ៍* : ពូថៅ កាំបិត ពន្លាក... ជាឧបករណ៍ប្រើប្រាស់ដែលមានមុខជាប្លង់ទេរ ។

### មេរៀនសង្ខេប

- ប្លង់ទេរ ជាផ្ទៃរាបមួយដែលភ្ជាប់ពីទីកន្លែងទាបទៅទីកន្លែងខ្ពស់ ។
- កាលណាប្រវែងប្លង់ទេរកាន់តែវែង នោះកម្លាំងចលករដើម្បីផ្លាស់ទីវត្ថុកាន់តែតូច(បើគេមិនគិតកកិត) ។
- ផលមេកានិចនៃប្លង់ទេរ $MA = \frac{F_R}{F_E}$ ឬ $MA = \frac{L}{h}$ ( $L > h$ ជានិច្ច)
- ក្នុងការប្រើប្លង់ទេរ ប្រសិនបើប្រវែងប្លង់ទេរកាន់តែវែង នោះផលមេកានិចនៃប្លង់ទេរក៏កាន់តែធំដែរ ។

## សំណួរនិងលំហាត់

1. ដូចម្ដេចហៅប្លង់ទេរ ?
2. ហេតុអ្វីបានជាគេចូលចិត្តប្រើប្លង់ទេរ ដើម្បីរុញឬប្រមៀលធុងសាំងឡើងលើរថយន្ត ?
3. តើជណ្ដើរឡើងផ្ទះរបស់អ្នកចាត់ទុកជាប្លង់ទេរដែរឬទេ ?
4. ក្នុងការលើកដាក់វត្ថុធ្ងន់ៗឡើងលើរថយន្ត តើគេត្រូវជ្រើសរើសប្រវែងប្លង់ទេរដូចម្ដេច ទើបចំណេញកម្លាំងចលករបានច្រើន ?
5. រកផលមេកានិចនៃប្លង់ទេរខាងក្រោម ។




6. ដើម្បីដាក់ធុងសាំងទម្ងន់ 1380N ចេញពីរថយន្ត កម្មករម្នាក់ប្រើប្លង់ទេរដែលមានប្រវែងស្មើនិង 6ដងនៃកម្ពស់ ។ គណនាអាំងតង់ស៊ីតេកម្លាំងដែលកម្មករនោះត្រូវបញ្ចេញ ដើម្បីទប់ធុងសាំងមិនឱ្យរមៀលធ្លាក់ចុះមកដី(មិនគិតកម្លាំងកកិត) ។
7. ផ្លូវចំណោតមួយមានប្រវែង 20m និងមានកម្ពស់ 4m ។ គណនាកម្មន្តដែលគេត្រូវបំពេញដើម្បីទាញវត្ថុមួយទម្ងន់ 150N ឱ្យដល់កំពូលចំណោត ។ គណនាកម្លាំងដែលត្រូវផ្ដល់ដើម្បីបំពេញកម្មន្តនេះ(មិនគិតកម្លាំងកកិត) ។

# 3 កង់យោងនិងស្ពឺ

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពីការបញ្ជូនចលនាតាមខ្សែពាននិងស្ពឺ
- គណនាផលមេកានិចនៃកង់យោងនិងស្ពឺ ។

## 1. ការបញ្ជូនចលនាតាមខ្សែពាន

ក្នុងផ្នែកខ្លះនៃម៉ាស៊ីន យើងសង្កេតឃើញមានការបញ្ជូនចលនាពីកង់យោងទៅកង់មួយទៀតតាមរយៈខ្សែពាន ។



*ការបញ្ជូនចលនាតាមខ្សែពាន*

គេមានកង់យោងពីរ A និងB (ដូចរូប) ។ កង់យោង A មានកាំ $r = 10cm$ និង B មានកាំ $R = 20cm$ ។ នៅពេលគេបង្វិលកង់ A កង់ B ក៏វិលដែរ ។ គេនិយាយថា កង់ A ជា កង់ចលករ រីឯកង់ B ជាកង់ទប់ ។ ដូចនេះ គេបាន :

ម៉ូម៉ង់នៃកម្លាំងកង់ចលករគឺ $M_E = F_E \times r$

ម៉ូម៉ង់នៃកម្លាំងកង់ទប់គឺ $M_R = F_R \times R$

តាមគោលការណ៍រក្សាម៉ូម៉ង់ គេអាចសរសេរ : $M_E = M_R$ ឬ $F_E \times r = F_R \times R$

$F_E = F_R \times \frac{R}{r}$ តាមទំនាក់ទំនងនេះបង្ហាញថា កាលណាកាំនៃកង់ចលករកាន់តែធំ នោះកម្លាំងចលករដើម្បីបង្វិលកង់កាន់តែតូច(បើគេមិនគិតកកិតរវាងកង់និងខ្សែពាន) ។

បើគេធ្វើផលធៀបរវាងកម្លាំងនៃកង់ចលករ ($F_E$) និងកម្លាំងនៃកង់ទប់ ($F_R$) ឬផលធៀបរវាងកាំនៃកង់ទប់ (R) និងកាំនៃកង់ចលករ (r) គេបានទំហំមួយហៅថា ផលមេកានិច (MA) នៃកង់យោង ។ គេសរសេរ : $\boxed{MA = \frac{F_E}{F_R}}$ ឬ $\boxed{MA = \frac{R}{r}}$ ។

***ឧទាហរណ៍*** : ផលមេកានិចនៃកង់យោងខាងលើគឺ $MA = \frac{20}{10} = 2$ នេះមានន័យថា កម្លាំងដែល បញ្ចេញដោយកង់ចលករ A ធំជាងកម្លាំងនៃកង់ទប់ B ពីរដង ។

## 2. ការបញ្ជូនចលនាតាមស្ពី



ប្រសិនបើអ្នកសង្កេតមើលផ្នែកខាងក្នុងនៃនាឡិកាដៃ(មេកានិច) អ្នកនឹងឃើញកង់ដែលមានធ្មេញហៅថា ស្ពី។ ស្ពីធ្វើឱ្យទ្រនិច ម៉ោង នាទី វិនាទី ដើរដោយល្បឿនខុសៗគ្នា។

ស្ពីក៏មាននៅក្នុងទោចក្រយាន ទោចក្រយានយន្ត...ផងដែរ។ ចំពោះទោចក្រយាន(កង់)ថាសស្ពីបញ្ជូនចលនាទៅលីបស្ពីតាមច្រវាក់។

### 2.1. ស្ពីប្តូរទិសដៅចលនា




ស្ពី A និងស្ពី B មានអង្កត់ផ្ចិតនិងចំនួនធ្មេញ ស្មើគ្នា។ ប្រសិនបើ ស្ពី A វិលបានមួយជុំតាមទិសដៅ ទ្រនិចនាឡិកា នោះស្ពី B ក៏វិលបានមួយជុំដែរ ប៉ុន្តែតាមទិសដៅផ្ទុយ។

### 2.2. ស្ពីបង្កើនល្បឿនរង្វិល




ស្ពី A មានអង្កត់ផ្ចិតធំជាងស្ពី B ។ នៅពេលស្ពី A វិល ស្ពី B ក៏វិលដែរ ប៉ុន្តែស្ពី B វិលដោយល្បឿនលឿនជាងស្ពី A ។

### 2.3. ស្ពីបង្កើនកម្លាំង

ស្ពី A មានអង្កត់ផ្ចិតតូចជាងស្ពី B ។ នៅពេលស្ពី A វិល វាធ្វើឱ្យកម្លាំងដែលបញ្ចេញដោយស្ពី B ខ្លាំងជាងវា។

## 3. ផលមេកានិចនៃស្ពី

នៅពេលគេបង្វិល ស្ពី A ស្ពី B ក៏វិលដែរ គេនិយាយថា ស្ពី A ជាអ្នកបង្វិលស្ពី B ។ គេហៅស្ពី A ថាជាស្ពីចលករ និងស្ពី B ជាស្ពីទប់។

ប្រសិនបើ ស្ពី A មានធ្មេញ 10 ហើយ ស្ពី B មានធ្មេញ 20 ។ នៅពេល ស្ពី A វិលបាន 2 ជុំ ស្ពី B វិលបាន 1 ជុំ។ ដូចនេះស្ពី A វិលលឿនជាងស្ពី B ពីរដង ហើយកម្លាំងដែលបញ្ចេញដោយស្ពី B ក៏ធំជាងស្ពី A ពីរដង។

បើគេធ្វើផលធៀបរវាងចំនួនធ្មេញនៃស្ពឺទប់ ($N_R$) និងចំនួនធ្មេញនៃស្ពឺចលករ($N_E$) ឬផលធៀបរវាងកម្លាំងនៃស្ពឺទប់ និងកម្លាំងនៃស្ពឺចលករ គេបានទំហំមួយហៅថា ផលមេកានិច (MA) ស្ពឺ ។

គេសរសេរ : $MA = \frac{N_R}{N_E}$ ឬ $MA = \frac{F_R}{F_E}$

*ឧទាហរណ៍* : ផលមេកានិចនៃស្ពឺខាងលើគឺ $MA = \frac{20}{10} = 2$ នេះមានន័យថា កម្លាំងដែលបញ្ចេញដោយស្ពឺ B ធំជាងស្ពឺ A ពីរដង ។ ស្ពឺ A ជាអ្នកបង្វិលហៅថា ស្ពឺចលករ ហើយស្ពឺ B ជាអ្នកដែលត្រូវគេបង្វិលហៅថា ស្ពឺទប់ ។

ក្នុងការបញ្ជូនចលនាតាមស្ពឺ

- ស្ពឺមានកាំធំ(ចំនួនធ្មេញច្រើន)វិលយឺត តែវាបញ្ចេញកម្លាំងខ្លាំង ។
- ស្ពឺមានកាំតូច(ចំនួនធ្មេញតិច)វិលលឿន តែវាបញ្ចេញកម្លាំងខ្សោយ ។

## មេរៀនសង្ខេប

- ផលមេកានិចនៃកង់យោង $MA = \frac{F_E}{F_R}$ ឬ $MA = \frac{R}{r}$ ។
- ក្នុងការបញ្ជូនចលនាតាមស្ពឺ
  - ស្ពឺប្តូរទិសដៅចលនា
  - ស្ពឺបង្កើនល្បឿនរង្វិល
  - ស្ពឺបង្កើនកម្លាំង
- ផលមេកានិចនៃស្ពឺ $MA = \frac{N_R}{N_E}$ ឬ $MA = \frac{F_R}{F_E}$ ។

## ? សំណួរនិងលំហាត់

1. លីបកង់ខ្លះមានលីបវង់ដែលច្រវាក់អាចប្តូរកន្លែងឆ្លងពីមួយទៅមួយបាន ។ បើច្រវាក់ព័ទ្ធលើលីបធំ តើអ្នកធាក់ធូរឬតឹង ? បើច្រវាក់ព័ទ្ធលើលីបតូច តើកម្លាំងធាក់ទៅជាយ៉ាងណា ? បើតាមគោលការណ៍រក្សាម៉ូម៉ង់នៃកម្លាំង ក្នុងករណីប្រើលីបធំ តើអ្នកចំណេញអ្វី ? ខាតអ្វី ? ហើយក្នុងករណីប្រើលីបតូច តើអ្នកចំណេញអ្វី ? ខាតអ្វី ?
2. ចូរធ្វើការវិភាគរកកម្លាំងចលករនិងកម្លាំងទប់នៅលើរហាត់ទឹក ។ តើរហាត់ទឹកដែលមានកាំធំនាំឱ្យគេចំណេញអ្វី ? ឯរហាត់ដែលមានកាំតូចនាំឱ្យគេចំណេញអ្វី ? តើរហាត់ណាវិលលឿនជាង ?

3. ចាសឈ្នាន់កង់មួយមានធ្មេញ 14 និងលីបមានធ្មេញ 42 ។ បើគេធាក់ឈ្នាន់កង់បានបីជុំ តើលីបវិលបានប៉ុន្មានជុំ ?

4. ចាសឈ្នាន់កង់មួយមានធ្មេញ 51 និងលីបមានធ្មេញ 17 ។ គណនាផលមេកានិចនៃស្ពី ។

5. គេមានស្ពីបី A, B, C ដូចរូប ។




ក. ចូរគូសព្រួញបញ្ជាក់ពីទិសដៅរង្វិលនៃស្ពី B និង C កាលណាស្ពី A វិលតាមទិសដៅដូចរូប ។

ខ. គណនាចំនួនជុំក្នុងមួយវិនាទីនៃស្ពី B និង C បើស្ពី A វិលបាន 30 ជុំ ។

6. ជាងកាត់ដេរម្នាក់បញ្ចេញកម្លាំង 200N ដើម្បីបង្វិលកង់យោងឈ្នាន់នៃម៉ាស៊ីនដេរមួយដែលមានកាំ 30cm ។ ឯកង់យោងនៅត្រង់ក្បាលម៉ាស៊ីនមានកាំ 10cm ។ គណនា

ក. កម្លាំងទប់របស់ក្បាលម៉ាស៊ីនដេរ(បើគេមិនគិតកកិតរវាងកង់យោងនិងខ្សែពាន)

ខ. ផលមេកានិចនៃកង់យោងនោះ ។

គ. ម៉ូម៉ង់កម្លាំងនៃកង់ចលករនិងម៉ូម៉ង់កម្លាំងនៃកង់ទប់ ។

មេរៀនទី

# 4 រ៉កនិងត្រីយ

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាអំពីរ៉កនិងការប្រើប្រាស់រ៉កនឹង រ៉កចល័តនិងប្រព័ន្ធរ៉ក
- រៀបរាប់ពីគោលការណ៍របស់ត្រីយ
- គណនាផលមេកានិចនៃរ៉ក
- គណនាផលមេកានិចនៃត្រីយ
- អនុវត្តត្រីយក្នុងជីវភាពរស់នៅ ។

## 1. រ៉ក



រ៉ក

រ៉កជាកង់ម្យ៉ាងដែលធ្វើអំពីឈើឬដែកនិងមានចង្អូរព័ទ្ធជុំវិញ ។ ចង្អូរនេះសម្រាប់ដាក់ខ្សែឬខ្សែកាប ។ កង់នេះចល័តដោយសេរីជុំវិញអ័ក្សមួយដែលកាត់តាមផ្ចិតរបស់វា ។ គេដំឡើងអ័ក្សនេះឱ្យជាប់នឹងចំពាមមួយ ដើម្បីចៀសវាងកុំឱ្យកកិតរវាងកង់រ៉កនិងអ័ក្សរបស់វាខ្លាំងពេក គេធ្វើអ័ក្សនោះរអិលដោយដាក់ប្រេង ។ ក្នុងករណីខ្លះ គេបន្ថយកកិតដោយប្រើអ័ក្សមានកង់គ្រាប់ឃ្លី ។ រ៉កជាម៉ាស៊ីនងាយមួយជួយសម្រួលក្នុងការលើកដាក់វត្ថុធ្ងន់ៗ ។

### 1.1. រ៉កនឹង

#### ក. លក្ខណៈនៃរ៉កនឹង

ដើម្បីលើកបន្ទុកឡើងទៅលើ គេប្រើរ៉កនឹងមួយ ។ រ៉កនេះត្រូវបានគេចងភ្ជាប់ទៅនឹងចំណុចនឹងមួយដូចរូប ។ គេចងភ្ជាប់ចុងម្ខាងនៃខ្សែទៅនឹងកូនទម្ងន់ $F_R = 20N$ ហើយចុងម្ខាងទៀតគេចងភ្ជាប់វាទៅនឹងឌីណាម៉ូម៉ែត្រមួយ រួចគេទាញឌីណាម៉ូម៉ែត្រនោះដោយចលនាឃឹតស្មើ ។

គេសង្កេតឃើញ ឌីណាម៉ូម៉ែត្រចង្អុលអាំងតង់ស៊ីតេកម្លាំងទាញនៃបន្ទុកសឹងតែស្មើនឹង $F_E = 20N$ ដែរ ។

ដូចនេះក្នុងការប្រើរ៉កនឹង អាំងតង់ស៊ីតេកម្លាំងចលករ F ស្មើនឹងអាំងតង់ស៊ីតេនៃបន្ទុក គេសរសេរ : $F_E = F_R$ ។ គេនិយាយថា រ៉កនឹងប្តូរទិសដៅកម្លាំងដោយមិនប្រែប្រួលអាំងតង់ស៊ីតេនៃកម្លាំងនោះទេ ។




## ខ. គោលការណ៍រក្សាកម្មន្តនៃរ៉កនឹង

បើគេទាញខ្សែរ៉កបានប្រវែងAA' = d ទម្ងន់ $\vec{P}$ ក៏ផ្លាស់ទីបានប្រវែង d ដូចគ្នាដែរ ។ គេគណនាកម្មន្តទាំងពីរ គឺកម្មន្តចលករនិងកម្មន្តទប់ គេបាន :

កម្មន្តចលករនៃកម្លាំង F : $W_F = F_E \times d$

កម្មន្តទប់នៃកម្លាំង P : $W_R = F_R \times d$

ដោយ $F_E = F_R$ នាំឱ្យ $W_F = W_R$

គេសន្និដ្ឋានថា ចំពោះការប្រើរ៉កនឹងមួយដែលមានចលនាយឺតស្មើ ហើយគ្មានកកិត គេបានកម្មន្តចលករស្មើនឹងកម្មន្តទប់ ។

# 1.2. រ៉កចល័ត

## ក. លក្ខណៈនៃរ៉កចល័ត

គេក៏អាចប្រើរ៉កចល័តមួយ ដើម្បីផ្លាស់ទីទៅលើបានដែរ ។ គេចងចុងខ្សែម្ខាងនៃរ៉កនេះជាប់នៅនឹងមួយកន្លែង ហើយគេទាញចុងម្ខាងទៀតនៃខ្សែដែលយោងបន្ទុកមួយព្យួរនឹងរ៉កឡើងត្រង់ទៅលើយ៉ាងណាឱ្យកន្ទុយខ្សែទាំងពីរនៅសងខាងរ៉កស្របគ្នា ។




តាមពិសោធន៍បញ្ជាក់ថា បើគេលើកបន្ទុកមួយទម្ងន់ 10N ព្យួរនឹងរ៉ក គេសង្កេតឃើញឌីណាម៉ូម៉ែត្រចង្អុលកម្លាំងតែ 5N ប៉ុណ្ណោះ(ប្រសិនបើទម្ងន់ខ្សែនិងរ៉កមិនបាច់គិត) ។ ដូចនេះគេបញ្ចេញកម្លាំងចលករស្មើតែពាក់កណ្តាលនៃទម្ងន់បន្ទុកប៉ុណ្ណោះ ដើម្បីទប់បន្ទុកកុំឱ្យវាធ្លាក់ចុះទៅវិញ ។ ក្នុងការប្រើរ៉កចល័តមួយ បន្ទុកនិងរ៉កផ្លាស់ទីតាមទិសដៅកម្លាំងចលករហើយកម្លាំងចលករស្មើនឹងពាក់កណ្តាលនៃបន្ទុក $\left(F_E = \frac{F_R}{2}\right)$ ។

## ខ. គោលការណ៍រក្សាកម្មន្តនៃរ៉កចល័ត

ដើម្បីលើកបន្ទុក $F_R$ មួយត្រង់ឡើងលើឱ្យបានកម្ពស់ h គេត្រូវការកម្មន្ត ឬថាមពល $W_R = F_R \times h$ ។ ប៉ុន្តែបើគេលើកបន្ទុក $F_R$ ដដែលឱ្យបានកម្ពស់ h ដូចគ្នាដោយប្រើរ៉កចល័តវិញ គេត្រូវទាញខ្សែរ៉កត្រង់ឡើងលើឱ្យបានប្រវែង 2h ហើយគេត្រូវការកម្មន្ត ឬថាមពល $W_E = F_E \times 2h$ ។ តាមគោលការណ៍រក្សាកម្មន្ត ឬថាមពល គេបាន $W_R = W_E$ (កម្មន្តទប់ស្មើនឹងកម្មន្តចលករ)

$F_R \times h = F_E \times 2h$ ឬ $F_E = \frac{F_R}{2}$ ។ គេសន្និដ្ឋាន ក្នុងការប្រើរ៉កចល័តមួយ គេប្រើកម្លាំងចលករស្មើនឹងពាក់កណ្ដាលនៃកម្លាំងទប់ប៉ុណ្ណោះ ។

### 1.3. ប្រព័ន្ធរ៉ក

ក្នុងការលើកដាក់វត្ថុធ្ងន់ៗ គេច្រើនប្រើប្រព័ន្ធរ៉កដែលមានរ៉កនឹងពីរឬបីឬច្រើនជាងនេះនិងរ៉កចល័តមានចំនួនស្មើគ្នា ។ ប្រព័ន្ធរ៉កបែបនេះហៅថា បាឡង់ឬកៅឡាក់ ។ ប្រសិនបើគេប្រើបាឡង់ដែលមានរ៉កនឹងបីនិងរ៉កចល័តបី នោះកម្លាំងចលករដែលគេត្រូវបញ្ចេញ ដើម្បីលើកបន្ទុកគឺសឹងតែស្មើ $\frac{1}{6}$ នៃទម្ងន់បន្ទុកប៉ុណ្ណោះ ។ ប៉ុន្តែគេត្រូវទាញខ្សែប្រវែង6m ដើម្បីផ្លាស់ទីបន្ទុកបានកម្ពស់ 1m ។




*ប្រព័ន្ធរ៉ក*

## 2. ផលមេកានិចនៃរ៉ក




*ផលមេកានិចនៃរ៉កស្មើនឹងចំនួនខ្សែទ្របន្ទុក*

ផលមេកានិចនៃរ៉កក៏ដូចផលមេកានិចនៃឃ្នាស់ដែរគឺ $MA = \frac{F_R}{F_E}$ ។ យើងប្រើរូបមន្តនេះក្នុងករណីដែលកកិតនិងម៉ាសរ៉កមិនបាច់គិតឬអាចចោលបាន ។

# 3. ត្រីយ

## 3.1. ត្រីយងាយ



ត្រីយងាយ

ដើម្បីលើកបន្ទុកមួយឡើងលើបាន គេព្យួរបន្ទុកនោះនឹងចុងខ្សែម្ខាង ឯចុងខ្សែម្ខាងទៀត គេរុំវាទៅនឹងស៊ីឡាំងមួយមានអ័ក្សដេក ។ គេបង្វិលស៊ីឡាំងជុំវិញអ័ក្សនេះដោយដៃរវៃមួយ ។ ម៉ាស៊ីនងាយនេះហៅថា ត្រីយងាយ ។ ត្រីយងាយគឺជាឃ្នាស់ដែលវិលជុំវិញអ័ក្សមួយ ។

## 3.2. លក្ខខណ្ឌលំនឹងនៃត្រីយងាយ




គំនូសបំប្រួញត្រីយងាយ

ឧបមាកម្លាំងចលករ $F_E$ ដែលចាប់ត្រង់ A នៃដងដៃរវៃមានអាំងតង់ស៊ីតេថេរ ហើយទោះជាដងស្ថិតនៅស្ថានភាពណាក៏ដោយក៏កម្លាំង $F_E$ នៅតែប៉ះនឹងរង្វង់គូសដោយកាំ OA ជានិច្ច ។ ដូចនេះវាកាត់កែងនឹង អ័ក្សរង្វិលនៃត្រីយ ហើយដៃឃ្នាស់របស់វាមានប្រវែង OA = R ។ ម្យ៉ាងទៀតកម្លាំងទប់ $F_R$ នៃបន្ទុកជាកម្លាំងឈរ ដូចនេះវាកាត់កែងនឹងអ័ក្សរង្វិលនៃត្រីយដែរហើយដៃឃ្នាស់របស់វាមានប្រវែង OB = r ។

តាមគោលការណ៍ម៉ូម៉ង់ ដើម្បីឱ្យត្រីយមានលំនឹង លុះត្រាតែម៉ូម៉ង់នៃកម្លាំងចលករ $F_E$ ធៀបទៅនឹងអ័ក្សរង្វិលរបស់វាឱ្យវិលទៅតាមទិសដៅម្ខាងស្មើនឹងម៉ូម៉ង់នៃកម្លាំងទប់ $F_R$ ធៀបទៅនឹងអ័ក្សរង្វិលរបស់វាឱ្យវិលទៅតាមទិសដៅផ្ទុយ ។

គេសរសេរ : $F_E \times R = F_R \times r$ ឬ $\boxed{F_E = F_R \times \frac{r}{R}}$ ។

តាមរូបមន្តខាងលើនេះយើងឃើញថា ប្រសិនបើប្រវែង R នៃដៃឃ្នាស់ដងរវៃកាន់តែវែងនោះ កម្លាំងចលករដែលត្រូវលើកបន្ទុកកាន់តែតូច ។

*ឧទាហរណ៍ :* អង្កត់ផ្ចិតរបស់ស៊ីឡាំងនៃត្រីយមួយមានប្រវែង 20cm និងកាំនៃរង្វង់គូសដោយដៃរវៃមានប្រវែង 50cm ។ តើគេត្រូវបញ្ចេញកម្លាំងប៉ុន្មាន ដើម្បីលើកធុងទឹកមួយមានម៉ាស 12kg ? គេឱ្យ 1kg = 10N ។

ដោយ $F_R = 12kg \times 10m/s^2 = 120N$ , $r = \frac{D}{2} = \frac{20}{2}cm = 10 \cdot 10^{-2}m$ ,

$R = 50cm = 50 \cdot 10^{-2}m$

$F_E = 120N \times \frac{10 \cdot 10^{-2}m}{50 \cdot 10^{-2}m} = 24N$ ។

## 4. ផលមេកានិចនៃត្រឹយ

ផលមេកានិចនៃត្រឹយក៏ដូចផលមេកានិចនៃឃ្នាស់ដែរគឺ $MA = \frac{F_R}{F_E}$ ឬ $MA = \frac{R}{r}$ ។ យើងប្រើរូបមន្តនេះក្នុងករណីដែលទម្ងន់ដៃរវៃនិងកកិតមិនបាច់គិតឬអាចចោលបាន ។

## 5. អនុវត្តន៍ត្រឹយ




គេយកត្រឹយងាយទៅប្រើដើម្បីយោងទឹក លើកយកឥដ្ឋឬស៊ីម៉ង់ត៍ឡើងទៅជាន់ខ្ពស់ៗនៃសំណង់អគារ ។ ជួនកាលគេប្រើត្រឹយងាយ រ៉កចល័ត និងរ៉កនិងមួយចំនួនផ្សំបានជាម៉ាស៊ីនស្ទូចងាយសម្រាប់យោងជាងកំបោរទៅលាបជញ្ជាំងអគារខ្ពស់ៗ ។

គេអាចភ្ជាប់អ័ក្សរបស់ត្រឹយទៅនឹងភ្លៅម៉ូទ័រ ហើយកម្លាំងបង្វិលដែលបង្កើតដោយម៉ូទ័រនោះ ធ្វើឱ្យត្រឹយវិលបង្កើតជាម៉ាស៊ីនស្ទូចទំនើបមួយ ។

### មេរៀនសង្ខេប

- ក្នុងការប្រើរ៉កនិងមួយ អាំងតង់ស៊ីតេកម្លាំងចលករស្មើនឹងអាំងតង់ស៊ីតេកម្លាំងទប់ឬបន្ទុក $F_E = F_R$ ។ ដូចនេះផលមេកានិចនៃរ៉កគឺ $MA = 1$ ។
- ក្នុងការប្រើរ៉កចល័តមួយ អាំងតង់ស៊ីតេកម្លាំងចលករស្មើនឹងពាក់កណ្ដាលអាំងតង់ស៊ីតេនៃកម្លាំងទប់ឬបន្ទុក $F_E = \frac{F_R}{2}$ ។
- ផលមេកានិចនៃប្រព័ន្ធរ៉កស្មើនឹងចំនួនខ្សែដែលទ្របន្ទុក ។
- ត្រឹយងាយគឺ ជាឃ្នាស់វិលជុំវិញអ័ក្សមួយ ។
- ផលមេកានិចនៃត្រឹយ $MA = \frac{F_R}{F_E}$ ឬ $MA = \frac{R}{r}$ ដែល $F_E$ ជាកម្លាំងចលករដែលមានអំពើលើដៃរវៃឬដៃឃ្នាស់ $F_R$ ជាបន្ទុកឬកម្លាំងទប់ ហើយ $r$ កាំរបស់ស៊ីឡាំងនៃត្រឹយ និង $R$ កាំនៃរង្វង់គូសដោយដៃរវៃ ។

## ? សំណួរនិងលំហាត់

1. ដូចម្តេចហៅថា រ៉ក ? តើរ៉កនិងនិងរ៉កចល័តខុសគ្នាដូចម្តេច ?
2. ដូចម្តេចហៅថា ត្រីយ ?
3. តើផលមេកានិចនៃរ៉កនឹងមួយស្មើនឹងប៉ុន្មាន ? តើផលមេកានិចនៃរ៉កចល័តមួយស្មើនឹងប៉ុន្មាន ?
4. តើផលមេកានិចនៃប្រព័ន្ធរ៉កមួយដែលមានរ៉កនិងពីរ និង រ៉កចល័តមួយស្មើនឹងប៉ុន្មាន ?
5. គេប្រើរ៉កនិងមួយ ដើម្បីលើកវត្ថុមួយមានម៉ាស 85kg ។ តើគេអាចលើកវត្ថុបានដែរឬទេ បើគេបញ្ចេញកម្លាំងចលករតែ 750N ប៉ុណ្ណោះ ?
6. គេព្យួរវត្ថុមួយមានម៉ាស 59kg ទៅនឹងរ៉កចល័តមួយ ។ គណនាអាំងតង់ស៊ីតេកម្លាំងដែលមានអំពើទៅលើតំពក់និងអាំងតង់ស៊ីតេកម្លាំងដែលកម្មករទាញវត្ថុនោះទៅលើ ។
7. តើគេត្រូវតំរៀបរ៉កមួយចំនួនដូចម្តេច ដើម្បីលើកវត្ថុមួយដែលមានម៉ាស 160kg ដោយកម្លាំងដែលមានអាំងតង់ស៊ីតេ 200N ។ គេមិនគិតកម្លាំងកកិតនិងទម្ងន់រ៉កទេ ។
8. ខ្សែមួយអាចទ្រតំណឹងបានតែ 2000N ។ តើគេអាចប្រើរ៉កមួយនិងខ្សែនោះ ដើម្បីលើកវត្ថុមួយដែលមានម៉ាស 1000kg បានដែរឬទេ ? ប្រសិនបើបាន តើគេត្រូវប្រើរ៉កនោះដូចម្តេច ?
9. អង្កត់ផ្ចិតនៃកង់រហាត់ទឹកមួយមានប្រវែង 10cm និងកាំនៃរង្វង់គូសដោយដៃរវៃមានប្រវែង 2m ។ គណនាផលមេកានិចនៃកង់រហាត់ទឹកនោះ ។
10. អង្កត់ផ្ចិតនៃស៊ីឡាំងរបស់ត្រីយមួយមានប្រវែង 30cm និងកាំនៃរង្វង់គូសដោយដៃរវៃមានប្រវែង 60cm ។ តើគេត្រូវបញ្ចេញកម្លាំងប៉ុន្មាន ដើម្បីលើកធុងទឹកមួយទម្ងន់ 120N ?
11. គេចង់ធ្វើត្រីយមួយដែលអង្កត់ផ្ចិតនៃស៊ីឡាំងរបស់ត្រីយមានប្រវែង 20cm ដើម្បីលើកទម្ងន់មួយ 150N ដោយកម្លាំង 100N ។ តើគេត្រូវធ្វើដៃរវៃឬដៃឃ្នាស់នោះមានប្រវែងប៉ុន្មាន ?
12. គេព្យួរបន្ទុកមួយមានទម្ងន់ 200N នៅលើអង្កត់ផ្ចិតនៃស៊ីឡាំងរបស់ត្រីយមួយមានប្រវែង 14cm និងកាំនៃរង្វង់គូសដោយដៃរវៃមានប្រវែង 70cm ។ គណនា
    ក. ម៉ូម៉ង់នៃកម្លាំងដែលមានអំពើលើស៊ីឡាំង ។
    ខ. កម្លាំងទប់នៅលើដៃរវៃ ដើម្បីឱ្យត្រីយមានលំនឹង ។

មេរៀនទី

# 5 ទិន្នផលម៉ាស៊ីនងាយ

ចប់មេរៀននេះ សិស្សអាច

- ពន្យល់ពីគោលការណ៍ប្រើប្រាស់ម៉ាស៊ីនងាយ
- គណនាទិន្នផលនៃម៉ាស៊ីនងាយ ។

## 1. គោលការណ៍រក្សាកម្មន្ត

យើងបានសិក្សារួចមកហើយថា នៅពេលដែលយើងប្រើ ឬង់ទេរ រ៉ក ឃ្នាស់ ស្ពី ឬត្រីយ វាគ្រាន់តែដើម្បីចំណេញកម្លាំងឬបំលាស់ទីតែប៉ុណ្ណោះ ។ តាមគោលការណ៍រក្សាកម្មន្តសំដែងថា គ្មានម៉ាស៊ីនងាយណាមួយដែលធ្វើឱ្យចំណេញកម្មន្តទេ ទោះបីជាក្នុងលក្ខខណ្ឌណាក៏ដោយ វាបានត្រឹមតែបញ្ជូនកម្មន្តដែលគេផ្តល់ឱ្យវាប៉ុណ្ណោះ ។

ក្នុងការប្រើម៉ាស៊ីនងាយ កាលណាគេខាតបំលាស់ទី គេចំណេញកម្លាំង ហើយច្រាសមកវិញ បើគេខាតកម្លាំង គេចំណេញបំលាស់ទី ។

## 2. ទិន្នផលម៉ាស៊ីនងាយ

តាមគោលការណ៍រក្សាកម្មន្តនៃម៉ាស៊ីនងាយ កម្មន្តចលករស្មើនិងកម្មន្តទប់ $W_E = W_R$ ។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង កម្មន្តចលករ $W_E$ ដែលបំពេញដោយម៉ាស៊ីនងាយមួយតែងតែធំជាងកម្មន្តទប់ $W_R$ ជានិច្ចដើម្បីធ្វើឱ្យម៉ាស៊ីនងាយនោះមានចលនា ពីព្រោះកម្មន្តមួយផ្នែកត្រូវបានចំណាយ ដើម្បីធ្វើឱ្យម៉ាស៊ីនមានចលនា (កម្មន្តចលករ)និងកម្មន្តមួយផ្នែកផ្សេងទៀតត្រូវចំណាយលើកកិត(កម្មន្តមិនបានការ) ។ ដូចនេះកម្មន្តឬថាមពលសរុប= កម្មន្តឬថាមពលចលករ + កម្មន្តឬថាមពលមិនបានការ ។

ក្នុងការលើកដាក់បន្ទុកមួយទៅលើដោយប្រើរ៉កចល័ត គេត្រូវធ្វើកម្មន្តបន្ថែមលើកម្មន្តបានការដើម្បីលើករ៉កផង លើកខ្សែផង និងដើម្បីឈ្នះកម្លាំងកកិតផ្សេងៗក្នុងរ៉កផង ។ ដូចនេះទោះបី គេខិតខំបំបាត់កកិតយ៉ាងណាក៏ដោយក៏កម្មន្តចលករឬ កម្មន្តបានការ $W_E$ ដែលវាអាចធ្វើគ្រាន់តែជាផ្នែកមួយនៃកម្មន្តសរុបប៉ុណ្ណោះ ។

បើគេធ្វើផលធៀបរវាងកម្មន្តបានការ $W_E$ និងកម្មន្តសរុប $W_T$ ឬអានុភាព $P_E$ បានការនិងអានុភាពសរុប $P_T$ គេបានទំហំមួយហៅថាទិន្នផល (Rd) នៃម៉ាស៊ីនងាយ គិតជាភាគរយ ។

គេសរសេរ :

$$\boxed{Rd = \frac{W_E}{W_T}} \text{ ឬ } Rd(\%) = \frac{W_E}{W_T} \times 100 \text{ ដោយ } (W_E < W_T) \text{ និង } (P_E < P_T)$$

ដូចនេះទិន្នផល $Rd < 1$ មានន័យថាទិន្នផលម៉ាស៊ីនងាយតូចជាង 100 % ជានិច្ច ។

*ឧទាហរណ៍ :* គេចង់លើកអង្គធាតុមួយទម្ងន់ 40N ត្រង់ទៅលើឱ្យបានកម្ពស់ 10m ដោយប្រើរ៉កនិងមួយ ។ ដូចនេះគេត្រូវចងចុងខ្សែម្ខាងទៅនឹងវត្ថុនោះ ហើយគេរុំចុងខ្សែម្ខាងទៀតទៅនឹងអ័ក្សម៉ូទ័រមួយ ។ គេដឹងថា ដើម្បីលើកវត្ថុនោះឱ្យបានកម្ពស់ 10m ម៉ូទ័រត្រូវបញ្ចេញកម្មន្តសរុប 500J ។ គណនាទិន្នផលនៃរ៉ក ។




កម្មន្តបានការដែលត្រូវលើកបន្ទុកគឺ

$W_E = P \times h = 40N \times 10m = 400J$

កម្មន្តសរុបស្មើនឹងកម្មន្តបំពេញដោយម៉ូទ័រ

$W_T = 500J$

ដូចនេះទិន្នផលនៃរ៉កគឺ

$Rd = \frac{W_E}{W_T} = \frac{400J}{500J} = 0.80$ ឬ 80 % ។

## មេរៀនសង្ខេប

- ទិន្នផល (Rd) នៃម៉ាស៊ីនងាយ :

  $\boxed{Rd = \frac{W_E}{W_T}}$ ឬ $\boxed{Rd = \frac{P_E}{P_T}}$ ដោយ $(W_E < W_T)$ និង $(P_E < P_T)$

  ទិន្នផល (Rd) នៃម៉ាស៊ីនងាយគិតជាភាគរយ ។

- កម្មន្តបានការឬអានុភាពបានការតូចជាងកម្មន្តសរុបឬអានុភាពសរុបជានិច្ច ។

## សំណួរនិងលំហាត់

1. ដូចម្តេចហៅថា ទិន្នផលនៃម៉ាស៊ីនងាយ?
2. ហេតុអ្វីបានជា ទិន្នផលនៃម៉ាស៊ីនងាយតូចជាង100 % ?
3. ម៉ូទ័រអគ្គិសនីមួយលើកបន្ទុកទម្ងន់ 5N ត្រង់ទៅលើបានកម្ពស់ 3m ។ គេដឹងថា ម៉ូទ័រត្រូវបញ្ចេញកម្មន្តសរុប 27J ។ គណនាកម្មន្តមិនបានការនិងទិន្នផលនៃម៉ូទ័រ ។

## ? សំណួរបញ្ចប់ជំពូកទី២

**I.** ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវមានតែមួយគត់

1 បណ្ដារូបមន្តខាងក្រោម តើមួយណាដែលបង្ហាញពីផលមេកានិចនៃស្ដី

☐ក $MA = \frac{d_E}{d_R}$ ☐ខ $MA = \frac{L}{h}$ ☐គ $MA = \frac{N_R}{N_E}$ ☐ឃ $MA = \frac{D_R}{D_E}$

2. តាមរូបភាពខាងក្រោមតើរូបមួយណាជាឃ្នាស់ទំនប់កណ្ដាល ?




**II.** ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. ឃ្នាស់ដែលមានចំណុចទម្រស្ថិតនៅចន្លោះកម្លាំងចលករនិងកម្លាំងទប់ហៅថា .......... ។
2. ផ្ទៃរាបមួយដែលភ្ជាប់ពីទីកន្លែងខ្ពស់ទៅទីកន្លែងទាបហៅថា ............ ។
3. ផលមេកានិចនៃប្រព័ន្ធរ៉កស្មើនឹង .......... ។
4. ឃ្នាស់ដែលចល័តជុំវិញអ័ក្សនឹងមួយហៅថា ........ ។
5. កម្មន្តឬថាមពលសរុប = .......... + .............. ។

**III.** លំហាត់

1. កម្មករម្នាក់រុញរទេះកង់មួយដែលផ្ទុកអីវ៉ាន់ ទម្ងន់ 500N ។ ដៃទាំងពីររបស់គាត់ចាប់ត្រង់ចំណុច A ស្ថិតនៅ 1.45m ពីអ័ក្ស 0 នៃកង់វិល ។ គេសន្មតថាបន្ទុកទាំងអស់ផ្ដុំនៅចំណុច B ស្ថិតលើដៃរទេះដែលមានចម្ងាយស្មើនឹង 0.55m ពីអ័ក្សរង្វិលនៃកង់ ។ គណនាអាំងតង់ស៊ីតេកម្លាំងដែលកម្មករលើករទេះរុញត្រង់ចំណុច A ។



គំនូសបំព្រួញ

2. ជាងជួសជុលរថយន្តម្នាក់ប្រើរ៉កមួយដើម្បីលើកម៉ាស៊ីនមួយចេញពីរថយន្ត ។ ម៉ាស៊ីននោះមានទម្ងន់ 500N ហើយត្រូវលើកក្នុងរយៈកម្ពស់ 2m ។ ជាងនោះបានប្រើកម្លាំង 200N ដើម្បីទាញខ្សែរ៉កចុះក្រោមក្នុងចម្ងាយ 10m នៅពេលលើកវា ។ គណនា

ក. កម្មន្តក្នុងការលើកម៉ាស៊ីន

ខ. កម្មន្តដែលបំពេញដោយជាង

គ. ទិន្នផលនៃរ៉ក

# ជំពូកទី 3 អគ្គិសនី



ថាមពលអគ្គិសនីត្រូវបានប្រើយ៉ាងទូលំទូលាយក្នុងសកម្មភាពជាច្រើនដូចជា សម្រាប់បំភ្លឺ គេហដ្ឋាន ទីសាធារណៈ ដុតកម្ដៅ ឬប្រើនៅក្នុងទូរស័ព្ទ វិទ្យុ ទូរទស្សន៍ កង្ហារ កុំព្យូទ័រ ម៉ាស៊ីនត្រជាក់... ។ល។

ថាមពលអគ្គិសនីផ្ដល់សារប្រយោជន៍ដល់យើងខ្លាំងណាស់ ប៉ុន្តែវាក៏ផ្ដល់គ្រោះថ្នាក់ដល់យើងខ្លាំងណាស់ដែរ ប្រសិនបើយើងប្រើប្រាស់វាដោយខ្វះការប្រុងប្រយ័ត្ន ។

ក្នុងជំពូកនេះ យើងនឹងសិក្សាពីរបៀបគណនាថាមពលអគ្គិសនី ទំនាក់ទំនងថាមពលអគ្គិសនី និងថាមពលកម្ដៅ របៀបប្រើប្រាស់អគ្គិសនីក្នុងគេហដ្ឋាន និងវិធានការបង្ការគ្រោះថ្នាក់ដោយចរន្តអគ្គិសនី ។

មេរៀនទី

# 1 ថាមពលអគ្គិសនី

**ចប់មេរៀននេះ សិស្សអាច**

- បកស្រាយអានុភាពនៃគ្រឿងទទួលអគ្គិសនី
- គណនាបរិមាណកម្ដៅដែលភាយចេញពីខ្សែចម្លងអគ្គិសនីតាមរូបមន្ត $E = RI^2t$
- បង្ហាញពីទំនាក់ទំនងរវាងថាមពលអគ្គិសនីនិងថាមពលកម្ដៅតាមរូបមន្ត $RI^2t = mc\Delta t$
- គណនាតម្លៃប្រើប្រាស់ថាមពលអគ្គិសនី ។

## 1. ថាមពលនិងអានុភាពអគ្គិសនី

### 1.1. ថាមពលអគ្គិសនី

យើងបានសិក្សារួចមកហើយថា អានុភាពនៃគ្រឿងអគ្គិសនីមួយជាថាមពលអគ្គិសនីដែលគ្រឿងអគ្គិសនីនោះទទួលឬស៊ីក្នុងរយៈពេលមួយវិនាទី ដើម្បីបំលែងថាមពលអគ្គិសនីនោះទៅជាថាមពលផ្សេងទៀត ។

បើយើងស្គាល់អានុភាពនៃគ្រឿងអគ្គិសនី យើងអាចគណនាថាមពលអគ្គិសនីដែលគ្រឿងទទួលអគ្គិសនីនោះស៊ីក្នុងរយៈពេល $t$ តាមរូបមន្ត : $\boxed{E = P \times t}$

$E$ ជាថាមពលអគ្គិសនីគិតជាស៊ូល (J) $P$ អានុភាពអគ្គិសនីនៃគ្រឿងទទួលគិតជាវ៉ាត់ W និង $t$ ជារយៈពេលគិតជាវិនាទី (s) ។



*អំពូលចង្កៀង (100W-120V)*

មួយស៊ូល(1J) គឺជាថាមពលអគ្គិសនីដែលគ្រឿងអគ្គិសនីមានអានុភាពមួយវ៉ាត់ 1W ទទួលឬស៊ីក្នុងរយៈពេលមួយវិនាទី (1s) : $1J = 1W \times 1s$ ។

ដើម្បីវាស់ថាមពលអគ្គិសនីស៊ីដោយគ្រឿងទទួល គេប្រើកុងទ័រអគ្គិសនី ។ កុងទ័រអគ្គិសនីជាឧបករណ៍កត់ត្រាថាមពលអគ្គិសនីគិតជា គីឡូវ៉ាត់ម៉ោង(kWh) ។ មួយគីឡូវ៉ាត់ម៉ោង(1kWh) ជាថាមពលអគ្គិសនីដែលគ្រឿងអគ្គិសនីមានអានុភាព1 000W ឬ 1kW ទទួលឬស៊ីក្នុងរយៈពេលមួយម៉ោង(1h) :

$1kWh = 1kW \times h = 1000W \times 3600s = 3\ 600\ 000J = 36 \times 10^5 J$ ។

## 1.2. អានុភាពនៃគ្រឿងទទួលអគ្គិសនី

យើងដឹងអានុភាព P នៃគ្រឿងទទួលអគ្គិសនីមួយ កាលណាយើងវាស់អាំងតង់ស៊ីតេចរន្ត I ឆ្លងកាត់និងតង់ស្យុងឬផលសងប៉ូតង់ស្យែល V រវាងគោលទាំងពីរនៃគ្រឿងទទួលអគ្គិសនីនោះ ។

គេសរសេរ : $P = IV$

P អានុភាពអគ្គិសនីនៃគ្រឿងទទួលគិតជាវ៉ាត់ W , I អាំងតង់ស៊ីតេចរន្តគិតជាអំពែ (A) V តង់ស្យុងឬផលសងប៉ូតង់ស្យែលគិតជាវ៉ុល (V) ។

*ឧទាហរណ៍ទី 1:* គណនាអានុភាពនៃអំពូលចង្កៀងរថយន្តមួយ ។ បើគេដឹងថាអាំងតង់ស៊ីតេឆ្លងកាត់អំពូល 3A កាលណាគេភ្ជាប់វានិងអាគុយមួយដែលមានតង់ស្យុងឬផលសងប៉ូតង់ស្យែល12V ។




តាមរូបមន្ត : $P = VI$

ដោយ $I = 3A$ និង $V = 12V$

$P = 3A \times 12V = 36W$

$P = 36W$

ដូចនេះអំពូលចង្កៀងរថយន្តមានកំណត់ចង្អុល 36W ។

*ឧទាហរណ៍ទី 2 :* គណនាអាំងតង់ស៊ីតេចរន្តឆ្លងកាត់អំពូលពីរដែលមានកំណត់ចង្អុលរៀងគ្នា 60W – 220V និង 40W – 220V ។

កំណត់ចង្អុល 60W – 220V បង្ហាញឱ្យឃើញថា អំពូលនេះប្រើក្រោមតង់ស្យុង 220V ស៊ីអានុភាព 60W ។

តាមរូបមន្ត : $P = VI$ នាំឱ្យ $I = \frac{P}{V}$

$I = \frac{60}{220} = 0.27A$ និង $I = \frac{40}{220} = 0.18A$ ។

## 1.3. ការគណនាថាមពលអគ្គិសនីស៊ីដោយគ្រឿងទទួល

*ឧទាហរណ៍ :* អំពូលអគ្គិសនីមួយមានអានុភាព 100W ។ គណនាថាមពលអគ្គិសនីដែលអំពូលនោះស៊ីក្នុងរយៈពេលមួយនាទី ។

គណនាថាមពលអគ្គិសនីដែលអំពូលនោះស៊ីក្នុងរយៈពេលមួយនាទី

តាមរូបមន្ត : $E = P \times t$ ដោយ $P = 100W$ និង $t = 1mn = 60s$

$$E = 100W \times 60s = 6\ 000J$$

អំពូលអគ្គិសនីដែលមានអានុភាព 100W មានន័យថា នៅពេលមានចរន្តឆ្លងកាត់រយៈពេល 1s វាបំលែងថាមពលអគ្គិសនី 100J ឱ្យទៅជាថាមពលពន្លឺនិងកម្ដៅ ។ ដូចនេះ រយៈពេល 60s អំពូលស៊ីថាមពលអគ្គិសនីអស់ 6 000J ។

## 1.4. ការគណនាតម្លៃថាមពលអគ្គិសនី

*ឧទាហរណ៍:* អំពូលអគ្គិសនីមួយមានអានុភាព 20W ។ ជារៀងរាល់ថ្ងៃ គេបំភ្លឺវារយៈពេល 4ម៉ោងក្នុងមួយថ្ងៃ ។ គណនាតម្លៃប្រើប្រាស់ថាមពលអគ្គិសនីក្នុងរយៈពេលមួយខែ(30ថ្ងៃ) បើគេដឹងថា តម្លៃថាមពលអគ្គិសនីក្នុង 1kWh គឺ 720រៀល ។

អានុភាពអំពូលគិតជាគីឡូវ៉ាត់: $P = 20W = 20 \times 10^{-3}kW = 2 \times 10^{-2}kW$

រយៈពេលបំភ្លឺក្នុងមួយខែ : $t = 4h \times 30 = 120h$

អំពូលស៊ីថាមពលអគ្គិសនីក្នុងមួយខែ :$E = 2 \times 10^{-2}kW \times 120h = 2.4kWh$

តម្លៃប្រើប្រាស់ថាមពលអគ្គិសនី : 2.4kWh × 720រៀល/kwh = 1728 រៀល ។

## 1.5. ទំនាក់ទំនងរវាងថាមពលអគ្គិសនីនិងថាមពលកម្តៅ

កម្តៅដែលភាយចេញពីអង្គធាតុចម្លងពេលមានចរន្តឆ្លងកាត់ ជាថាមពលមួយបែបហៅថា ថាមពលកម្តៅ ។ ចំណែកឯចរន្តអគ្គិសនីដែលជាបុព្វហេតុបង្កើតកម្តៅក្នុងអង្គធាតុចម្លងនេះក៏មានថាមពលមួយបែបដែរហៅថាថាមពលអគ្គិសនី ។ ដូចនេះ ថាមពលអគ្គិសនីអាចក្លាយជាថាមពលកម្តៅ ។




*ពិសោធន៍ស៊ូល-ឡឹន*

ក្នុងករណីថាមពលអគ្គិសនីបំលែងទៅជាថាមពលកម្តៅទាំងស្រុង ក្នុងពិសោធន៍នេះគេបានថាមពលអគ្គិសនី :

$E = P \times t$ ឬ $E = RI^2t$ ព្រោះ $P = RI^2$

E ជាថាមពលអគ្គិសនីគិតជាស៊ូល(J) , R ជារេស៊ីស្តង់នៃគ្រឿងកម្តៅគិតជាអូម (Ω) , I អាំងតង់ស៊ីតេចរន្តគិតជាអំពែ (A) និង t រយៈពេលគិតជាវិនាទី (s) ។

ថាមពលកម្តៅឬបរិមាណកម្តៅ : $Q = mc\Delta t$

Q បរិមាណកម្តៅគិតជាស៊ូល (J) , m ជាម៉ាសនៃអង្គធាតុគិតជាគីឡូក្រាម (kg) , c ជាកម្តៅម៉ាសនៃអង្គធាតុគិតជាស៊ូលក្នុងមួយគីឡូក្រាមអង្សាសេលស៊ុស J/kg °C និង $\Delta t = t_2 - t_1$ កំណើនឬតំហាយសីតុណ្ហភាពគិតជាអង្សាសេលស៊ុស (°C) ។

តាមច្បាប់រក្សានិងបំលែងថាមពល គេបាន : $E = Q$ ឬ $RI^2t = mc\Delta t$ ។

***ឧទាហរណ៍ទី 1*** : កំសៀវទឹកអគ្គិសនីមួយមានអានុភាព 2.3kW ។ គេប្រើកំសៀវទឹកនេះ ដាំទឹកចំណុះ 3 លីត្រ នៅសីតុណ្ហភាព 25°C ទៅពុះនៅ 100°C ។ គណនា :

ក. រេស៊ីស្តង់របស់កំសៀវ ។ បើគេដឹងថា អាំងតង់ស៊ីតេចរន្តឆ្លងកាត់កំសៀវស្មើនឹង 2A ។

ខ. រយៈពេលដាំទឹក ។

គ. ប្រាក់ចំណាយដើម្បីដាំទឹកនេះ បើគេដឹងថា ថាមពលអគ្គិសនីថ្លៃ 720 រៀលក្នុង 1kWh ។

គេឱ្យកម្តៅម៉ាសទឹក $c = 4200J/kg\cdot°C$ និង ទឹកចំណុះ 3 លីត្រស្មើនឹង 3 គីឡូក្រាម ។

## ✍ ដំណោះស្រាយ

ក. រេស៊ីស្តង់របស់កំសៀវ



កំសៀវអគ្គិសនី

តាមរូបមន្ត : $P = RI^2$ នាំឱ្យ $R = \frac{P}{I^2}$

អាំងតង់ស៊ីតេចរន្តឆ្លងកាត់កំសៀវ $I = 2A$

អានុភាពកំសៀវ $P = 2.3kW = 2.3\times10^3W$

$$R = \frac{2.3\times10^3W}{(2A)^2} = \frac{2300W}{4A^2} = 575\frac{W}{A^2} = 575\Omega$$

រេស៊ីស្តង់របស់កំសៀវ : $R = 575\Omega$ ។

ខ. រយៈពេលដាំទឹក

បរិមាណកម្តៅដើម្បីដំឡើងសីតុណ្ហភាពទឹកពី 25°C ទៅ 100°C

$Q = mc(t_2 - t_1)$

ម៉ាសទឹក $m = 3kg$ កម្តៅម៉ាសទឹក $c = 4200J/kg\cdot°C$

កំណើនសីតុណ្ហភាព $\Delta t = t_2 - t_1 = 100 - 25 = 75°C$

$Q = 3kg\times4200J/kg\cdot°C\times75°C = 945\ 000J$

ដោយថាមពលអគ្គិសនីបំលែងទៅជាថាមពលកម្តៅទាំងស្រុង យើងបាន : $E = Q$

$P\times t = mc\Delta t$ នាំឱ្យ $t = \frac{mc\Delta t}{P}$ ដោយ $P = 2.3kw = 2300W$ ,

$Q = mc\Delta t = 945\ 000J$ $\quad t = \frac{945\ 000}{2300} = 410s = 6mn50s$

រយៈពេលដាំទឹក $t = 410s = 6mn50s$

គ. ប្រាក់ចំណាយដើម្បីដាំទឹក

អានុភាពកំសៀវ $P = 2.3kW$

រយៈពេលដាំទឹក $t = 410s = \frac{410}{3600} = \frac{41}{360}h$

$2.3kW\times\frac{41}{360}h\times$ 720 រៀល/kWh $= 1886$ រៀល ។

*ឧទាហរណ៍ទី 2:* ឆ្នាំងអ៊ុតអគ្គិសនីមួយមានរេស៊ីស្តង់ $60\Omega$ ។ បើចរន្តឆ្លងកាត់វាមានអាំងតង់ស៊ីតេ 4A ។ ចូរគណនា :

ក. តង់ស្យុងអគ្គិសនីដែលផ្តល់ឱ្យឆ្នាំងអ៊ុត

ខ. អានុភាពអគ្គិសនីដែលផ្តល់ឱ្យឆ្នាំងអ៊ុត

គ. ថាមពលកម្តៅដែលភាយចេញពីឆ្នាំងអ៊ុតក្នុងរយៈពេល 5 នាទី ។

## ✍ ដំណោះស្រាយ

**ក. តង់ស្យុងអគ្គិសនីដែលផ្តល់ឱ្យឆ្នាំងអ៊ុត**

តាមច្បាប់អូម $V = RI$ ដោយ $R = 60\Omega$ , $I = 4A$

ដូចនេះ $V = 60\Omega \times 4A = 240V$

**ខ. អានុភាពអគ្គិសនី P**

តាមរូបមន្ត $P = RI^2$ ដោយ $R = 60\Omega$ , $I = 4A$

ដូចនេះ $P = 60\Omega \times (4A)^2 = 960W$

**គ. ថាមពលកម្តៅដែលបំភាយក្នុងរយៈពេល 5នាទី**

តាមរូបមន្ត $E = RI^2t$ ដោយ $R = 60\Omega$ , $I = 4A$ , $t = 5mn = 5 \times 60s = 300s$

ដូចនេះ $E = 60\Omega \times (4A)^2 \times 300s = 288000J$ ។

### មេរៀនសង្ខេប

- ថាមពលអគ្គិសនី : $E = P \times t$ ឬ $E = RI^2t$ ព្រោះ $P = RI^2$

  E ជាថាមពលអគ្គិសនីគិតជាស៊ូល(J) , R ជារេស៊ីស្តង់នៃគ្រឿងកម្តៅគិតជាអូម ($\Omega$) , I អាំងតង់ស៊ីតេចរន្តគិតជាអំពែ (A) និងt រយៈពេលគិតជាវិនាទី (s) ។

- ថាមពលកម្តៅឬបរិមាណកម្តៅ : $Q = mc\Delta t$

  Q បរិមាណកម្តៅគិតជាស៊ូល (J) , m ជាម៉ាសនៃអង្គធាតុគិតជាគីឡូក្រាម (kg) , c កម្តៅម៉ាសនៃអង្គធាតុគិតជាស៊ូលក្នុងមួយគីឡូក្រាមអង្សាសែលស៊ុស J/kg °C និង $\Delta t = t_2 - t_1$ កំណើន ឬតំហយសីតុណ្ហភាពគិតជាអង្សាសែលស៊ុស (°C) ។

- តាមច្បាប់រក្សានិងបំលែងថាមពល គេបាន : $E = Q$ ឬ $RI^2t = mc\Delta t$ (ក្នុងករណី ថាមពលអគ្គិសនីបំលែងទៅជាថាមពលកម្តៅទាំងស្រុង) ។

## ? សំណួរនិងលំហាត់

1. តើថាមពលអគ្គិសនីអាស្រ័យនិងកត្តាអ្វីខ្លះ ?
2. ចូរឱ្យឧទាហរណ៍នៃឧបករណ៍អគ្គិសនីពីរដែលប្រើក្នុងគេហដ្ឋាន ដែលបំលែងថាមពលអគ្គិសនីទៅជាថាមពលកម្ដៅ ។
3. គណនាបរិមាណកម្ដៅដែលភាយចេញក្នុងរយៈពេល 10នាទីពីខ្សែចម្លងមួយដែលមានរេស៊ីស្តង់ 2.09Ω កាលណាអាំងតង់ស៊ីតេចរន្ត 2.5A ឆ្លងកាត់វា ។
4. រេស៊ីស្តង់ធ្នារមួយនៃខ្សែចម្លងដែលត្រាំក្នុងទឹក 0.400kg ឆ្លងកាត់ដោយចរន្ត 3A ។ ក្នុងរយៈពេល 250វិនាទីសីតុណ្ហភាពកើនបាន 5.6°C ។ គណនារេស៊ីស្តង់នៃខ្សែចម្លងអគ្គិសនីនោះ ។ គេឱ្យកម្ដៅម៉ាសទឹក $C = 4200 J/kg°c$ ។
5. ចូរបំពេញតម្លៃក្នុងតារាងខាងក្រោម

| ឧបករណ៍អគ្គិសនី | អំពូល | ទូរទស្សន៍ | បំពង់ផ្លុំសក់ | ម៉ាស៊ីនត្រជាក់ |
|---|---|---|---|---|
| អានុភាព | .................. | 120W | 500W | .................. |
| តង់ស្យុង | 220V | .................. | 220V | 220V |
| អាំងតង់ស៊ីតេចរន្ត | 0.25A | 0.50A | .................. | 8A |

6. ខ្សែចម្លងអគ្គិសនីមួយមានរេស៊ីស្តង់ 10Ω ឆ្លងកាត់ដោយចរន្តអគ្គិសនី 5A ក្នុងរយៈពេល 180វិនាទី ។ គណនា :
   ក. អានុភាពដែលចរន្តផ្ដល់ឱ្យខ្សែចម្លង ។
   ខ. បរិមាណបន្ទុកអគ្គិសនីដែលឆ្លងកាត់ខ្សែចម្លងនេះ ។
   គ. ផលកម្ដៅដែលភាយចេញពីខ្សែចម្លង ។
7. ឆ្នាំងអ៊ុតអគ្គិសនីមួយមានរេស៊ីស្តង់ $R = 24\Omega$ ហើយមានអានុភាព 1000W ។ គណនា
   ក. អាំងតង់ស៊ីតេចរន្តដែលឆ្លងកាត់ឆ្នាំងអ៊ុតនោះ ។
   ខ. ថាមពលអគ្គិសនីដែលឆ្នាំងអ៊ុតនោះស៊ីក្នុងមួយម៉ោងគិតជាគីឡូវ៉ាត់ម៉ោង(kWh)និងស៊្សូល(J) ។
   គ. ប្រាក់ចំណាយដើម្បីប្រើឆ្នាំងអ៊ុតនោះក្នុងរយៈពេល 30ថ្ងៃ បើមួយថ្ងៃគេប្រើវា 2 ម៉ោងហើយថាមពលអគ្គិសនីថ្លៃ 750រៀលក្នុង1kWh ។

មេរៀនទី

# 2 ការប្រើប្រាស់ចរន្តអគ្គិសនីក្នុងគេហដ្ឋាន

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីបណ្ដាញអគ្គិសនីដែលប្រើប្រាស់ទូទៅតាមគេហដ្ឋាន
- ❑ បង្ហាញពីរបៀបតកុងតាក់និងភុយស៊ីបក្នុងសៀគ្វី
- ❑ បង្ហាញពីរបៀបជ្រើសរើសភុយស៊ីប
- ❑ បង្ហាញពីរបៀបតបណ្ដាញអំពូលមួយដែលមានកុងតាក់ពីរ
- ❑ ពណ៌នាបានពីគ្រោះថ្នាក់បណ្ដាលមកពីចរន្តអគ្គិសនី
- ❑ មានវិធានការបង្ការគ្រោះថ្នាក់ដែលបណ្ដាលមកពីចរន្តអគ្គិសនី ។

យើងបានសិក្សារួចមកហើយពីបណ្ដាញអគ្គិសនីក្នុងគេហដ្ឋាន តើចរន្តអគ្គិសនីនៃបណ្ដាញដែលប្រើប្រាស់ក្នុងគេហដ្ឋានមានប្រភពមកពីណា ? ហើយចរន្តនេះគេប្រើក្រោមតង់ស្យុងប៉ុន្មាន ?

## 1. ការប្រើប្រាស់ចរន្តអគ្គិសនីក្នុងគេហដ្ឋាន

ជាទូទៅ បណ្ដាញអគ្គិសនីដែលយើងប្រើប្រាស់តាមគេហដ្ឋានជាសៀគ្វីបិទមួយ ។ ក្នុងសៀគ្វីនេះគ្មានថ្មពិលឬអាគុយជាប្រភពទេ ។ ប្រភពថាមពលអគ្គិសនីនេះបានមកពីរោងចក្រអគ្គិសនី ។ ចំណែកឯចរន្តដែលចេញពីរោងចក្រអគ្គិសនីពុំមានទិសដៅតែមួយដូចចរន្តជាប់ (DC) ចេញពីថ្មពិលឬអាគុយឡើយ ។ ចរន្តនេះប្ដូរទិសដៅច្រើនដងក្នុងមួយវិនាទី "ចរន្តប្ដូរទិសដៅ 50 (ឬ 60 ដង) ក្នុងមួយវិនាទី" គេហៅចរន្តបែបនេះថា ចរន្តឆ្លាស់ (AC) ។

ការប្រើប្រាស់ចរន្តឆ្លាស់ (AC) ជួយសម្រួលដល់ការដឹកបញ្ជូនថាមពលអគ្គិសនីទៅកាន់តំបន់ឆ្ងាយៗជាងការប្រើប្រាស់ចរន្តជាប់ (DC) ។ នៅប្រទេសកម្ពុជា គេប្រើចរន្តឆ្លាស់ដែលមានតង់ស្យុងពី 220V ទៅ 240V និងមានប្រេកង់ 50Hz ។

ជាទូទៅបណ្ដាញអគ្គិសនីដែលយើងប្រើប្រាស់ក្នុងគេហដ្ឋានមានខ្សែមេពីរគឺខ្សែផាស ( Live wire) និងខ្សែណឺត (Neutral wire ) ។

## 1.1. សៀគ្វីអគ្គិសនី




### ក. ខ្សែផាស

ខ្សែផាសជាខ្សែដែលមានចរន្តអគ្គិសនីឆ្លងកាត់និងមានប៉ូតង់ស្យែលខ្ពស់ ។

### ខ. ខ្សែណឺត

ខ្សែណឺតជាខ្សែដែលមានចរន្តអគ្គិសនីឆ្លងកាត់ដែរ ប៉ុន្តែមានប៉ូតង់ស្យែលសូន្យ ។ ខ្សែនេះត្រូវបានគេតភ្ជាប់ទៅនឹងបន្ទះលោហៈមួយ រួចកប់វាទៅក្នុងដីនៅឯរោងចក្រអគ្គិសនីឬស្ថានីយចែកចាយ ។

### គ. ខ្សែដី

ខ្សែដីជាខ្សែភ្ជាប់តួនៃឧបករណ៍អគ្គិសនីដែលជាលោហៈទៅដីនៅកន្លែងប្រើប្រាស់ ដើម្បីបង្ការគ្រោះថ្នាក់ចៃដន្យដល់អ្នកប្រើប្រាស់(អគ្គិសនីឆក់) នៅពេលគេប៉ះទៅនឹងតួនៃឧបករណ៍អគ្គិសនីនោះ ព្រោះបន្ទុកអគ្គិសនីនៅលើសំបកត្រូវបានផ្ទេរអស់ទៅដី ។ ប៉ុន្តែចំពោះឧបករណ៍អគ្គិសនីដែលស្រោបអ៊ីសូឡង់ពីខាងក្រៅមិនមានខ្សែដែលតភ្ជាប់តួរបស់វាទៅដីទេ ។

## 2. របៀបតកុងតាក់និងភុយស៊ីបក្នុងសៀគ្វីមួយ

កុងតាក់និងភុយស៊ីបត្រូវតភ្ជាប់ទៅនឹងខ្សែផាស (L) ក្នុងសៀគ្វីដូចរូប ។ កាលណាកុងតាក់បិទឬចំហ ឬភុយស៊ីបដាច់នោះគ្មានចរន្តឆ្លងកាត់គ្រឿងអគ្គិសនីទេ ។ ផ្ទុយទៅវិញ បើកុងតាក់និងភុយស៊ីបត្រូវបានតភ្ជាប់ទៅនឹងខ្សែណឺត ពេលកុងតាក់ចំហឬភុយស៊ីបដាច់នោះ ចុងខ្សែផាស (L) នៅមានចរន្តឆ្លងកាត់ដដែល ។



*របៀបតកុងតាក់និងភុយស៊ីបក្នុងសៀគ្វី*

## 3. របៀបជ្រើសរើសភុយស៊ីប

ភុយស៊ីបប្រើនៅក្នុងឆ្នាប់ចរន្តបង្គោលបី មានកំណត់ចង្អុលស្តង់ដាតម្លៃ 3A និង 13A ។ តម្លៃ 3A នេះបញ្ជាក់ថាភុយស៊ីបអាចរលាយដាច់ កាលណាមានចរន្តធំជាង 3A ឆ្លងកាត់វា ។ បើគ្រឿងអគ្គិសនីឆ្លងកាត់ដោយចរន្តធំជាង 3A យើងគួរជ្រើសរើសភុយស៊ីបដែលមានកំណត់ចង្អុលធំជាង 3A ។



*របៀបជ្រើសរើសភុយស៊ីប*

## 4. របៀបតអំពូលមួយកុងតាក់ពីរ

តាមគេហដ្ឋាន មួយចំនួនគេចូលចិត្តប្រើកុងតាក់ពីរសម្រាប់បិទឬបើកសៀគ្វីដែលមានអំពូលតែមួយ ។ ក្នុងការតកុងតាក់បែបនេះ គេត្រូវបណ្តែតខ្សែចម្លងមួយនៅចន្លោះកុងតាក់ទាំងពីរ A និង B ដូចបង្ហាញក្នុងរូប ។

អំពូលនេះភ្លឺ កាលណាកុងតាក់ទាំងពីរបិទគឺភ្ជាប់ទៅនឹងខ្សែរួមគ្នា ប៉ុន្តែបើកុងតាក់មួយចំហ ហើយមួយទៀតបិទនោះគ្មានចរន្តឆ្លងកាត់អំពូលទេ ។

*ឧទាហរណ៍* : បើកុងតាក់ $K_1$ ភ្ជាប់ទៅនឹងចំណុច A ហើយកុងតាក់ $K_2$ ភ្ជាប់ទៅនឹងចំណុច B នោះអំពូលនេះភ្លឺ ។



*របៀបតអំពូលមួយកុងតាក់ពីរ*

## 5. វិធានបង្ការគ្រោះថ្នាក់ដោយសារចរន្តអគ្គិសនី

អគ្គិសនីផ្តល់ផលប្រយោជន៍ដល់យើងខ្លាំងណាស់ ប៉ុន្តែវាក៏ផ្តល់គ្រោះថ្នាក់ដល់យើងខ្លាំងណាស់ដែរ ប្រសិនបើយើងប្រើប្រាស់វាដោយខ្វះការប្រុងប្រយ័ត្ន ។

ខាងក្រោមនេះជាវិធានខ្លះៗដើម្បីបង្ការគ្រោះថ្នាក់ដោយសារចរន្តអគ្គិសនី:

- មិនត្រូវតភ្ជាប់គ្រឿងអគ្គិសនីច្រើនព្រមគ្នាទៅនឹងឆ្នាប់ចរន្តតែមួយ ព្រោះការប្រើហួសប្រមាណនេះបណ្តាលឱ្យខ្សែចម្លងឡើងក្តៅរលាយស្រោមអ៊ីសូឡង់ ហើយប៉ះគ្នាបង្កើតបានជាអគ្គិភ័យ ។
- មិនត្រូវប្រើប្រាស់ខ្សែចម្លងដែលដាច់រហែកស្រោមអ៊ីសូឡង់ទេ ។
- មិនត្រូវយកម្រាមដៃឬលោហៈទៅសិកបញ្ចូលក្នុងឆ្នាប់ចរន្តទេ ។

- មិនត្រូវឈរក្បែរបណ្ដាញខ្សែកាបអគ្គិសនីនៅពេលភ្លៀងខ្យល់ទេ ព្រោះខ្សែកាបអាចដាច់ធ្លាក់ចុះមកក្រោមប៉ះអ្នកផ្ទាល់ឬប៉ះដីសើម ដែលអាចចម្លងអគ្គិសនីមកឆក់អ្នក ។
- មិនត្រូវប៉ះពាល់ផ្នែកខាងក្នុងនៃទូរទស្សន៍ក្រោយពេលផ្ដាច់ចរន្តភ្លាមទេ ។
- មិនត្រូវធ្វើឱ្យប៉ូលទាំងពីរនៃអាគុយប៉ះគ្នាដោយមិនបានឆ្លងកាត់គ្រឿងទទួលអគ្គិសនីទេ ។

## មេរៀនសង្ខេប

- ជាទូទៅបណ្ដាញអគ្គិសនីដែលយើងប្រើប្រាស់មានខ្សែមេពីរគឺខ្សែផាស និងខ្សែណឺត ។
- ក្នុងសៀគ្វីកុងតាក់និងភុយស៊ីបត្រូវតភ្ជាប់ទៅនឹងខ្សែផាស ព្រោះកាលណាកុងតាក់ចំហឬភុយស៊ីបដាច់ នោះគ្មានចរន្តឆ្លងកាត់គ្រឿងអគ្គិសនីទេ ។
- គ្រោះថ្នាក់នៃចរន្តអគ្គិសនីបណ្ដាលមកពីមូលហេតុសំខាន់បីយ៉ាងគឺការខូចឬរលាយអ៊ីសូឡង់ដែលស្រោបខ្សែ ខ្សែចម្លងក្ដៅខ្លាំងពេក និងលក្ខខណ្ឌសំណើម ។

## សំណួរនិងលំហាត់

1. តើចរន្តអគ្គិសនីប្រើប្រាស់ក្នុងគេហដ្ឋានជាចរន្តជាប់ឬចរន្តឆ្លាស់? ហើយមានប្រភពមកពីណា ?
2. ដូចម្ដេចហៅថា ខ្សែផាស ខ្សែណឺត នឹងខ្សែដី ?
3. តើហេតុអ្វីបានជាកុងតាក់និងភុយស៊ីបត្រូវតបញ្ចូលនឹងខ្សែផាសក្នុងសៀគ្វី ?
4. នៅក្នុងឧបករណ៍អគ្គិសនីតែងតែមានភ្ជាប់នឹងខ្សែដី ។ តើគេភ្ជាប់ខ្សែដីក្នុងគោលបំណងអ្វី ?
5. ចូររៀបរាប់វិធីបង្ការគ្រោះថ្នាក់ដោយសារចរន្តអគ្គិសនី ។
6. ចូរបំពេញតារាងដោយជ្រើសរើសតម្លៃភុយស៊ីបដែលសមស្របនិងអាំងតង់ស៊ីតេចរន្តអគ្គិសនីដែលឆ្លងកាត់គ្រឿងអគ្គិសនី ។

| គ្រឿងអគ្គិសនី | ចរន្តឆ្លងកាត់គ្រឿងអគ្គិសនីគិតជា (A) | តម្លៃភុយស៊ីបគិតជា (A) |
|---|---|---|
| ប្រដាប់ដុតស៊ក់ | 4 | .................... |
| កង្ហារកម្ដៅ | 12 | .................... |
| ឆ្នាំងអ៊ុត | 10 | .................... |
| ទូទឹកកក | 0.5 | .................... |
| ម៉ាញេ | 0.2 | .................... |

## ? សំណួរបញ្ចប់ជំពូកទី៣

**I.** ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវមានតែមួយគត់

1 ខ្សែដីត្រូវបានប្រើដើម្បី

☐ ក. ការពារការឆក់ ☐ ខ. ការពារឧបករណ៍កុំឱ្យឆេះខូច

☐ គ. ការពារចរន្តដែលលើសឆ្លងកាត់ ☐ ឃ. ការពារបំរែបំរួលនៃតង់ស្យុង

2. តើរូបមន្តខាងក្រោមមួយណាដែលបង្ហាញថាមពលកម្ដៅ

☐ ក. $E = RI^2t$ ☐ ខ. $E = VIt$ ☐ គ. $E = Pt$ ☐ ឃ. $E = mc\Delta t$

3. រូបនេះបង្ហាញពីអំពូលពីរតជាខ្នែងក្នុងសៀគ្វីបំភ្លឺមួយ ។ នៅនឹងសៀគ្វីនេះគេមានទីតាំងសម្គាល់ 4 គឺ A , B , C , និង D ។ តើភុយស៊ីបត្រូវភ្ជាប់ត្រង់ទីតាំងណាទើបសៀគ្វីនេះត្រឹមត្រូវ ?




☐ ក. ទីតាំង D ☐ ខ. ទីតាំង B

☐ គ. ទីតាំង A ☐ ឃ. ទីតាំង C

**II.** ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1 កម្ដៅដែលភាយចេញពីអង្គធាតុចម្លង ពេលមានចរន្តឆ្លងកាត់ជាថាមពលមួយបែបហៅថា ..... ។

2. កុងតាក់និងភុយស៊ីបត្រូវតែតភ្ជាប់ទៅនឹងខ្សែ .................. ។

3 ខ្សែចម្លងដែលភ្ជាប់ទៅនឹងឧបករណ៍អគ្គិសនីភាគច្រើនមានបីគឺខ្សែ ..................

ខ្សែ .................. និងខ្សែ .................. ។

**III.** លំហាត់

1 ឆ្នាំងអ៊ិតអគ្គិសនីមួយបានដំណើរការរហូតដល់សីតុណ្ហភាពថេរ ក្រោយពេលបិទកុងតាក់អស់រយៈពេល 300s មក ។ ចរន្តដែលឆ្លងកាត់គឺ 1.3A ។ គណនាថាមពលដែលផ្ដល់ពីប្រភពមេ 240V ក្នុងខណៈដែលឆ្នាំងអ៊ិតកំពុងឡើងក្ដៅ ។

2. កំសៀវអគ្គិសនីមួយមានអានុភាព 600W ។ គណនា :

ក. រេស៊ីស្តង់នៃកំសៀវ បើចរន្តដែលឆ្លងកាត់មានអាំងតង់ស៊ីតេ 5A

ខ. បរិមាណកម្ដៅដែលកំសៀវនោះផ្ដល់ឱ្យក្នុងមួយម៉ោង

3. ខ្សែចម្លងមួយឆ្លងកាត់ដោយចរន្តដែលមានអាំងតង់ស៊ីតេ 2A ក្នុងរយៈពេល 1 នាទី ។ ថាមពលអគ្គិសនីដែលត្រូវចំណាយមានទាំងអស់ 2640J ។ គណនារេស៊ីស្តង់របស់ខ្សែចម្លង ។

4. តារាងខាងក្រោមនេះបង្ហាញពីឧបករណ៍អគ្គិសនីមួយចំនួន

| តង់ស្យុងផ្តល់ 230V | |
|---|---|
| ក. ប្រដាប់បូមធូលី 460W | ខ. ឆ្នាំងអ៊ុត 920W |
| គ. កង្ហារកម្តៅ 1150W | ឃ. ម៉ាញេ 23W |
| ង. ក្បាលចាក់វីដេអូ 46W | ច. ទូរទស្សន៍ 115W |

ក. គណនាអានុភាពនៃឧបករណ៍នីមួយៗគិតជា kW ។

ខ. គណនាចរន្តដែលឆ្លងកាត់ឧបករណ៍នីមួយៗ ។

5. ចូរសរសេរឈ្មោះផ្នែកផ្សេងៗនៃឆ្នាប់ចរន្តដូចរូប ។




ក. ...................... ខ. ......................

គ. ...................... ឃ. ......................

6. ខាងក្រោមនេះជាតារាងលំអិតនៃការប្រើប្រាស់អគ្គិសនីនៅគេហដ្ឋានមួយក្នុងកំឡុងពេលបីខែ ។

| ឧបករណ៍អគ្គិសនី | អានុភាពប្រើ kW | រយៈពេលប្រើ h | ថាមពលប្រើគិតជាkWh |
|---|---|---|---|
| បំភ្លឺ | 0.8 | 270 | ? |
| កម្តៅ | 12.0 | 150 | ? |
| ផ្សេងៗ | 2.0 | 400 | ? |
| | | សរុប | ? |

ក. ចូរបំពេញឱ្យបានត្រឹមត្រូវត្រង់កន្លែងសញ្ញាសួរក្នុងតារាង ។

ខ. គណនាតម្លៃសរុបនៃការប្រើប្រាស់ថាមពលអគ្គិសនីក្នុងរយៈពេលបីខែ ។ បើគេគិតក្នុង 1kWh ថ្លៃ 720 រៀល ។

7. រូបខាងក្រោមនេះបង្ហាញពីផ្នែកមួយនៃសៀគ្វីមេនៅក្នុងគេហដ្ឋានមួយ ។ អំពូលពីរ A និង B នីមួយៗមានកំណត់ចង្អុល 60W – 230V ត្រូវតភ្ជាប់នៅនិងខ្សែផាសឆ្លងកាត់ដោយកុយស៊ីប X ។ កំសៀវអគ្គិសនីមួយមានកំណត់ចង្អុល 750W – 230V ត្រូវតភ្ជាប់នៅនិងខ្សែផាសឆ្លងកាត់ដោយ

ភុយស៊ីប Y ។ ឯភុយស៊ីប z ការពារសៀគ្វីចេញ ។ សំបកកំសៀវអគ្គិសនីនេះតភ្ជាប់ទៅនិងខ្សែដី ។ តង់ស្យុងផ្តល់មានតម្លៃ 230V ។

ក. គណនាអាំងតង់ស៊ីតេចរន្តឆ្លងកាត់ភុយស៊ីបនីមួយៗនៅពេលដែលអំពូលទាំងពីរនិងកំសៀវអគ្គិសនីកំពុងដំណើរការ(កុងតាក់បិទ) ។

ខ. កំហុសឆ្លងក្នុងប្រព័ន្ធកំសៀវបណ្តាលឱ្យមានចរន្ត 10A ឆ្លងកាត់ភុយស៊ីប Y ។ កុងតាក់អំពូល A និង B នៅតែបិទដដែល ។

តម្លៃចរន្តអតិបរមានៃភុយស៊ីបមានក្នុងតារាង :

| | ភុយស៊ីប X | ភុយស៊ីប Y | ភុយស៊ីប Z |
|---|---|---|---|
| តម្លៃចរន្ត (A) | 3 | 5 | 15 |

ចូររៀបរាប់និងពន្យល់ តើមានអ្វីកើតឡើងចំពោះភុយស៊ីបនីមួយៗ X , Y និង Z ក្នុងពេលដែលប្រព័ន្ធកំសៀវមានកំហុសឆ្លង ។

គ. បើកំសៀវអគ្គិសនីនេះមានដំណើរការធម្មតា គេប្រើវាក្នុងមួយថ្ងៃ 15 នាទី ។ គណនាថាមពលអគ្គិសនីដែលកំសៀវស៊ីនិងតម្លៃថាមពលអគ្គិសនីដែលត្រូវចំណាយលើកំសៀវក្នុងរយៈពេលមួយសប្តាហ៍ បើ 1kWh ថ្លៃ 720 រៀល ។



# ជំពូកទី 4 អេឡិចត្រូម៉ាញេទិច




នៅឆ្នាំ 1820 មានអ្នកប្រាជ្ញជាតិ ដាណឺម៉ាកម្នាក់ឈ្មោះ អ៊ីក ស្តេដ បានពិសោធនិងរកឃើញពីទំនាក់ទំនងរវាងចរន្តអគ្គិសនី(បំលាស់ទីអេឡិចត្រុង)និងម៉ាញេទិច(លក្ខណៈឆក់ទាញនៃមេដែក)។ ទំនាក់ទំនងនេះហៅថា អេឡិចត្រូម៉ាញេទិច ឬផលម៉ាញេទិចនៃចរន្តអគ្គិសនី។ គេតែងយកផលនេះទៅប្រើដើម្បីបង្កើតឧបករណ៍អគ្គិសនីជាច្រើនដូចជា កណ្ដឹង ម៉ូទ័រ ជនិតា ឌីណាម៉ូ ប្រដាប់បំពងសំឡេង កង្ហារ.... ។ល។

ក្នុងជំពូកនេះ យើងនឹងសិក្សាពី ដែនម៉ាញេទិចបង្កើតដោយចរន្តអគ្គិសនី អេឡិចត្រូមេដែក កម្លាំងម៉ាញេទិចលើចរន្តអគ្គិសនី ចរន្តអាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច និងត្រង់ស្វូ។

# 1 ដែនម៉ាញេទិចបង្កើតដោយចរន្តអគ្គិសនី

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីវិធីធ្វើមេដែក
- ❑ ប្រើវិធានដៃស្តាំដើម្បីកំណត់ទិសដៅខ្សែដែនឬខ្សែកម្លាំងម៉ាញេទិចបង្កើតដោយចរន្តត្រង់និងខ្សែដែនម៉ាញេទិចនៃសូលេណូអ៊ីត
- ❑ ធ្វើពិសោធន៍បង្ហាញពីដែនម៉ាញេទិចបង្កើតដោយចរន្តត្រង់ ។

## 1. ពិសោធន៍




យើងយកខ្សែចម្លងត្រង់មួយ AB ទៅដាក់ក្រោមត្រីវិស័យ ហើយភ្ជាប់ខ្សែចម្លងនោះទៅនឹងសៀគ្វីបិទមួយដូចរូប ។ ពេលយើងបិទកុងតាក់ចរន្តអគ្គិសនីបានឆ្លងកាត់ខ្សែចម្លង AB ពេលនោះយើងឃើញទ្រនិចត្រីវិស័យងាកចេញពីទីតាំងដើម ហើយកែងនឹងខ្សែចម្លង ។ ម្តងនេះ យើងដាក់ខ្សែចម្លង AB ពីលើត្រីវិស័យវិញម្តង នៅពេលចរន្តឆ្លងកាត់ខ្សែចម្លង AB យើងសង្កេតឃើញទ្រនិចត្រីវិស័យងាកចេញពីទីតាំងដើមហើយកែងនឹងខ្សែចម្លងដែរ ប៉ុន្តែតាមទិសផ្ទុយពីមុន ។ ម្យ៉ាងវិញទៀត បើយើងប្តូរទិសដៅចរន្ត ទ្រនិចត្រីវិស័យប្តូរទិសដៅដែរ ។

ពិសោធន៍នេះបញ្ជាក់ឱ្យឃើញថា ក្នុងលំហជុំវិញខ្សែចម្លងឆ្លងកាត់ដោយចរន្តអគ្គិសនី វាបង្កើតឱ្យមានដែនម៉ាញេទិចមួយហៅថា **ដែនម៉ាញេទិចនៃចរន្តអគ្គិសនី** ។ ដែនម៉ាញេទិចនេះធ្វើឱ្យទ្រនិចត្រីវិស័យងាកចេញពីស្ថានភាពលំនឹងដើម ។

# 2. ខ្សែដែនម៉ាញេទិចនៃចរន្តត្រង់

## 2.1. ខ្សែដែនឬខ្សែកម្លាំងម៉ាញេទិចនៃចរន្តត្រង់




យើងយកខ្សែចម្លងត្រង់មួយសិកតាមរន្ធនៃក្រដាសកាតុងពីក្រោមឡើងលើដូចបង្ហាញក្នុងរូប ។ បន្ទាប់មកយើងតភ្ជាប់ចុងសងខាងនៃខ្សែចម្លងនោះទៅនឹងគោលទាំងពីរនៃអាគុយ រួចយើងរោយកម្ទេចដែកនៅលើក្រដាសកាតុងនោះ ។ ពេលចរន្តឆ្លងកាត់ខ្សែចម្លង យើងគោះក្រដាសកាតុងនោះយ៉ាងស្រាលៗជាច្រើនដង កម្ទេចដែកក៏លោតហើយមកតំរៀបគ្នាជារង្វង់ៗដែលមានចំណុចផ្ចិតរួមមួយ ។ រង្វង់ទាំងនោះតាងឱ្យខ្សែដែនម៉ាញេទិចបង្កើតដោយចរន្តត្រង់ ។

**ដូចនេះ ខ្សែដែនម៉ាញេទិចបង្កើតដោយចរន្តត្រង់ ជារង្វង់ដែលមានផ្ចិតឋិតលើខ្សែចម្លងត្រង់ ហើយមានប្លង់កែងនឹងខ្សែចម្លងត្រង់នោះ ។**

## 2.2. ទិសដៅនៃខ្សែដែនឬខ្សែកម្លាំងម៉ាញេទិច




*វិធានកណ្ដាប់ដៃស្ដាំ ដើម្បីកំណត់ទិសដៅខ្សែដែនម៉ាញេទិច*

ដើម្បីកំណត់ទិសដៅខ្សែដែនម៉ាញេទិចជុំវិញខ្សែចម្លង យើងប្រើវិធានកណ្ដាប់ដៃស្ដាំ ។ ប្រសិនបើយើងក្ដាប់ខ្សែចរន្តត្រង់នឹងដៃស្ដាំ ដោយឱ្យមេដៃចង្អុលទិសដៅចរន្ត(ពី+ ទៅ − )នោះម្រាមដៃក្ដាប់ចង្អុលទិសដៅខ្សែដែនម៉ាញេទិចជុំវិញខ្សែចម្លង ។

ដែនម៉ាញេទិចជុំវិញខ្សែចម្លងត្រង់កាន់តែខ្លាំង កាលណា

- វានៅកាន់តែជិតខ្សែចម្លង ។
- ខ្សែចម្លងឆ្លងកាត់ដោយអាំងតង់ស៊ីតេចរន្តកាន់តែធំ ។

# 3. ដែនម៉ាញេទិចនៃសូលេណូអ៊ីត

## 3.1. ខ្សែដែនឬខ្សែកម្លាំងម៉ាញេទិច



ខ្សែដែនឬខ្សែកម្លាំងម៉ាញេទិច

យើងយកខ្សែចម្លងលាបវ៉ែនីមករុំជុំវិញស៊ីឡាំងវែងមួយ ដោយលៃយ៉ាងណាឱ្យខ្សែមួយជុំៗ(មួយស្ពៀ) រុំឱ្យបានកៀកជាប់ៗគ្នា(ស្ពៀជាប់)ហើយជាច្រើនជាន់ត្រួតលើគ្នាតាមទិសដៅតែមួយ ។ ទង្វើរបៀបនេះយើងបានសូលេណូអ៊ីត ឬបូប៊ីនវែងមួយ ។

យើងអាចពិនិត្យខ្សែដែនម៉ាញេទិចនៃបូប៊ីនមួយឆ្លងកាត់ដោយចរន្តអគ្គិសនី ដោយចោះរន្ធក្រដាសកាតុងរឹងជាពីរជួរ ហើយនៅតាមរន្ធនោះយើងបញ្ចូលខ្សែចម្លងវែងមួយលាបវ៉ែនីរុំជាបូប៊ីន ។ ពេលចរន្តឆ្លងកាត់បូប៊ីន យើងគោះក្រដាសយ៉ាងស្រាលៗជាច្រើនដង ពេលនោះយើងសង្កេតឃើញកម្ទេចដែកលោតមកតំរៀបគ្នារាងជាខ្សែកោងបិទរត់កាត់ខាងក្រៅសូលេណូអ៊ីត ។ ចំណែកឯតំបន់កណ្តាលនៃសូលេណូអ៊ីត ខ្សែដែនម៉ាញេទិចមានរាងជាបន្ទាត់ស្របនឹងអ័ក្ស(ដែនឯកសណ្ឋាន) ។

## 3.2. ទិសដៅនៃខ្សែដែនឬខ្សែកម្លាំងម៉ាញេទិច




ទិសដៅខ្សែដែន

បើយើងដាក់ម្ជុលមេដែកនៅក្បែរចុងទាំងពីរនៃសូលេណូអ៊ីត យើងសង្កេតឃើញចុងម្ខាងរបស់វាទាញប៉ូលជើង ឯចុងម្ខាងទៀតទាញប៉ូលត្បូងនៃម្ជុលមេដែក ។ ការណ៍នេះបញ្ជាក់ថា សូលេណូអ៊ីតមានប៉ូលពីរ ។

ដើម្បីកំណត់ប៉ូលជើងនិងប៉ូលត្បូងនៃសូលេណូអ៊ីត យើងអាចប្រើវិធានកណ្តាប់ដៃស្តាំ ។ ប្រសិនបើយើងក្តាប់សូលេណូអ៊ីតនឹងដៃស្តាំ ដោយឱ្យម្រាមដៃក្តាប់ចង្អុលទិសដៅចរន្ត នោះមេដៃចង្អុលប៉ូលជើង N នៃសូលេណូអ៊ីតដែលខ្សែដែនម៉ាញេទិចរត់ចេញ ។

ដែនម៉ាញេទិចនៃសូលេណូអ៊ីតមួយកាន់តែខ្លាំង កាលណា

- ចរន្តឆ្លងកាត់កាន់តែធំ
- ចំនួនស្ពៀកាន់តែច្រើន
- សូលេណូអ៊ីតមានស្នូលដែកថែបឬដែកនៅខាងក្នុង ។

## 4. ធ្វើមេដែក

កាលណាចរន្ត(DC)ឆ្លងកាត់សូលេណូអ៊ីតដែលមានស្នូលរបារដែកថែបនៅខាងក្នុង របារដែកថែបក្លាយទៅជាមេដែកអចិន្ត្រៃយ៍ ទោះបីគេផ្តាច់ចរន្តក៏វានៅតែឆក់ដដែល ។ នេះគឺជាវិធីធ្វើមេដែកអចិន្ត្រៃយ៍ ។



ធ្វើមេដែកអចិន្ត្រៃយ៍

### មេរៀនសង្ខេប

- ចរន្តអគ្គិសនីអាចបង្កើតដែនម៉ាញេទិចមួយហៅថា ដែនម៉ាញេទិចនៃចរន្តអគ្គិសនី ។
- ខ្សែដែនម៉ាញេទិចបង្កើតដោយចរន្តត្រង់ជារង្វង់ដែលមានផ្ចិតស្ថិតនៅលើខ្សែចម្លងត្រង់ ហើយមានប្លង់កែងនឹងខ្សែចម្លងត្រង់នោះ ។
- ដែនម៉ាញេទិចជុំវិញខ្សែចម្លងត្រង់កាន់តែខ្លាំង កាលណាវានៅកាន់តែជិតខ្សែចម្លង ឬឆ្លងកាត់ដោយចរន្តកាន់តែធំ ។
- ដែនម៉ាញេទិចនៃសូលេណូអ៊ីតមួយកាន់តែខ្លាំង កាលណាចរន្តឆ្លងកាត់កាន់តែធំ ចំនួនស្ពៀកាន់តែច្រើន និងមានស្នូលដែកនៅខាងក្នុង ។

### សំណួរនិងលំហាត់

1. ដូចម្តេចហៅថាដែនម៉ាញេទិចនៃចរន្តអគ្គិសនី ?
2. តើដែនម៉ាញេទិចបង្កើតជុំវិញចរន្តត្រង់មានរាងដូចម្តេច ?
3. តើគេត្រូវធ្វើដូចម្តេចដើម្បីឱ្យដែនម៉ាញេទិចជុំវិញខ្សែចម្លងត្រង់កាន់តែខ្លាំង ?
4. តើដែនម៉ាញេទិចស្ថិតនៅតំបន់កណ្តាលនៃសូលេណូអ៊ីតមានរាងដូចម្តេច ? ហើយជាដែនអ្វី ?
5. តើសូលេណូអ៊ីតមានប៉ូលដែរឬទេ ? តើគេត្រូវធ្វើដូចម្តេចដើម្បីកំណត់ប៉ូល ?

# 2 អេឡិចត្រូមេដែក

**ចប់មេរៀននេះ សិស្សអាច**

- កំណត់និយមន័យអេឡិចត្រូមេដែក
- ពិសោធបង្ហាញពីលក្ខណៈនៃអេឡិចត្រូមេដែក
- អនុវត្តអេឡិចត្រូមេដែកក្នុងជីវភាពរស់នៅ ។

## 1. អេឡិចត្រូមេដែក

អេឡិចត្រូមេដែក ជាឧបករណ៍ទាំងឡាយណាដែលមានដែកសុទ្ធរុំដោយស្ពៀជាខ្សែចម្លងដែលមានចរន្តឆ្លងកាត់ ។

របារដែកសុទ្ធជាស្នូលនៃអេឡិចត្រូមេដែក ឯស្ពៀទាំងអស់ដែលមានចរន្តឆ្លងកាត់ជាបូប៊ីនឬរបុំ ។ ចំពោះស្នូលដែករាង U របុំខ្សែចម្លង ត្រូវបានគេធ្វើដើម្បីឱ្យប៉ូលទាំងពីរផ្ទុយគ្នា នៅចុងសងខាងនៃស្នូលដែកសុទ្ធ ពេលមានចរន្តឆ្លងកាត់ ។



*អេឡិចត្រូមេដែក*

## 2. លក្ខណៈនៃអេឡិចត្រូមេដែក

អេឡិចត្រូមេដែក ឆក់ទាញវត្ថុធ្វើពីដែកដោយកម្លាំងធំជាងមេដែកអចិន្ត្រៃយ៍ ហើយកម្លាំងឆក់ទាញនេះមានតែក្នុងរយៈពេលដែលចរន្តអគ្គិសនីឆ្លងកាត់របុំតែប៉ុណ្ណោះ ។ កាលណាគេផ្ដាច់ចរន្ត វត្ថុនោះធ្លាក់ចុះភ្លាម ។ នេះបង្ហាញថា កម្លាំងឆក់ទាញក៏បាត់ទៅវិញអស់ដែរ ។ ដូចនេះ អេឡិចត្រូមេដែកជាមេដែកមិនអចិន្ត្រៃយ៍ ។ កម្លាំងឆក់ទាញនៃអេឡិចត្រូមេដែកអាស្រ័យនឹងអាំងតង់ស៊ីតេចរន្តឆ្លងកាត់ ចំនួនស្ពៀនៃរបុំ និងទីតាំងប៉ូល ។

## 2.1. អាំងតង់ស៊ីតេចរន្ត



អេឡិចត្រូមេដែកអាស្រ័យនិងអាំងតង់ស៊ីតេចរន្ត

យើងមានអេឡិចត្រូមេដែកពីរដូចគ្នាភ្ជាប់ទៅនិងសៀគ្វីដូចរូប ។ យើងឱ្យចរន្តអគ្គិសនីឆ្លងកាត់វាទាំងពីរដោយអាំងតង់ស៊ីតេខុសគ្នា ។ យើងសង្កេតឃើញថាអេឡិចត្រូមេដែកដែលឆ្លងកាត់ដោយចរន្តធំឆក់ទាញឃ្នាបដែកបានច្រើនជាង អេឡិចត្រូមេដែកដែលឆ្លងកាត់ដោយចរន្តតូច ។ ដូចនេះ យើងអាចសន្និដ្ឋានបានថា កាលណាចរន្តកើនឡើងកម្លាំងឆក់ទាញនៃអេឡិចត្រូមេដែកក៏កើនឡើងដែរ ។

## 2.2. ចំនួនស្ពៀ



អេឡិចត្រូមេដែកអាស្រ័យនិងចំនួនស្ពៀ

យើងធ្វើពិសោធន៍ដូចខាងលើដែរ ប៉ុន្តែយើងរក្សាអាំងតង់ស៊ីតេចរន្តអគ្គិសនីឱ្យនៅថេរ ហើយបង្កើនចំនួនស្ពៀនៃរបុំវិញម្តង ។ ពេលនេះយើងឃើញថា កាលណាចំនួនស្ពៀនៃរបុំកើនឡើង កម្លាំងឆក់ទាញនៃអេឡិចត្រូមេដែកក៏កើនឡើងដែរ ។

## 2.3. ទីតាំងប៉ូល



អេឡិចត្រូមេដែកអាស្រ័យនិងទីតាំងប៉ូល

យើងធ្វើពិសោធន៍ដូចខាងលើដែរជាមួយស្នូលដែករាង U ប៉ុន្តែម្តងនេះយើងរក្សាអាំងតង់ស៊ីតេចរន្តអគ្គិសនីឱ្យនៅថេរនិងចំនួនស្ពៀនៃរបុំនៅដដែល ។ ពេលនេះយើងឃើញថា កាលណាប៉ូលនៃស្នូលដែកនៅជិតគ្នា កម្លាំងឆក់ទាញនៃអេឡិចត្រូមេដែកក៏កើនឡើងដែរ ។

# 3. បម្រើប្រាស់នៃអេឡិចត្រូមេដែក

## 3.1. កណ្តឹងអគ្គិសនី



កណ្តឹងអគ្គិសនី

កណ្តឹងរោទ៍អគ្គិសនីជាឧបករណ៍សម្រាប់បំលែងថាមពលអគ្គិសនីទៅជាថាមពលសូរ ។ ផ្នែកសំខាន់ៗរបស់វាគឺអេឡិចត្រូមេដែករាង U របារដែកជាអាម៉ាតួនៃអេឡិចត្រូមេដែក កូនញញួរមួយភ្ជាប់ទៅនឹងអ័ក្សតាមរយៈបន្ទះលោហៈ ។ ពេលគេបិទកុងតាក់ ចរន្តអគ្គិសនីបានឆ្លងកាត់សៀគ្វីអេឡិចត្រូមេដែកប ហើយក៏ក្លាយជាមេដែក រួចធក់ទាញរបារដែកជាហេតុនាំឱ្យកូនញញួរវាយជួង ។ ប៉ុន្តែបំលាស់ទីរបស់របារដែកនេះធ្វើឱ្យបើកចំហកុងតាក់ គឺផ្តាច់ចរន្តក្នុងសៀគ្វី ហើយអេឡិចត្រូមេដែកបានបាត់បង់ដែនម៉ាញេទិចរបស់វាក៏លែងធក់ទាញរបារដែក ។ បន្ទះលោហៈក៏ទាញរបារដែកឱ្យមកស្ថានភាពដើមវិញ គឺប៉ះនឹងកុងតាក់ ធ្វើឱ្យសៀគ្វីដំណើរការម្តងទៀត ។ បន្ទាប់មកវដ្តនៃដំណើរការធ្វើដូចគ្នាដដែលៗ ធ្វើឱ្យកណ្តឹងចេះតែបន្តរោទ៍ពេលគេចុចកុងតាក់ ។

## 3.2. អេឡិចត្រូមេដែកប្រើក្នុងវិស័យសុខាភិបាល


វិធីយកកំទេចដែកចេញពីភ្នែក

គេប្រើអេឡិចត្រូមេដែក ក្នុងវិស័យសុខាភិបាល ដើម្បីទាញយកកំទេចដែកដែលចូលទៅក្នុងភ្នែកដោយមិនបាច់វះកាត់ឡើយ ។

## 3.3. គន្លឹះទ្វារអេឡិចត្រូម៉ាញេទិច



គន្លឹះទ្វារសុវត្ថិភាព

រូបនេះបង្ហាញពីគន្លឹះទ្វារសុវត្ថិភាពដែលប្រើប្រាស់ក្នុងធនាគារ ។ សោទ្វារនេះមានរបារដែកមួយសម្រាប់ចាក់ចូលទៅក្នុងរន្ធទ្វារ ។ ប្រសិនបើឆ្មាំទ្វារព្រមអនុញ្ញាតឱ្យនរណាចូលទៅក្នុងធនាគារ គាត់នឹងចុចកុងតាក់(កុងតាក់បិទ) ចរន្តក៏ឆ្លងកាត់តាមសូលេណូអ៊ីតហើយធ្វើឱ្យស្នូលដែកដែលនៅក្នុងសូលេណូអ៊ីតនោះក្លាយជាមេដែក រួចគឺធក់ទាញរបារដែកចេញពីរន្ធទ្វារហើយធ្វើឱ្យទ្វាររបើក ។ កាលណាគ្មានមនុស្សឆ្លងកាត់ទ្វារ គាត់នឹងចុចកុងតាក់ឡើងវិញ(កុងតាក់ចំហ) គ្មានចរន្តឆ្លងកាត់អេឡិចត្រូមេដែក ស្នូលដែកក៏ក្លាយទៅជាដែកធម្មតា ហើយរ៉ឺសក៏ទាញរបារដែកនោះឱ្យមកទីតាំងដើម ហើយទ្វារក៏ត្រូវបានដាក់គន្លឹះវិញ ។

## មេរៀនសង្ខេប

- អេឡិចត្រូមេដែក ជាឧបករណ៍ដែលមានដែកសុទ្ធរុំដោយស្ពៀជាខ្សែចម្លងដែលមានចរន្តឆ្លងកាត់ ។
- កម្លាំងឆក់ទាញនៃអេឡិចត្រូមេដែកអាស្រ័យនិង អាំងតង់ស៊ីតេចរន្ត ចំនួនស្ពៀ និងទីតាំងនៃប៉ូល ។

## ? សំណួរនិងលំហាត់

1. ដូចម្តេចហៅថាអេឡិចត្រូមេដែក ? តើផ្នែកសំខាន់ៗនៃអេឡិចត្រូមេដែកមានអ្វីខ្លះ ?
2. តើលក្ខណៈឆក់ទាញរបស់អេឡិចត្រូមេដែកមួយអាស្រ័យនិងកត្តាអ្វីខ្លះ ?
3. គេមានរបុំខ្សែចម្លងបួនឆ្លងកាត់ដោយចរន្តដូចគ្នាដូចរូបខាងក្រោម ។ តើរបុំមួយណាដែល




ក. មានដែនម៉ាញេទិចនៅជុំវិញវាខ្សោយជាងគេ ?

ខ. មានប៉ូលជើង(N) នៅខាងឆ្វេងដៃ ?

គ. នៅតែមានដែនម៉ាញេទិចនៅជុំវិញវា ទោះបីគេផ្តាច់ចរន្តមិនឱ្យឆ្លងកាត់វាក៏ដោយ ?

4. គេមានអេឡិចត្រូមេដែកមួយដូចរូប ។

ក. តើស្នូលនៃអេឡិចត្រូមេដែកធ្វើពីអ្វី ?

ខ. ហេតុអ្វីបានជាគេមិនយកដែកថែបធ្វើស្នូលអេឡិចត្រូមេដែក ?

គ. ហេតុអ្វីបានជាគេយកខ្សែចម្លងដែលមានស្រោបអ៊ីសូឡង់មករុំជារបុំឬបូប៊ីន ?

ឃ. ចូរបញ្ជាក់ឈ្មោះប៉ូលនៃអេឡិចត្រូមេដែក ។



អេឡិចត្រូមេដែក

# 3 កម្លាំងម៉ាញេទិចលើចរន្តអគ្គិសនី

**ចប់មេរៀននេះ សិស្សអាច**

- ❑ កំណត់ទិស ទិសដៅកម្លាំងម៉ាញេទិច
- ❑ បង្ហាញថាកម្លាំងដែលមានអំពើលើខ្សែអាស្រ័យនិងមេដែកនិងអាំងតង់ស៊ីតេចរន្តឆ្លងកាត់ខ្សែចម្លង
- ❑ បង្ហាញថាស៊ុមរាងចតុកោណកែងដែលឆ្លងកាត់ដោយចរន្តស្ថិតក្នុងដែនម៉ាញេទិចនឹងបង្កើតកម្លាំងបង្វិល ។

## 1. អំពើនៃកម្លាំងម៉ាញេទិចលើចរន្តអគ្គិសនី

### 1.1. ពិសោធន៍

យើងដាក់ខ្សែចម្លងស្រាលមួយ ឱ្យឋិតក្នុងដែនម៉ាញេទិចនៃមេដែករាង U (ដូចរូប) ។



*អំពើនៃកម្លាំងម៉ាញេទិចលើចរន្តអគ្គិសនី*

កាលណាចរន្តឆ្លងកាត់ខ្សែចម្លង ខ្សែចម្លងនោះផ្លាស់ទីចេញក្រៅមេដែកដោយកែងនិងខ្សែកម្លាំងម៉ាញេទិច ។ ទិសដៅនៃបំលាស់ទី គឺអាស្រ័យនឹងទិសដៅចរន្តនិងទិសដៅខ្សែកម្លាំងម៉ាញេទិច ។

- បើយើងប្តូរទិសដៅចរន្ត(ប្តូរគោលនៃបាតឺរីថ្មពិល) យើងឃើញខ្សែចម្លងនោះផ្លាស់ទីផ្ទុយពីទិសដៅមុន ។
- បើយើងប្តូរប៉ូលនៃមេដែក(ប្តូរទិសដៅខ្សែកម្លាំងម៉ាញេទិច) យើងឃើញខ្សែចម្លងនោះផ្លាស់ទីផ្ទុយពីទិសដៅមុនដែរ ។

ម្យ៉ាងវិញទៀតកម្លាំងដែលធ្វើឱ្យអង្គធាតុចម្លងផ្លាស់ទីគឺអាស្រ័យនឹង

- អាំងតង់ស៊ីតេចរន្តឆ្លងកាត់អង្គធាតុចម្លង : បើអាំងតង់ស៊ីតេចរន្តឆ្លងកាត់អង្គធាតុចម្លងកាន់តែធំ នោះកម្លាំងដែលធ្វើឱ្យអង្គធាតុចម្លងផ្លាស់ទីក៏កាន់តែខ្លាំងដែរ ។
- ដែនម៉ាញេទិចនៃមេដែក : បើអង្គធាតុចម្លងឋិតក្នុងដែនម៉ាញេទិចកាន់តែខ្លាំង នោះកម្លាំងដែលធ្វើឱ្យអង្គធាតុចម្លងផ្លាស់ទីក៏កាន់តែខ្លាំងដែរ ។
- ប្រវែងនៃអង្គធាតុចម្លងដែលឋិតនៅក្នុងដែនម៉ាញេទិចនៃមេដែកនោះ : បើប្រវែងអង្គធាតុចម្លងឋិតក្នុងដែនម៉ាញេទិចកាន់តែវែង នោះកម្លាំងដែលធ្វើឱ្យអង្គធាតុចម្លងផ្លាស់ទីក៏កាន់តែខ្លាំងដែរ ។

## 1.2. សន្និដ្ឋាន

ក្នុងដែនម៉ាញេទិចមួយ អង្គធាតុចម្លងឆ្លងកាត់ដោយចរន្តអគ្គិសនីរងនូវអំពើកម្លាំងមួយដែលកម្លាំងនោះអាស្រ័យនឹងអាំងតង់ស៊ីតេចរន្ត ដែនម៉ាញេទិច និងប្រវែងនៃអង្គធាតុចម្លង ដែលឋិតក្នុងដែនម៉ាញេទិច ។

## 1.3. ទិសដៅនៃបំលាស់ទីអង្គធាតុចម្លងឬទិសដៅកម្លាំង



*ទិសដៅនៃបំលាស់ទីអង្គធាតុចម្លងឬទិសដៅកម្លាំង*

យើងអាចកំណត់ទិសដៅកម្លាំងដែលមានអំពើលើអង្គធាតុចម្លងឆ្លងកាត់ដោយចរន្តអគ្គិសនីតាមវិធានដៃឆ្វេង ។ បើយើងដាក់ដៃឆ្វេងយ៉ាងណាឱ្យខ្សែកម្លាំងម៉ាញេទិច(ខ្សែកម្លាំងម៉ាញេទិចរត់ពីប៉ូល N ទៅ S)នៅតាមទិសដៅចង្អុលដៃ ហើយម្រាមដៃកណ្ដាលចង្អុលទិសដៅចរន្ត(ចរន្តរត់ពីប៉ូល + ទៅ -) នោះមេដៃកន្ទែកចង្អុលទិសដៅបំលាស់ទីនៃអង្គធាតុចម្លង ។ យើងអាចកំណត់ទិសដៅកម្លាំងម៉ាញេទិចតាមវិធានដៃឆ្វេងដោយប្រើម្រាមបី ដូចរូបខាងលើ ។

## 2. ស៊ុមឆ្លងកាត់ដោយចរន្តអគ្គិសនីឋិតក្នុងម៉ាញេទិច



*ស៊ុមឆ្លងកាត់ដោយចរន្តអគ្គិសនីឋិតក្នុងម៉ាញេទិច*

យើងដាក់ស៊ុមមួយធ្វើពីខ្សែចម្លងរាងចតុកោណកែងឱ្យស្របនិងទិសខ្សែកម្លាំងម៉ាញេទិចនៅចន្លោះប៉ូលនៃមេដែករាង U ហើយវាអាចវិលដោយសេរីជុំវិញអ័ក្សមួយ ។ ពេលចរន្តឆ្លងកាត់ស៊ុម ជ្រុងទាំងពីរនៃស៊ុមឆ្លងកាត់ដោយចរន្តមាន ទិសដៅផ្ទុយគ្នា ។ ដូចនេះនៅលើជ្រុងទាំងពីរនៃស៊ុមរងនូវកម្លាំងពីរស្របគ្នានិងមានទិសដៅផ្ទុយគ្នា ។ ជ្រុងម្ខាងរងកម្លាំងដែលមានទិសដៅទៅលើ ឯជ្រុងម្ខាងទៀតរងកម្លាំងដែលមានទិសដៅទៅក្រោម ។ អំពើនៃកម្លាំងទាំងពីរនេះហើយដែលធ្វើឱ្យស៊ុមវិលរហូតទាល់តែកម្លាំងទាំងពីរឈមគ្នានិងទប់ទល់គ្នានៅត្រង់ទីតាំងឈរមួយដែលប្លង់ស៊ុមកែងនិងខ្សែកម្លាំងម៉ាញេទិច ។

## 3. ម៉ូទ័រចរន្តជាប់

ផលរង្វិលនៃស៊ុមរាងចតុកោណកែងឆ្លងកាត់ដោយចរន្តហើយឋិតក្នុងដែនម៉ាញេទិចត្រូវបានយកទៅអនុវត្តធ្វើជាម៉ូទ័រអគ្គិសនី ។ ម៉ូទ័រអគ្គិសនីជាឧបករណ៍អគ្គិសនីដែលបំលែងថាមពលអគ្គិសនីទៅជាថាមពលមេកានិច ។

### 3.1. បង្គុំនៃម៉ូទ័រងាយ



*ម៉ូទ័រងាយ*

ស៊ុមមួយរាងចតុកោណកែងមានស្ពៀ រុំជារបុំច្រើនជាន់ធ្វើអំពីខ្សែទង់ដែងឆ្មារស្រោបអ៊ីសូឡង់ ។ ស៊ុមនេះដំឡើងនៅលើអ័ក្សមួយដែលឋិតនៅចន្លោះនៃមេដែករាង U ហើយចុងខ្សែម្ខាងៗនៃរបុំស៊ុមភ្ជាប់ទៅនិងគន្លះកងលោហៈពីរដែលនៅដាច់ពីគ្នាហៅថាកុំមុយតាទ័រ ។ ចរន្តទៅដល់កងតាមរយៈដុំកាបូនពីរបន្ទះហៅថាច្រាស ហើយចុងទាំងសងខាងរបស់វាភ្ជាប់ទៅនិងប្រភពចរន្តជាប់(បាតឺរីអាគុយឬថ្មពិល) ។

## ៣.២. ដំណើរការ

យើងរៀបចំឱ្យប្លង់ស៊ុមស្របនឹងខ្សែដែនម៉ាញេទិចនៃមេដែក រួចយើងឱ្យចរន្តឆ្លងកាត់វា ។ ពេលចរន្តឆ្លងកាត់ស៊ុម ជ្រុងទាំងពីរនៃស៊ុមឆ្លងកាត់ដោយចរន្តមានទិសដៅផ្ទុយគ្នា ។ ដូចនេះ ជ្រុងទាំងពីររងនូវកម្លាំងពីរស្របគ្នានិងមានទិសដៅផ្ទុយគ្នា ។ ជ្រុងម្ខាងរងកម្លាំងដែលមានទិសដៅទៅលើ ឯជ្រុងម្ខាងទៀតរងកម្លាំងដែលមានទិសដៅទៅក្រោម ។ អំពើនៃកម្លាំងទាំងពីរនេះធ្វើឱ្យស៊ុមវិលដល់ទីតាំងឈរមួយ(ទីតាំងលំនឹង) ដែលប្លង់ស៊ុមកែងនឹងខ្សែដែនម៉ាញេទិចទើបឈប់ ។ ប៉ុន្តែដោយសារនិចលភាព វាក៏បន្តធ្វើចលនាហួសពីទីតាំងនោះបន្តិច ។ នៅខណៈនោះ កុំមុយតាទ័រប្តូរទិសដៅចរន្តឆ្លងកាត់ជ្រុងទាំងពីរនៃស៊ុម ហើយស៊ុមក៏បន្តវិលក្នុងដែនម៉ាញេទិច ។

**មេរៀនសង្ខេប**

- ទិសដៅបំលាស់ទីនៃអង្គធាតុចម្លងអាស្រ័យនឹងទិសដៅចរន្តអគ្គិសនីនិងទិសដៅខ្សែដែនម៉ាញេទិច ។
- កម្លាំងដែលធ្វើឱ្យអង្គធាតុចម្លងផ្លាស់ទីអាស្រ័យនឹងអាំងតង់ស៊ីតេចរន្ត ដែនម៉ាញេទិច និងប្រវែងនៃអង្គធាតុចម្លងដែលឋិតនៅក្នុងដែនម៉ាញេទិចនៃមេដែកនោះ ។
- គោលការណ៍ស៊ុមវិលត្រូវបានយកទៅអនុវត្តក្នុងម៉ូទ័រអគ្គិសនី ។

## ? សំណួរនិងលំហាត់



រូប ក
រូប ខ

1. ចូរគូសបញ្ជាក់ទិសដៅកម្លាំងដែលមានអំពើលើខ្សែចម្លង(ដូចរូបក) ។ តើកម្លាំងប្រែប្រួលដូចម្តេច បើអាំងតង់ស៊ីតេចរន្តឆ្លងកាត់ខ្សែចម្លងកើនឡើង ? បើគេប្តូរទិសដៅចរន្ត ?
2. គេដាក់ខ្សែចម្លងឆ្លងកាត់ដោយចរន្តក្នុងដែនម៉ាញេទិច(ដូចរូបខ) ។
   - ក. ចូរគូសបញ្ជាក់ទិសដៅចរន្ត ។
   - ខ. ចូរគូសបញ្ជាក់ទិសដៅដែនម៉ាញេទិច ។
   - គ. ចូរគូសបញ្ជាក់ទិសដៅកម្លាំងដែលមានអំពើលើខ្សែចម្លង ។

មេរៀនទី

# 4 អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច

**ចប់មេរៀននេះ សិស្សអាច**

- បង្ហាញពីវិធីបង្កើតចរន្តអាំងឌុចស្យុង
- បង្ហាញពីវិធីបង្កើនអាំងតង់ស៊ីតេចរន្តអាំងឌុចស្យុង
- ពន្យល់ពីដំណើរការជនិតាចរន្តឆ្លាស់
- កំណត់ទិសដៅចរន្តអាំងឌុចស្យុង ។

តើគេផលិតចរន្តអគ្គិសនីដែលយើងប្រើប្រាស់សព្វថ្ងៃយ៉ាងដូចម្តេច ?

យើងមិនត្រូវការបាតិរីថ្មពិលឬអាគុយ ដើម្បីផលិតចរន្តអគ្គិសនីទេ ។ ប៉ុន្តែយើងគ្រាន់តែផ្លាស់ទីខ្សែចម្លងនៅក្នុងដែនម៉ាញេទិចនៃមេដែកឬផ្លាស់ទីមេដែកក្នុងរបុំខ្សែចម្លងប៉ុណ្ណោះ ។

យើងបានសិក្សារួចមកហើយថា ចរន្តអគ្គិសនីដែលឆ្លងកាត់ខ្សែចម្លងមួយបង្កើតឱ្យមានដែនម៉ាញេទិចជុំវិញខ្សែចម្លងនោះ ។ ប៉ុន្តែអ្នកប្រាជ្ញជនជាតិអង់គ្លេសម្នាក់ឈ្មោះ មីសែល ផារ៉ាដេ (Michael Faraday) បានលើកឡើងផ្ទុយវិញថា តើគេអាចបង្កើតចរន្តអគ្គិសនីដោយប្រែប្រួលដែនម៉ាញេទិចក្នុង អង្គធាតុចម្លងមួយឬផ្លាស់ទីអង្គធាតុចម្លងមួយក្នុងដែនម៉ាញេទិចបានដែរឬទេ ?

ហេតុដូចនេះហើយ បានជានៅឆ្នាំ 1831 គាត់អាចបង្កើតចរន្តអគ្គិសនីដោយផ្លាស់ទីអង្គធាតុចម្លងមួយក្នុងដែនម៉ាញេទិចបានពិតប្រាកដមែន ។

## 1. ចរន្តអគ្គិសនីបានមកពីអាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច

### 1.1. ពិសោធន៍ផារ៉ាដេ

គេភ្ជាប់ខ្សែចម្លងមួយទៅនឹងកាល់វ៉ាណូម៉ែត្រមួយរួចផ្លាស់ទីខ្សែចម្លងនោះតាមទិសដៅកែងនឹងខ្សែដែនម៉ាញេទិចនៃមេដែក(ដូចរូបទី 1) ។ គាត់សង្កេតឃើញ ទ្រនិចកាល់វ៉ាណូម៉ែត្រងាកចេញពីទីតាំងដើម ។ នេះបង្ហាញថា ក្នុងសៀគ្វី មានចរន្តអគ្គិសនីកើតឡើង ។




*រូបទី 1 : ការបង្កើតចរន្តអាំងឌុចស្យុង*

កាលណាគាត់រុញរបារមេដែកយ៉ាងលឿនចូលទៅក្នុងបូប៊ីន គាត់សង្កេតឃើញទ្រនិចកាល់វ៉ាណូម៉ែត្រងាកចេញតាមទិសដៅ (ដូចរូប ក) ។ នេះបង្ហាញថា ក្នុងសៀគ្វី មានចរន្តអគ្គិសនីកើតឡើង ។



*រូបទី 2: ការបង្កើតចរន្តអាំងឌុចស្យុង*

កាលណាគាត់ទុកមេដែកឱ្យនៅស្ងៀមក្នុងបូប៊ីន គាត់សង្កេតឃើញទ្រនិចកាល់វ៉ាណូម៉ែត្រមិនងាកទេ (ដូចរូបខ) ។ នេះបង្ហាញថា ក្នុងសៀគ្វីគ្មានចរន្តអគ្គិសនីកើតឡើង ។

កាលណាគាត់ទាញរបារមេដែកចេញពីបូប៊ីននោះ ទ្រនិចកាល់វ៉ាណូម៉ែត្រងាកចេញតាមទិសផ្ទុយ (ដូចរូប គ) ។ នេះបង្ហាញថា ក្នុងសៀគ្វីមានចរន្តអគ្គិសនីកើតឡើង ប៉ុន្តែមានទិសដៅផ្ទុយពីមុន ។

### 1.2. សន្និដ្ឋាន

តាមពិសោធន៍ខាងលើ គាត់សន្និដ្ឋានបានថា បំលាស់ទីខ្សែចម្លងនៅក្នុងដែនម៉ាញេទិចនៃមេដែក ឬបំលាស់ទីមេដែកក្នុងរបុំខ្សែចម្លងបង្កើតឱ្យមានចរន្តអគ្គិសនីនៅក្នុងសៀគ្វីបិទ ។ គេហៅបាតុភូតនេះថា **អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច** ។ ចំណែកឯចរន្តអគ្គិសនីដែលកើតឡើងក្នុងរយៈពេលដ៏ខ្លីក្នុងសៀគ្វីបិទនោះ គេហៅថា ចរន្តអគ្គិសនីអាំងឌុចស្យុង ឬចរន្តអាំងឌុចស្យុង ។

## 2. អាំងតង់ស៊ីតេនិងទិសដៅចរន្តអាំងឌុចស្យុង (អាំងឌី)

### 2.1. អាំងតង់ស៊ីតេចរន្តអាំងឌុចស្យុង

តាមពិសោធន៍បង្ហាញថា តម្លៃអាំងតង់ស៊ីតេចរន្តអាំងឌុចស្យុងកាន់តែធំ កាលណាគេ

- ផ្លាស់ទីខ្សែចម្លងឬមេដែកកាន់តែលឿន
- ប្រើមេដែកដែលមានកម្លាំងកាន់តែខ្លាំង(ខ្សែដែនម៉ាញេទិចខ្លាំង)
- រុំរបុំខ្សែចម្លងកាន់តែច្រើនជុំ

## 2.2. ទិសដៅចរន្តអាំងឌុចស្យុង (អាំងឌូ៊)



ទិសដៅចរន្តអាំងឌុចស្យុង

ដើម្បីកំណត់ទិសដៅចរន្តអាំងឌុចស្យុង គេប្រើវិធានដៃស្តាំ ។ ប្រសិនបើអ្នកដាក់ដៃស្តាំរបស់អ្នកក្នុងដែនម៉ាញេទិចនៃមេដែកយ៉ាងណាឱ្យខ្សែដែនម៉ាញេទិច(ខ្សែដែនម៉ាញេទិចរត់ពីប៉ូល N ទៅ S)តាមទិសចង្អុលដៃ ហើយមេដៃចង្អុលទិសដៅនៃបំលាស់ទីខ្សែចម្លង នោះម្រាមដៃកណ្តាលចង្អុលទិសដៅនៃចរន្តអាំងឌុចស្យុង ។ រូប(ក) ឬកំណត់ទិសដៅចរន្តអាំងឌុចស្យុងតាមវិធានដូច រូប(ខ) ។

# 3. ជនិតាចរន្តឆ្លាស់ឬអាល់ទែណាទ័រ

ផលវង្វិលនៃស៊ុមរាងចតុកោណកែងឆ្លងកាត់ដែនម៉ាញេទិចត្រូវបានយកទៅអនុវត្តធ្វើជាជនិតាអគ្គិសនីឬអាល់ទែណាទ័រ ។ ជនិតាអគ្គិសនីឬអាល់ទែណាទ័រជាឧបករណ៍អគ្គិសនីដែលបំលែងថាមពលមេកានិចទៅជាថាមពលអគ្គិសនី ។

## 3.1. ធាតុនៃជនិតា



បង្គុំនៃជនិតា

ស៊ុមមួយរាងចតុកោណកែងមានស្ពៀរ៉ុំជារបុំច្រើនជាន់ធ្វើអំពីខ្សែទង់ដែងឆ្មារស្រោបអ៊ីសូឡង់ ។ ស៊ុមនេះដំឡើងនៅលើអ័ក្សមួយដែលឋិតនៅចន្លោះនៃមេដែករាង U ហើយចុងខ្សែម្ខាងៗនៃរបុំស៊ុមភ្ជាប់ទៅនឹងកងលោហៈពីរដែលនៅដាច់ពីគ្នាហៅថា **កុំមុយតាទ័រ** ។ ចរន្តទៅដល់កុំមុយតាទ័រតាមរយៈបន្ទះកាបូនពីរបន្ទះ(បន្ទះធ្យូងពីរបន្ទះ)ហៅថា ច្រាស ។ ហើយចុងទាំងសងខាងរបស់វាភ្ជាប់ទៅនឹងគ្រឿងទទួលអគ្គសនី(អំពូល) ។

## 3.2. ដំណើរការ

ឧបមាថា គេចាប់ផ្តើមបង្វិលស៊ុមពីទីតាំងដេកតាមទិសដៅទ្រនិចនាឡិកា ។ ជ្រុងទាំងពីរនៃស៊ុមវិលឆ្លងកាត់ខ្សែដែនម៉ាញេទិចនៃមេដែកហើយចរន្តអាំងឌុចស្យុងក៏កើតមាននៅក្នុងរបុំខ្សែចម្លងតាមទិសដៅមួយ ។

នៅខណៈជ្រុងទាំងពីរនៃស៊ុមវិលដល់ទីតាំងមួយដែលខ្សែដែនម៉ាញេទិចស្របនឹងប្លង់នៃស៊ុមនោះគ្មានចរន្តឆ្លងកាត់ស៊ុមទេ ។

នៅខណៈជ្រុងទាំងពីរនៃស៊ុមបន្តវិលហួសពីទីតាំងនេះ ជ្រុងទាំងពីរនៃស៊ុមវិលឆ្លាស់ទីតាំងគ្នាឆ្លងកាត់ខ្សែដែនម៉ាញេទិចសាជាថ្មីហើយចរន្តអាំងឌុចស្យុងក៏កើតមាននៅក្នុងរបុំខ្សែចម្លងម្តងទៀត ប៉ុន្តែតាមទិសដៅផ្ទុយពីមុន ។ ដូចនេះជារៀងរាល់ពេលស៊ុមវិលបានកន្លះជុំ ចរន្តផ្លាស់ប្តូរទិសដៅម្តង ។ ចរន្តបែបនេះគេហៅថា ចរន្តឆ្លាស់(AC) ។ ចរន្តអាំងឌុចស្យុងដែលកើតមាននៅក្នុងរបុំខ្សែចម្លងគឺជាចរន្តឆ្លាស់ ។

## មេរៀនសង្ខេប

- បំលាស់ទីខ្សែចម្លងនៅក្នុងដែនម៉ាញេទិចនៃមេដែក ឬបំលាស់មេដែកក្នុងរង្វង់ខ្សែចម្លង បង្កើតឱ្យមានចរន្តអាំងឌុចស្យុង ។
- ជនិតាអគ្គិសនីឬអាល់ទែណាទ័រជាឧបករណ៍អគ្គិសនីដែលបំលែងថាមពលមេកានិចទៅជាថាមពលអគ្គិសនី ។

## សំណួរនិងលំហាត់

1. ដូចម្តេចហៅថា បាតុភូតអាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច ? ចរន្តអាំងឌុចស្យុង?

2. គេផ្លាស់ទីខ្សែចម្លងមួយក្នុងដែនម៉ាញេទិចដូចរូប (រូបទី 1) ។ ចូរកំណត់ទិសដៅចរន្ត អាំងឌុចស្យុង ។ តើចរន្តអាំងឌុចស្យុងទៅជាយ៉ាងណា បើគេប្រើមេដែកខ្លាំងជាងមុន ? បើគេផ្លាស់ទីខ្សែចម្លងកាន់តែលឿនជាងមុន? បើគេប្តូរទិសដៅបំលាស់ទីខ្សែចម្លង ? បើគេផ្លាស់ទីខ្សែចម្លងពីប៉ូល $S \rightarrow N$ ឬ $N \rightarrow S$ ?



រូបទី 1

3. គេផ្លាស់ទីមេដែកមួយទៅក្នុងរបុំខ្សែចម្លងមួយ(រូប) ។
   ក. កំណត់ប៉ូលនៃបូប៊ីន ។
   ខ. កំណត់ទិសដៅចរន្តអាំងឌុចស្យុងដោយប្រើវិធានដៃស្តាំ ។
   គ. តើទ្រនិចកាល់វ៉ាណូម៉ែត្រងាកទៅខាងណា បើគេ ផ្លាស់ទីមេដែកចូលក្នុងបូប៊ីន ? បើគេផ្លាស់ទីមេដែកចេញពីបូប៊ីន ? បើគេដាក់មេដែកឱ្យនៅស្ងៀម ?



រូបទី 2

មេរៀនទី

# 5 ត្រង់ស្វូម៉ាទ័រឬត្រង់ស្វូ

**ចប់មេរៀននេះ សិស្សអាច**

- ☐ រៀបរាប់ពីគោលការណ៍របស់ត្រង់ស្វូ
- ☐ សរសេរសមីការ $V_p/V_s = N_p/N_s$ និង $V_pI_p = V_sI_s$

តើត្រូវធ្វើដូចម្ដេច ដើម្បីបន្ថយតង់ស្យុងរាប់ពាន់វ៉ុលដែលចេញពីខ្សែបណ្ដាញតង់ស្យុងខ្ពស់មកនៅត្រឹម 220V ទៅ 240V សម្រាប់ប្រើប្រាស់ក្នុងគេហដ្ឋាន ?

## 1. រចនាសម្ព័ន្ធត្រង់ស្វូ

ត្រង់ស្វូ ជាឧបករណ៍បំលែងចរន្តអគ្គិសនីដែលមានតង់ស្យុងទាបទៅជាចរន្តអគ្គិសនីដែលមានតង់ស្យុងខ្ពស់ឬច្រាសមកវិញ ។

### 1.1. ត្រង់ស្វូ

ត្រង់ស្វូមានស្នូលធ្វើអំពីបន្ទះដែកថែបពិសេស(សំលោហៈដែកស៊ីឡិច ម៉ង់កាណែស...) មានរាងជាស៊ុមចតុកោណកែង ដែលគេញែកពីគ្នាតាមន័យអគ្គិសនីដោយលាបអ៊ីសូឡង់អគ្គិសនីយ៉ាងស្ដើង ។ គេរុំខ្សែចម្លងលាបវ៉ែនីជាបូប៊ីនជុំវិញស្នូលនេះជាពីររបុំផ្សេងគ្នាគឺ




- របុំទីមួយ(បូប៊ីនទី 1)តភ្ជាប់ទៅនឹងប្រភពចរន្តឆ្លាស់ហៅថា **របុំបឋម** ។ របុំនេះបង្កើតដែនម៉ាញេទិចឆ្លាស់ដែលបន្សុីស្នូលទៅជាមេដែក ។
- របុំទីពីរ(បូប៊ីនទី 2)មានចំនួនស្ពៀខុសពីរបុំទីមួយ របុំនេះតភ្ជាប់ទៅនឹងឧបករណ៍ប្រើប្រាស់ថាមពលអគ្គិសនីហៅថា **របុំមធ្យម (របុំរង)** ។

## 1.2. ប្រភេទនិងគំនូសបំព្រួញត្រង់ស្វូ

ត្រង់ស្វូមានពីរប្រភេទគឺ ត្រង់ស្វូដំឡើងនិងបញ្ចុះតង់ស្យុង ។ ត្រង់ស្វូដំឡើងតង់ស្យុងឆ្លាស់ពីទាបទៅខ្ពស់ហៅថា ស្ទិករ៉ុលទ័រ ។ ឯត្រង់ស្វូបញ្ចុះតង់ស្យុងឆ្លាស់ពីខ្ពស់ទៅទាបហៅថា ស្ទូរ៉ុលទ័រ ។




*គំនូសបំព្រួញត្រង់ស្វូបញ្ចុះតង់ស្យុង(ស្ទូរ៉ុលទ័រ)*




*គំនូសបំព្រួញត្រង់ស្វូដំឡើងតង់ស្យុង(ស្ទិករ៉ុលទ័រ)*

## 1.3. គោលការណ៍ត្រង់ស្វូ

គេចង់ប្រើអំពូលមួយដំណើរការក្រោមតង់ស្យុង 12V តែតង់ស្យុងបណ្ដាញមេគឺ 240V ដូចនេះ គេត្រូវប្រើត្រង់ស្វូ ។




*គោលការណ៍ត្រង់ស្វូ*

យើងដាក់របារដែកសុទ្ធមួយក្នុងរបុំ (បូប៊ីនទី 1)ដែលមានចំនួន 1 000 ស្ពៀ ហើយតភ្ជាប់វាទៅនឹងប្រភពចរន្តឆ្លាស់ដែលមានតង់ស្យុង 240V ។ បន្ទាប់មកយើងយករបុំមួយទៀត(បូប៊ីនទី2) ដែលមានចំនួន 50 ស្ពៀទៅតភ្ជាប់ទៅនឹងអំពូលមួយដែលអាចប្រើតង់ស្យុង 12V ។ យើងបង្វិតរបុំទីពីរនេះបន្តិចម្ដងៗ មកជិតរបុំទីមួយ ។ នៅចម្ងាយណាមួយនោះ យើងឃើញអំពូលនោះឆេះភ្លឺហើយពន្លឺរបស់វាកាន់តែខ្លាំង កាលណាវានៅកាន់តែជិតបូប៊ីនទីមួយ ។

ពេលចរន្តឆ្លាស់ឆ្លងកាត់របុំទីមួយឬរបុំចូល វាបង្កើតឱ្យមានបម្រែបម្រួលដែនម៉ាញេទិចនៅក្នុងរបុំទីពីរឬរបុំចេញហើយបង្កើតបានតង់ស្យុងឆ្លាស់ឡោយនៅរវាងចុងខ្សែនៃរបុំរបស់វា ។ ដូចនេះ របុំនេះបង្កើតបានចរន្តអាំងឌុចស្យុងហើយធ្វើឱ្យអំពូលឆេះភ្លឺ ។

តាមពិសោធន៍ គេសង្កេតឃើញថា តង់ស្យុង 240V បានថយចុះមកត្រឹមតង់ស្យុង 12V ប៉ុណ្ណោះ ។ ច្រាសមកវិញ គេក៏អាចបង្កើនតង់ស្យុងពី 12V ទៅតង់ស្យុង 240V បានដែរ ដោយប្រើត្រង់ស្វូដំឡើងតង់ស្យុង ។

*សំគាល់* : ត្រង់ស្វូដំណើរការជាមួយតែចរន្តឆ្លាស់ប៉ុណ្ណោះ វាមិនដំណើរការជាមួយនិងចរន្តជាប់ទេ ពីព្រោះចរន្តជាប់វាមិនធ្វើឱ្យមានបម្រែបម្រួលអាំងឌុចស្យុងម៉ាញ៉េទិចនៅក្នុងត្រង់ស្វូឡើយ ។

ម្យ៉ាងវិញទៀតគេសង្កេតឃើញថា តង់ស្យុងរវាងគោលនៃរបុំទី 1 និង របុំទី 2 អាស្រ័យនិងចំនួនស្ពៀរបស់វា ។ ប្រសិនបើចំនួនស្ពៀក្នុងរបុំទាំងពីរស្មើគ្នា តង់ស្យុងក៏ដូចគ្នាដែរ ។ កាលណាចំនួនស្ពៀក្នុងបូប៊ីនទាំងពីរខុសគ្នា តង់ស្យុងរវាងគោលនៃរបុំទី 1 និង របុំទី 2 សមាមាត្រនឹងចំនួនស្ពៀរបស់វា ។

គេសរសេរ : $\boxed{\frac{V_p}{V_s} = \frac{N_p}{N_s}}$ (1) $\frac{N_s}{N_p}$ ហៅថា ផលធៀបចំនួនស្ពៀឬចំនួនជុំ ។

$V_p$ តង់ស្យុងចូលនៃរបុំទី 1 និង $V_s$ តង់ស្យុងចេញនៅរបុំទី 2

$N_s$ ចំនួនស្ពៀនៅរបុំទី 2 និង $N_p$ ចំនួនស្ពៀនៅរបុំទី 1 ។

*ឧទាហរណ៍* : គេមានត្រង់ស្វូមួយដូចរូបខាងក្រោម ។




តាមសមីការ $\frac{V_p}{V_s} = \frac{N_p}{N_s}$ ដោយតង់ស្យុងចូលនៃរបុំទី 1 $V_s = 220V$

ចំនួនស្ពៀនៅរបុំទី 1 $N_p = 2200$ ជុំ និងចំនួនស្ពៀនៅរបុំទី 2 $N_s = 100$ ជុំ

យើងបាន : $\frac{220}{V_s} = \frac{2200}{100}$ ឬ $V_s = \frac{220 \times 100}{2200} = 10V$

តង់ស្យុងចូលនៅរបុំទី 1 (របុំបឋម) ស្មើនឹង 22 ដងនៃតង់ស្យុងចេញនៅរបុំទី 2 (របុំមធ្យម) ហើយចំនួនស្ពៀនៃរបុំទី 1 ស្មើនឹង 22 ដងនៃរបុំទី 2 ។

## 1.4. អានុភាពដែលផ្ទេរនៅក្នុងត្រង់ស្វូ

បើសិនគ្មានកំហាតថាមពលអគ្គិសនីក្នុងត្រង់ស្វូទេ នោះអានុភាពនៃចរន្តក្នុងរបុំទី 1 បានផ្ទេរទាំងអស់ទៅរបុំទី 2 ។ គេបានអានុភាពរបុំទី 1 = អានុភាពក្នុងរបុំទី 2 ឬ $P_p = P_s$

ព្រោះ $P_p = I_pV_p$ និង $P_s = I_sV_s$ គេសរសេរ : $I_pV_p = I_sV_s$ (2)

$I_p$ ចរន្តក្នុងរបុំទី 1 $V_p$ តង់ស្យុងចូលនៅរបុំទី 1

$I_s$ ចរន្តក្នុងរបុំទី 2 $V_s$ តង់ស្យុងចេញនៅរបុំទី 2

តាមសមីការ(1) និង (2) គេបាន : $\boxed{\frac{V_s}{V_p} = \frac{N_s}{N_p} = \frac{I_p}{I_s}}$ (ព្រោះ $\frac{V_s}{V_p} = \frac{I_p}{I_s}$) ។

*ឧទាហរណ៍* : ត្រង់ស្វូមួយមានអានុភាពស្មើនិង 23W ។ របុំទី 1 មានតង់ស្យុង 230V ហើយរបុំទី 2 មាន 10V ។ គណនាអាំងតង់ស៊ីតេចរន្តក្នុងបូប៊ីនទាំងពីរនោះ ។




អាំងតង់ស៊ីតេចរន្តក្នុងបូប៊ីនទាំងពីរនោះ

តាមសមីការ : $I_pV_p = I_sV_s$ ដោយ $V_p = 230V$ , $V_s = 10V$ , $P = 23W$

យើងបាន : $I_p \times 230 = I_s \times 10 = 23$

$$I_p \times 230 = 23 \text{ ឬ } I_p = \frac{23}{230} = 0.1A$$

$$I_s \times 10 = 23 \text{ ឬ } I_s = \frac{23}{10} = 2.3A \text{ ។}$$

ចំពោះរបុំដែលមានចំនួនស្ពៀតិច អាំងតង់ស៊ីតេចរន្តអគ្គិសនីឆ្លងកាត់វាមានតម្លៃធំ ។ ច្រាសមកវិញ ចំពោះរបុំមានចំនួនស្ពៀច្រើន ចរន្តអគ្គិសនីឆ្លងកាត់វាមានតម្លៃតូច ។

## 2. ដឹកជញ្ជូនថាមពល

ក្នុងចំណោមថាមពលទាំងអស់មានតែថាមពលអគ្គិសនីទេដែលអាចដឹកជញ្ជូនងាយជាងគេ ។

ឧបមាថា គេចង់ប្រើថាមពលមេកានិចនៃទន្លាក់ទឹកដែលនៅកន្លែងឆ្ងាយៗ ។ គេគ្រាន់តែបំលែងថាមពលមេកានិចនៃទន្លាក់ទឹកនោះឱ្យទៅជាថាមពលអគ្គិសនីដោយប្រើតួប៊ីនបង្វិលអាល់ទែណាទ័រឬជនិតាហើយតភ្ជាប់គ្រឿងអគ្គិសនីទៅនិងជនិតានេះតាមរយៈខ្សែចម្លងជាការស្រេច ។ ប៉ុន្តែក្នុងការបញ្ជូននិងចែកចាយថាមពលអគ្គិសនីពីកន្លែងផលិតទៅកន្លែងប្រើប្រាស់(រោងចក្រ មន្ទីរពេទ្យ សាលារៀន គេហដ្ឋាន ...) ថាមពលអគ្គិសនីមួយចំនួនត្រូវបានបាត់បង់ក្នុងខ្សែចម្លង ($RI^2t$) (ថាមពលអគ្គិសនីបំលែងទៅជាថាមពលកម្តៅ) ។ ដូចនេះដើម្បីកាត់បន្ថយថាមពលកម្តៅដែលភាយចេញពីខ្សែចម្លង គេប្រើវិធីពីរយ៉ាងគឺ បន្ថយរេស៊ីស្តង់ R ឬបន្ថយអាំងតង់ស៊ីតេចរន្ត I ។

- តាមរូបមន្ត $R = \rho\frac{L}{A}$ ដើម្បីបន្ថយ R គេត្រូវប្រើលោហៈដែលមានរេស៊ីស្ទីវីតេ $\rho$ តូចដូចជាអាលុយមីញ៉ូមឬទង់ដែងហើយមានមុខកាត់ A ធំ ។ ចំពោះផ្លូវឆ្ងាយវិធីនេះមិនចំណេញទេពីព្រោះ R នៅតែធំគេត្រូវការបរិមាណទង់ដែងយ៉ាងច្រើនបំផុត ហើយម្យ៉ាងទៀតខ្សែនិងមានទម្ងន់ធ្ងន់ដែលត្រូវចំណាយសសរយ៉ាងច្រើនដាំនៅជិតគ្នាក្នុងការទ្រវា ។ វិធីនេះពិបាកនិងសម្រេចបានតាមបច្ចេកទេសណាស់ ។

• វិធីដែលប្រសើរបំផុតក្នុងការប្រើប្រាស់សព្វថ្ងៃនេះ គឺបន្ថយចរន្តមកតូចបំផុតដែលអាចធ្វើទៅបាន ។ តាមរូបមន្ត P = VI បើគេបន្ថយអាំងតង់ស៊ីតេចរន្ត គេត្រូវដំឡើងតង់ស្យុង V ។ ការណ៍នេះធ្វើទៅបានលុះត្រាតែគេប្រើត្រង់ស្វូ ។

## មេរៀនសង្ខេប

• ត្រង់ស្វូ ជាឧបករណ៍សម្រាប់បំលែងថាមពលអគ្គិសនីដែលមានតង់ស្យុងទាបទៅជាថាមពលអគ្គិសនីដែលមានតង់ស្យុងខ្ពស់ឬប្រាសមកវិញ ។

• ត្រង់ស្វូដែលដំឡើងតង់ស្យុងឆ្លាស់ពីទាបទៅខ្ពស់ ហៅថាស៊ួកវ៉ុលទ័រ ។

• ត្រង់ស្វូដែលតំហាយតង់ស្យុងឆ្លាស់ពីខ្ពស់ទៅទាប ហៅថាស៊ូវ៉ុលទ័រ ។

• ទំនាក់ទំនងរវាងតង់ស្យុង ចំនួនជុំឬចំនួនស្ពៀ និងអាំងតង់ស៊ីតេចរន្តក្នុងត្រង់ស្វូ គណនាតាមរូបមន្ត $\frac{V_s}{V_p} = \frac{N_s}{N_p} = \frac{I_p}{I_s}$ ។

## សំណួរនិងលំហាត់

1. ដូចម្តេចហៅថាអាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច ?

1. តើចរន្តអាំងឌុចស្យុងកើតឡើងនៅពេលណា ?

2. ដូចម្តេចហៅថាជនិតាចរន្តឆ្លាស់ ?

3. ដូចម្តេចហៅថាត្រង់ស្វូ ?តើត្រង់ស្វូប្រភេទណាជាស៊ួកវ៉ុលទ័រ ? ហើយប្រភេទណាជាស៊ូវ៉ុលទ័រ ?

4. រូបខាងក្រោមនេះបង្ហាញពីត្រង់ស្វូមួយ ។ គណនាតង់ស្យុងចេញនៅរបុំមធ្យម ។

5. ក្នុងប៉ុស្តិវិទ្យុគេប្រើត្រង់ស្វូដែលមានរបុំមធ្យមពីរតជាសេរីឬជាខ្នែង ? នៅបង្គោលរបុំមធ្យមមួយមានតង់ស្យុង 4,4V ហើយបង្គោលរបុំមធ្យមមួយទៀតមានតង់ស្យុង 400V ។ តង់ស្យុងនៅរបុំបឋមស្មើនឹង 220V និងចំនួនស្ពៀស្មើនឹង 1300 ។ គណនាចំនួនស្ពៀនៃរបុំមធ្យមទាំងពីរ ។



## ? សំណួរបញ្ចប់ជំពូកទី៤

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយត្រូវតែមួយគត់ :

1. ក្នុងតំបន់កណ្ដាលនៃសូលេណូអ៊ីតដែលមានចរន្តឆ្លងកាត់ខ្សែកម្លាំងម៉ាញេទិចមានរាងជា :

☐ ក. ស្មើ ☐ ខ. រង្វង់

☐ គ. បន្ទាត់ស្របនិងអ័ក្សនៃសូលេណូអ៊ីត ☐ ឃ. បន្ទាត់កែងនិងអ័ក្សនៃសូលេណូអ៊ីត

2. កាលណាចរន្តឆ្លងកាត់របុំនៃខ្សែចម្លងដែលរុំជុំវិញស្នូលដែករាង U ដូចបង្ហាញក្នុងរូប ។ តើប៉ូលម៉ាញេទិចដែលមានត្រង់ W, X និង Y តាមប្រភេទមួយណា :

| | ត្រង់ W | ត្រង់ X | ត្រង់ Y |
|---|---|---|---|
| ☐ ក. | S | N | N |
| ☐ ខ. | N | S | S |
| ☐ គ. | S | S | N |
| ☐ ឃ. | N | S | N |




3. តើដំណើរការមួយណាដែលមិនអាចបង្កើតកម្លាំងអគ្គិសនីចលករបាន ?

☐ ក. ដាក់របាមេដែកនៅនឹង ខាងក្រៅបូប៊ីន ☐ ខ. បង្វិលបូប៊ីនក្នុងដែនម៉ាញេទិច

☐ គ. បង្វិលរបាមេដែកជុំវិញបូប៊ីន ☐ ឃ. ផ្លាស់ទីរបាមេដែកក្នុងបូប៊ីន

4. ត្រង់ស្វូមួយជាស្វូរ៉ុលទ័រកាលណាផលធៀប :

☐ ក. $\frac{N_s}{N_p} < 1$ ☐ ខ. $\frac{N_s}{N_p} = 1$ ☐ គ. $\frac{N_s}{N_p} = 0$ ☐ ឃ. $\frac{N_s}{N_p} > 1$

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ :

1. ចរន្តអគ្គិសនីអាចបង្កើតដែនម៉ាញេទិចមួយហៅថា ............................. ។

2. ក្នុងដែនម៉ាញេទិចមួយ អង្គធាតុចម្លងឆ្លងកាត់ដោយចរន្តអគ្គិសនីរងអំពើនៃ ................ ហើយផ្លាស់ទី ។

3. ខ្សែចម្លងត្រង់វែងពីរដាក់ស្របគ្នា កាលណាគេឱ្យចរន្តឆ្លងកាត់ខ្សែទាំងពីរតាមទិសដៅផ្ទុយគ្នានោះ ខ្សែទាំងពីរ ................................ ។

4. បាតុភូតដែលធ្វើឱ្យកើតមានកម្លាំងអគ្គិសនីចលករនៅក្នុងសៀគ្វីដោយសារបំរែបំរួលដែនម៉ាញេទិចហៅថា ...................................... ។

5. ត្រង់ស្វូដំឡើងតង់ស្យុងឆ្លាស់ពីទាបទៅខ្ពស់ហៅថា ........................ ។

6. ត្រង់ស្វូដែលតំហយតង់ស្យុងឆ្លាស់ពីខ្ពស់ទៅទាបហៅថា ........................ ។

## III. លំហាត់

1. ស្វូវ៉ុលទ័រមួយដែលតំហាយតង់ស្យុងឆ្លាស់ពី 240V ទៅ 12V សម្រាប់អយស្ម័នយានទំនើបមួយ ។ បើនៅរបុំទី 1 មាន 1000 ស្ពៀ តើនៅរបុំទី 2 មានចំនួនស្ពៀប៉ុន្មាន ?

2. ត្រង់ស្វូមួយមានចំនួនស្ពៀ $N_p = 100$ នៅរបុំទី 1 និង $N_s = 500$ នៅរបុំទី 2 ។

   ក. តើត្រង់ស្វូម៉ាទ័រនេះជាស្វូវ៉ុលទ័រឬជាស្វូវ៉ុលទ័រ ?

   ខ. គណនាតង់ស្យុងឆ្លាស់នៅរបុំទី 2 បើគេឱ្យតង់ស្យុងឆ្លាស់នៅរបុំទី 1 $V_p = 12V$ ។

3. ត្រង់ស្វូមួយនៅរបុំទី 1 មានចំនួនស្ពៀ $N_1$ និងនៅរបុំទី 2 មានចំនួនស្ពៀ $N_2$ ។ គេដឹងថាផលធៀប $\frac{N_2}{N_1} = 2$ ។ គណនា :

   ក. តង់ស្យុងនៅរបុំទី 2 បើគេឱ្យតង់ស្យុងនៅរបុំទី 1 $V_p = 240V$ ។

   ខ. ចំនួនជុំនៅរបុំទី 2 បើគេដឹងថាចំនួនជុំនៅរបុំទី 1 $N_p = 100$ ។

4. ត្រង់ស្វូនៃវិទ្យុទទួលសំឡេងមួយមានរបុំបឋមមួយនិងរបុំមធ្យម 4 ដូចរូប ។ របុំបឋមមាន 920 ស្ពៀ ហើយតទៅបណ្ដាញអគ្គិសនីដែលមានតង់ស្យុង 115V ។ តង់ស្យុងចេញនៅរបុំមធ្យមមានសរសេរនៅក្នុងរូប ។ គណនាចំនួនស្ពៀនៃរបុំមធ្យមនីមួយៗ ។



# ជំពូកទី 5 អុបទិច



យើងរាល់គ្នាអាចប្រកបអាជីវកម្មចិញ្ចឹមជីវិតបានដោយសារមានពន្លឺ បើគ្មានពន្លឺគឺគ្មានជីវិតសត្វលោកឡើយ ។ តើពន្លឺជាអ្វី ? ដើម្បីយល់ដឹងថាពន្លឺជាអ្វីហើយមានសារៈសំខាន់បែបណានោះទើបអ្នកវិទ្យាសាស្ត្រខិតខំសិក្សាស្រាវជ្រាវរាល់បាតុភូតទាំងឡាយណាដែលទាក់ទងនឹងពន្លឺមានន័យថាសិក្សាពីអ្វីដែលមើលឃើញដោយភ្នែក ។ ការសិក្សាពីពន្លឺនេះហៅថា **អុបទិច** ។ ក្នុងជំពូកនេះយើងសិក្សាតែអុបទិចធរណីមាត្រ ដែលមានមូលដ្ឋានលើដំណាលត្រង់ ចំណាំងផ្លាត ចំណាំងបែរនៃពន្លឺ ។ ការសិក្សានេះនាំឱ្យយើងយល់ច្បាស់ពីកំណរូបភាព ដែលឱ្យដោយប្រអប់ខ្មៅ កញ្ចក់ស្វ៊ែ និងឡង់ទី ។

មេរៀនទី

# 1 ដំណាលត្រង់នៃពន្លឺ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីប្រភពពន្លឺ
- ❑ បង្ហាញពីខ្សែត្រង់នៃពន្លឺ
- ❑ ពណ៌នាពីដំណាលពន្លឺឆ្លងកាត់អង្គធាតុថ្លា ស្រអាប់ ឃ្មឹក
- ❑ បង្ហាញពីកំណរូបភាពឱ្យដោយបន្ទប់ងងឹត ។

## 1. ពន្លឺ ចក្ខុវិទ្យា

### 1.1. សញ្ញាណពន្លឺ

ក្នុងបន្ទប់ងងឹត យើងមិនអាចមើលឃើញវត្ថុនានាដែលនៅជុំវិញយើងទេ ។ កាលណាយើងអុជទៀន ឬអុជចង្កៀងបំភ្លឺ រំពេចនោះយើងមើលឃើញទៀនឬចង្កៀង ហើយពិសេសឃើញវត្ថុទាំងឡាយដែលមាននៅក្នុងបន្ទប់នោះ ។ គំហើញនេះបណ្តាលមកពីវត្ថុទទួលពន្លឺ ហើយពន្លឺចាំងចេញចូលភ្នែក ។ ដូចនេះយើងអាចមើលឃើញវត្ថុនានាដោយសារវត្ថុទាំងនោះមានពន្លឺ ហើយភ្នែកយើងទទួលបានពន្លឺដែលចាំងចេញពីវត្ថុនោះដែរ ។

### 1.2. ប្រភពពន្លឺ

ភ្លើងទៀនឬភ្លើងចង្កៀងបង្កើតពន្លឺដោយផ្ទាល់ ហើយបន្សាយពន្លឺនោះទៅពេញបន្ទប់ ដូចនេះវត្ថុទាំងពីរនេះជាប្រភពពន្លឺ ។ ចំណែកឯព្រះអាទិត្យនិងផ្កាយបញ្ចេញពន្លឺដោយខ្លួនឯងក៏ជាប្រភពពន្លឺដែរ ។ គេចែកប្រភពពន្លឺជាពីរប្រភេទគឺ

- ប្រភពពន្លឺសិប្បនិម្មិត : ប្រភពនេះមនុស្សជាអ្នកបង្កើតដូចជា ភ្លើងទៀន ចង្កៀងពិល ចង្កៀងអគ្គិសនី ... ។
- ប្រភពពន្លឺធម្មជាតិ : ប្រភពពន្លឺនេះកើតឡើងពីធម្មជាតិដូចជាព្រះអាទិត្យ ផ្កាយ ... ។ ចំណែកឯព្រះចន្ទពុំមែនជាប្រភពពន្លឺធម្មជាតិទេ គឺគ្រាន់តែជាអង្គធាតុភ្លឺដែលមាននាទីបន្សាយពន្លឺទៅជុំវិញខ្លួនវានូវពន្លឺមួយភាគដែលវាបានទទួលពីព្រះអាទិត្យ ។

# 2. ដំណាលត្រង់នៃពន្លឺ សញ្ញាណកាំពន្លឺ

## 2.1. ការសង្កេត



គន្លងដំណាលពន្លឺ

ក្នុងលំហមួយងងឹតស្លុង ភ្នែកដែលស្ថិតនៅក្រៅគន្លងពន្លឺអាចមើលឃើញគន្លងនេះតាមផង់ធូលី ឬផ្សែងជាខ្សែត្រង់ ។ តាមការសង្កេតទូទៅអាចឱ្យគេសន្មតបានថា គន្លងដំណាលនៃពន្លឺជាបន្ទាត់ត្រង់ ។

## 2.2. ពិសោធន៍




(រូប ក) ពន្លឺដាលតាមខ្សែត្រង់ (រូប ខ)

គេដាក់ក្រដាសរឹងឃ្មិកបីដែលចោះប្រហោងនៅចន្លោះអណ្តាតភ្លើងទៀននិងភ្នែក ។ គេបង្ហួតដឹកខ្សែមួយក្នុងប្រហោងទាំងនោះ ដើម្បីឱ្យរន្ធរត់ត្រង់រៀងគ្នា(រូប ក) ។ ប្រហោងនៃក្រដាសរឹង A, B , C ស្ថិតនៅលើបន្ទាត់តែមួយ ពន្លឺចេញពីអណ្តាតភ្លើងទៅដល់ភ្នែកអ្នកសង្កេត ជាហេតុធ្វើឱ្យអ្នកសង្កេតអាចឃើញអណ្តាតភ្លើងទៀន ។ ប៉ុន្តែបើគេរុញក្រដាសរឹងណាមួយឱ្យរន្ធវាចេញពីជួរ(រូប ខ) ពេលនោះអ្នកសង្កេតមិនអាចមើលឃើញអណ្តាតភ្លើងទៀនទេ ។ តាមពិសោធន៍នេះគេអាចសន្និដ្ឋានបានថា **ពន្លឺដាលតាមខ្សែត្រង់** ។

កាំពន្លឺជាបន្ទាត់ដែលពន្លឺដាល ។ ***ឧទាហរណ៍*** : SA ជាបន្ទាត់តំណាងឱ្យកាំពន្លឺដែលដាលចេញពីប្រភព S នៃពន្លឺ(រូប ក) ។

បាច់ពន្លឺជាសំណុំកាំពន្លឺដែលស្ថិតក្នុងកោនកំណត់ដោយប្រភព ។ បាច់ពន្លឺមានបីប្រភេទ គឺបាច់ពន្លឺរីក បាច់ពន្លឺស្រប និងបាច់ពន្លឺរួម(រូបខ គ និង ឃ) ។




រូប(ក)កាំពន្លឺ រូប(ខ)បាច់ពន្លឺរីក រូប(គ)បាច់ស្រប រូប(ឃ)បាច់រួម

## 2.3. ល្បឿនដំណាលនៃពន្លឺ

ក្នុងមជ្ឈដ្ឋានផ្សេងគ្នា (ខ្យល់ ទឹក កែវ ...)ពន្លឺដាលដោយល្បឿនខុសៗគ្នា ។

- ក្នុងខ្យល់ឬសុញ្ញាកាសពន្លឺដាលដោយល្បឿនប្រហែល $300 \times 10^3 km/s$
- ក្នុងទឹកពន្លឺដាលដោយល្បឿនប្រហែល $225 \times 10^3 km/s$
- ក្នុងកែវពន្លឺដាលដោយល្បឿនប្រហែល $200 \times 10^3 km/s$ ។

# 3. អង្គធាតុថ្លា ស្រអាប់ ឃ្មឹក

អង្គធាតុថ្លា អាចឱ្យពន្លឺឆ្លងកាត់វាបាន ។ យើងអាចមើលឃើញវត្ថុនានាដែលនៅពីក្រោយវាបានច្បាស់ ។

ឧទាហរណ៍ : ខ្យល់ កញ្ចក់ កែវ ទឹកថ្លា ... ។

អង្គធាតុស្រអាប់ អាចទប់ស្កាត់ពន្លឺមួយភាគធំមិនឱ្យឆ្លងកាត់វា ។ ដូច្នេះមានតែពន្លឺមួយភាគតូចប៉ុណ្ណោះដែលអាចឆ្លងកាត់វាជាហេតុធ្វើឱ្យយើងមើលឃើញមិនបានច្បាស់ល្អ ។

ឧទាហរណ៍ : កញ្ចក់គ្រើម ប័សឺខ្សែនស្តើង ក្រដាសជ្រលក់ប្រេង ... ។

អង្គធាតុឃ្មឹក មិនអាចឱ្យពន្លឺឆ្លងកាត់វាបានទេ ជាហេតុធ្វើឱ្យយើងមិនអាចមើលឃើញវត្ថុនានាដែលនៅពីក្រោយវាទេ ។

ឧទាហរណ៍ : បន្ទះក្តារ បន្ទះលោហៈ ... ។

# 4. ម្លប់និងម្លប់ព្រាល

នៅពេលព្រះអាទិត្យចាំងពន្លឺប៉ះនឹងវត្ថុមួយ ពន្លឺមួយផ្នែកត្រូវបានទប់ស្កាត់ដោយដើមឈើ ។ យើងឃើញស្នាមខ្មៅនៅលើដី ស្នាមខ្មៅនោះហៅថា ស្រមោល ។ ចំណែកលំហដែលនៅចន្លោះស្រមោលនិងខ្លួនមនុស្សហៅថា ម្លប់ ។ ចំពោះស្រមោលនិងម្លប់ដែលភាគខ្លះប៉ុណ្ណោះនៃពន្លឺបានដាលដល់ហៅថា ស្រមោលព្រាលនិងម្លប់ព្រាល ។



### 4.1. ពិសោធន៍ទី 1




គេប្រើប្រភពពន្លឺមួយដែលជាចំណុចដូចរូប ។ នៅចន្លោះប្រភពពន្លឺ S និងអេក្រង់ E គេដាក់អង្គធាតុឃ្មឹកមួយរាងស្វៃដែលទប់ស្កាត់ពន្លឺ ។ តាមសម្មតិកម្ម ដំណាលត្រង់នៃពន្លឺគេសង្កេតឃើញកោនម្លប់មួយកំរិតដោយការស្មីដែលប៉ះប្រផិតនឹងរឹមនៃវត្ថុឃ្មឹកដែលដាក់ស្កាត់នោះ ។

ចន្លោះវត្ថុឃ្មឹកនិងអេក្រង់ដែលមិនបានទទួលពន្លឺហៅថាម្លប់ផ្ទាល់ ។ ចំណែកឯស្នាមម្លប់ដដែលនេះ ដែលស្ថិតនៅលើអេក្រង់ E ហៅថាស្រមោល ។

### 4.2. ពិសោធន៍ទី 2




ពិសោធន៍នេះមានលំនាំដូចពិសោធន៍ទី 1 ដែរ ប៉ុន្តែគេប្តូរប្រភពពន្លឺចំណុចទៅប្រភពពន្លឺលាតវិញ គេសង្កេតឃើញស្រមោលនិងម្លប់ផ្ទាល់គ្មានរឹមជាក់លាក់ទេ ។ តែមរបស់វាត្រូវព័ទ្ធដោយតំបន់កណ្តាលមួយហៅថាម្លប់ព្រាលនិងស្រមោលព្រាល ។

## 5. សូរ្យគ្រាសនិងចន្ទគ្រាស

បាតុភូតគ្រាសកើតមានឡើងពីការចោលស្រមោលនៃព្រះចន្ទលើផែនដីឬផែនដីលើព្រះចន្ទ ។

### 5.1. សូរ្យគ្រាស

សូរ្យគ្រាសកើតមានឡើងនៅខណៈដែលព្រះចន្ទស្ថិតនៅចន្លោះព្រះអាទិត្យនិងផែនដី ។ ពេលនោះមានស្រមោលនិងស្រមោលព្រាលកើតមានលើផ្ទៃផែនដី ។ តំបន់ដែលស្ថិតក្នុងស្រមោលប្រែជាងងឹតទាំងពេលថ្ងៃ ។ តំបន់ដែលស្ថិតក្នុងស្រមោលព្រាលបានទទួលពន្លឺព្រះអាទិត្យដោយភាគ ។



## 5.2. ចន្ទគ្រាស

ចន្ទគ្រាសកើតមាននៅខណៈដែលផែនដីស្ថិតនៅចន្លោះព្រះអាទិត្យនិងព្រះចន្ទ ។ ពេលនោះពន្លឺព្រះអាទិត្យមកប៉ះផែនដី(វត្ថុឃ្មិក)ដែលហេតុធ្វើឱ្យព្រះចន្ទមិនអាចទទួលពន្លឺពីព្រះអាទិត្យបាន ។ ដូចនេះហើយបានជាអ្នកដែលនៅលើផែនដីមិនអាចមើលឃើញព្រះចន្ទក្នុងពេលនោះ ។




## 6. កំណរូបភាពឱ្យដោយបន្ទប់ងងឹត ឬប្រអប់ខ្មៅ

យើងយកប្រអប់មួយរាងប្រលេពីប៉ែត មានចោះប្រហោងមួយតូចល្មមនៅផ្នែកខាងមុខហើយនៅខាងក្រោយរបស់វាគេភ្ជាប់បន្ទះកញ្ចក់ស្រអាប់មួយដែលអាចបិទបើកបាន(មើលរូប) ។ បើយើងដាក់វត្ថុភ្លឺមួយនៅពីមុខប្រអប់នេះ យើងនឹងឃើញរូបភាពរបស់វាឈរបញ្ច្រាសនៅលើបន្ទះស្រអាប់(អេក្រង់) ហើយមានរូបរាងដូចគ្នានិងវត្ថុដែលដាក់នៅពីមុខប្រអប់ ។



*កំណរូបភាពឱ្យដោយបន្ទប់ងងឹតឬប្រអប់ខ្មៅ*

តាង A, B, … ជាចំណុចដែលកាំពន្លឺដាលចេញពីវត្ថុឆ្លងកាត់ចំណុច O (រន្ធ)មកប៉ះបន្ទះកញ្ចក់ស្រអាប់ហើយទទួលបានជាស្លាមភ្លឺ A', B', … ។ សំណុំស្លាមភ្លឺទាំងនេះបង្កើតបានជារូបភាពមួយដូចគ្នានិងវត្ថុ ។ ម្យ៉ាងវិញទៀតដោយពន្លឺដាលជាខ្សែត្រង់ឬជាបន្ទាត់ យើងអាចគូសរូបភាពនៅលើអេក្រង់ដោយគូសកាំពន្លឺនីមួយៗដែលដាលចេញពីវត្ថុទៅអេក្រង់ ។

រូបភាពឱ្យដោយបន្ទប់ងងឹត ជារូបភាពពិតដិតលើអេក្រង់មានទិសដៅផ្ទុយពីវត្ថុ ។ យើងសង្កេតឃើញរូបភាពកាន់តែច្បាស់ កាលណាប្រហោងមានវិមាត្រកាន់តែតូច ។

ទំហំរូបភាពអាស្រ័យនឹងទីតាំងវត្ថុធៀបនឹងរន្ធ :

- បើចម្ងាយវត្ថុស្មើនឹងចម្ងាយរូបភាព ទំហំរូបភាព ស្មើនឹងទំហំវត្ថុ ។
- បើចម្ងាយវត្ថុជិតជាងចម្ងាយរូបភាពទំហំរូបភាពធំជាងទំហំវត្ថុ ។
- បើចម្ងាយវត្ថុឆ្ងាយជាងចម្ងាយរូបភាពទំហំរូបភាពតូចជាងទំហំវត្ថុ ។

យើងអាចគណនាទំហំវត្ថុឬទំហំរូបភាពតាមរូបមន្ត :

$$\frac{\text{ទំហំរូបភាព}}{\text{ទំហំវត្ថុ}} = \frac{\text{ចម្ងាយរូបភាព}}{\text{ចម្ងាយវត្ថុ}} \quad \text{ឬ} \quad \frac{h'}{h} = \frac{d'}{d}$$

## មេរៀនសង្ខេប

- គេចែកប្រភពពន្លឺជាពីរប្រភេទគឺប្រភពពន្លឺសិប្បនិម្មិតនិងប្រភពពន្លឺធម្មជាតិ ។
- ពន្លឺដាលតាមខ្សែត្រង់ ។
- ក្នុងមជ្ឈដ្ឋានផ្សេងគ្នា (ទឹក ខ្យល់ កែវ ...)ពន្លឺដាលដោយល្បឿនខុសៗគ្នា ។
- រូបភាពឱ្យដោយបន្ទប់ងងឹត ជារូបភាពពិតជិតលើអេក្រង់និងមានទិសដៅផ្ទុយពីវត្ថុហើយ ទំហំរូបភាពរបស់វាអាស្រ័យនឹងទីតាំងវត្ថុ ។

## សំណួរនិងលំហាត់

1. តើភ្នែករបស់អ្នកអាចមើលឃើញវត្ថុនានាក្នុងទីងងឹតបានដែរឬទេ ? ព្រោះហេតុអ្វី ?
2. ចូររៀបរាប់ពីប្រភពពន្លឺធម្មជាតិនិងប្រភពពន្លឺសិប្បនិម្មិត ?
3. តើពន្លឺដាលនៅក្នុងខ្យល់ដោយល្បឿនប៉ុន្មាន ?
4. ដូចម្ដេចហៅថា បាច់ពន្លឺ ? តើបាច់ពន្លឺមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
5. ដូចម្ដេចហៅថា អង្គធាតុថ្លា អង្គធាតុស្រអាប់ និងអង្គធាតុឃ្មឹក ? ចូររកឧទាហរណ៍ ។
6. ចូរពន្យល់បាតុភូតសូរ្យគ្រាស និងចន្ទគ្រាស ។
7. ចូរប្រើសម្មតិកម្មដំណាលត្រង់នៃពន្លឺដើម្បីពន្យល់រូបភាពបញ្ច្រាសនៅខាងក្រោយប្រអប់ខ្មៅ ។
8. តើទំហំរូបភាពនៃវត្ថុមួយដែលកើតក្នុងប្រអប់ងងឹតអាស្រ័យនឹងរាងរន្ធឬទេ ? តើទំហំនេះប្រែប្រួលដូចម្ដេច : កាលណាវត្ថុខិតចេញទៅឆ្ងាយពីប្រអប់ ? កាលណាគេបន្ថយជម្រៅប្រអប់ ?
9. ដើមឈើមួយដើមមានកម្ពស់ 12m ។ វាឋិតនៅឃ្លាតពីរន្ធនៃបន្ទប់ងងឹតចម្ងាយ 40m ។ គណនាទំហំរូបភាពរបស់ដើមឈើ(ជម្រៅរបស់បន្ទប់ងងឹតស្មើនឹង 20dm) ។

# 2 ចំណាំងផ្លាតនៃពន្លឺ

ចប់មេរៀននេះ សិស្សអាច

- ❑ ពិសោធបង្ហាញពីបាតុភូតចំណាំងផ្លាតនៃពន្លឺ
- ❑ បកស្រាយបានត្រឹមត្រូវពីច្បាប់ចំណាំងផ្លាតនៃពន្លឺ
- ❑ អនុវត្តចំណាំងផ្លាតនៃពន្លឺ ។

## 1. ចំណាំងផ្លាតនៃពន្លឺ

កាលណាយើងឈរនៅមាត់បឹងឬត្រពាំងនៅពេលស្ងប់ខ្យល់ យើងសង្កេតឃើញ នៅលើផ្ទៃទឹកមានរូបភាពវត្ថុទាំងឡាយដែលឋិតនៅតាមមាត់ទឹក ។ ម្យ៉ាងវិញទៀតកាលណាយើងឈរនៅមុខផ្ទៃកញ្ចក់ឆ្លុះមុខ យើងឃើញរូបភាពរបស់យើងនៅក្នុងផ្ទៃកញ្ចក់នោះ ។

យើងអាចមើលឃើញរូបភាពដោយសារពន្លឺដែលចេញមកពីវត្ថុហើយចូលមកក្នុងភ្នែកយើងក្រោយពីចាំងផ្លាតលើផ្ទៃទឹកឬកញ្ចក់ ។

ចំណាំងផ្លាតនៃពន្លឺ ជាដំណាលនៃពន្លឺចាំងប៉ះនឹងវត្ថុអ្វីមួយហើយផ្លាតចូលមជ្ឈដ្ឋានដើមវិញ ។

## 2. ច្បាប់ចំណាំងផ្លាត




កាលណា គេបញ្ចាំងកាំពន្លឺឆ្មារមួយចេញពីចំណុច A ឱ្យប៉ះនឹងកញ្ចក់ប្លង់ត្រង់ I (រូប) កាំពន្លឺនោះផ្លាតមកមជ្ឈដ្ឋានដើមវិញតាមទិស IR ។ គេបាន៖

- កាំ AI ហៅថា កាំចាំងប៉ះ ។
- កាំ IR ហៅថា កាំចាំងផ្លាត ។
- ចំណុច I ជាចំណុចចំណាំងប៉ះ ។
- ខ្សែIN កែងនឹងកញ្ចក់ត្រង់ចំណុចចំណាំងប៉ះហៅថា ខ្សែកែង ។
- មុំ i ដែលកើតពីកាំចាំងប៉ះ AI និងខ្សែកែង N ហៅថា មុំចំណាំងប៉ះ ។
- មុំ r ដែលកើតឡើងពីកាំចាំងផ្លាត IR និងខ្សែកែងហៅថា មុំចំណាំងផ្លាត ។
- មុំចំណាំងប៉ះ i ស្មើនឹងមុំចំណាំងផ្លាត r ។

# 3. កញ្ចក់ប្លង់

កញ្ចក់ប្លង់ ជាបន្ទះកែវសំប៉ែតស្តើងដែលផ្ទៃម្ខាងពាសទឹកប្រាក់រឺទឹកអាលុយមីញ៉ូម ។ កញ្ចក់ប្លង់ជាវត្ថុបំផ្លាតពន្លឺបានយ៉ាងល្អ ។

## 3.1. រូបភាពឱ្យដោយកញ្ចក់ប្លង់

យើងពិនិត្យតែពន្លឺដែលផាលចេញពីចំណុច A ហើយចូលទៅក្នុងភ្នែកអ្នកសង្កេតម្នាក់ក្រោយពីចាំងផ្លាតលើផ្ទៃកញ្ចក់មក ។ ភ្នែកអ្នកសង្កេតឃើញចំណុចភ្លឺ A នៅត្រង់ A' ក្រោយកញ្ចក់ ព្រោះបន្លាយកាំចាំងផ្លាតទាំងអស់ដូចជា IR និង IR' ជួបគ្នាត្រង់ A' ។ ភ្នែកអ្នកសង្កេតឃើញពន្លឺទាំងអស់ហាក់ដូចជាចេញមកពីប្រភព A' ។ តាមពិត A' គ្មានទេ គេថា A' ជាចំណុចរូបភាពមិនពិត ។



*រូបភាពឱ្យដោយកញ្ចក់ប្លង់*

កាលណាគេដាក់វត្ថុមួយនៅពីមុខកញ្ចក់ប្លង់ វាផ្តល់រូបភាពមិនពិតមួយដែលស៊ីមេទ្រីនឹងវត្ថុធៀបនឹងកញ្ចក់នោះ ។

សំគាល់ : រូបភាពមិនពិតមើលឃើញតែវាមិនផិតនៅលើអេក្រង់ទេ ។ ចំណែករូបភាពពិតវិញមើលឃើញហើយទទួលបាននៅលើអេក្រង់ ។

# 4. អនុវត្តន៍ចំណាំងផ្លាតនៃពន្លឺ

បរិទស្សន៍ជាឧបករណ៍សាមញ្ញដែលមានកញ្ចក់ប្លង់ពីរស្របនិងឈមគ្នា M និងM' ដាក់ទ្រេតក្រោមមុំ 45° នៅចុងសងខាងបំពង់ឈរមួយT ។ ភ្នែកសម្លឹងពីមុខកញ្ចក់M មើលឃើញវត្ថុទាំងឡាយដែលឋិតនៅមុខកញ្ចក់ M' ។

នៅក្នុងបរិទស្សន៍ដោយសារចំណាំងផ្លាតពីរដងលើកញ្ចក់ប្លង់ពីរ គេអាចមើលឃើញរូបភាពនៅពីក្រោយរបាំងបានយ៉ាងច្បាស់ ។



*រូបភាពចំណាំងផ្លាតនៃពន្លឺ*

## 5. កញ្ចក់ស្វ៊ែ

កញ្ចក់ស្វ៊ែ ជាផ្ទៃស្វ៊ែ(កំណាត់ស្វ៊ែឬកន្ទប់ស្វ៊ែ) ដែលមានមុខផតឬប៉ោងរលោងហើយបំផ្លាត ពន្លឺបានល្អ ។

កញ្ចក់ស្វ៊ែដែលមានមុខផតហៅថា កញ្ចក់ស្វ៊ែផត ។ រីឯកញ្ចក់ស្វ៊ែដែលមានមុខប៉ោងហៅថា កញ្ចក់ស្វ៊ែប៉ោង ។




### 5.1. លក្ខណៈនៃកញ្ចក់ស្វ៊ែ

- ចំណុច C ជាផ្ចិតកំណោងរបស់កញ្ចក់ស្វ៊ែ
- ចំណុច O ជាកំពូលកញ្ចក់ស្វ៊ែ
- បន្ទាត់ CO កាត់តាមផ្ចិត C និងកំពូល O ហៅថា អ័ក្សអុបទិចនៃកញ្ចក់ស្វ៊ែ ។
- ចម្ងាយOF ពីកំពូលកញ្ចក់ទៅកំណុំហៅថាចម្ងាយ កំណុំ ។ ចម្ងាយនេះស្មើនឹងពាក់កណ្ដាលកាំ OC នៃកញ្ចក់ស្វ៊ែ $OF = \frac{1}{2}OC$ ។



សិក្សាដំណើរកាំពន្លឺចំពោះកញ្ចក់ស្វ៊ែផត

គេបាញ់បាច់ពន្លឺទៅលើកញ្ចក់ស្វ៊ែផតមួយដោយលៃយ៉ាងណាឱ្យបាច់នោះស្របនឹងអ័ក្សអុបទិចរបស់វា ។ គេសង្កេតឃើញកាំចាំងផ្លាតទាំងអស់ រួមចូលត្រង់ចំណុចមួយនៃអ័ក្សនោះ ។ ចំណុចនេះហៅកំណុំ F នៃកញ្ចក់ស្វ៊ែ ។ ប្លង់កែងនិងអ័ក្សអុបទិចត្រង់កំណុំ F ហៅថាប្លង់កំណុំ ។ ផ្ទុយទៅវិញ ប្រសិនបើគេដាក់ប្រភពពន្លឺត្រង់កំណុំ F នៃកញ្ចក់ស្វ៊ែ គេសង្កេតឃើញកាំចាំងផ្លាតពីកញ្ចក់នោះជាកាំស្របនិងអ័ក្សអុបទិច ។

## 5.2. រូបភាពឱ្យដោយកញ្ចក់ស្វ៊ែ

### ក. រូបភាពឱ្យដោយកញ្ចក់ស្វ៊ែប៉ោង

កញ្ចក់ស្វ៊ែប៉ោងផ្តល់រូបភាពតែមួយប្រភេទគត់គឺ រូបភាពមិនពិត មានទិសដៅដូចវត្ថុនិងមានទំហំតូចជាងវត្ថុ ។




ដើម្បីសង់រូបភាពឱ្យដោយកញ្ចក់ស្វ៊ែប៉ោង គេគ្រាន់តែគូសកាំពន្លឺពិសេសពីរក្នុងចំណោមកាំពិសេសទាំងបីគឺ

- គូសកាំពន្លឺ(1) ចេញពីចំណុច B នៃវត្ថុស្របនឹងអ័ក្សអុបទិចប៉ះនឹងកញ្ចក់ស្វ៊ែប៉ោង ហើយផ្លាតចេញពីកញ្ចក់ដោយគូសបន្លាយនៃកាំរបស់វាកាត់តាមកំណុំ F
- គូសកាំពន្លឺ(2) ចេញពីចំណុច B នៃវត្ថុប៉ះនឹងកញ្ចក់ស្វ៊ែប៉ោងហើយផ្លាតតាមទិសដៅដើមដោយគូសបន្លាយនៃកាំរបស់វាកាត់តាមផ្ចិត(កាំពន្លឺដែលឆ្លងកាត់ផ្ចិតអុបទិច)
- គូសកាំពន្លឺ (3) ចេញពីចំណុច B ទៅកញ្ចក់ដែលមានបន្លាយកាត់តាមកំណុំ ។ គេបានកាំចាំងផ្លាតស្របនិងអ័ក្សមេ ។ ចំណុចប្រសព្វរវាងបន្លាយនៃកាំពន្លឺ (1) និង (2) គឺ B' ដែលជារូបភាពនៃវត្ថុ B ។ ដូចនេះ A'B' ជារូបភាពនៃវត្ថុ AB ។

សំគាល់ : យើងអាចគូសកាំពន្លឺ (1) និង (3) ឬកាំពន្លឺ (2) និង (3) ដើម្បីបានរូបភាព B'

### ក. រូបភាពឱ្យដោយកញ្ចក់ស្វ៊ែផត

កញ្ចក់ស្វ៊ែផតផ្តល់រូបភាពពីរប្រភេទគឺរូបភាពពិតនិងរូបភាពមិនពិតដែលអាស្រ័យនិងទីតាំងវត្ថុឋិតនៅ ។




*រូបភាពផ្តល់ដោយកញ្ចក់ស្វ៊ែផត*

- បើសិនវត្ថុឋិតនៅត្រង់ចន្លោះកំពូល O និងកំណុំ F គេឃើញរូបភាពក្នុងកញ្ចក់។ រូបភាពនេះជារូបភាពមិនពិតឋិតនៅក្រោយកញ្ចក់ មានទិសដៅដូចវត្ថុ និងទំហំធំជាងវត្ថុ។
- បើសិនវត្ថុឋិតនៅត្រង់ចន្លោះកំណុំ F និងផ្ចិត C គេទទួលបានរូបភាពនៅលើអេក្រង់។ រូបភាពនេះជារូបភាពពិតឋិតនៅលើអេក្រង់ មានទិសដៅផ្ទុយពីវត្ថុ និងមានទំហំធំជាងវត្ថុ។
- បើសិនវត្ថុឋិតនៅឆ្ងាយពីកំពូល O និងផ្ចិត C គេទទួលបានរូបភាពនៅលើអេក្រង់។ រូបភាពនេះជារូបភាពពិតឋិតនៅលើអេក្រង់ មានទិសដៅផ្ទុយពីវត្ថុ និងមានទំហំតូចជាងវត្ថុ។
- បើសិនវត្ថុឋិតនៅត្រង់ផ្ចិត C គេទទួលបានរូបភាពនៅលើអេក្រង់។ រូបភាពនេះជារូបភាពពិតឋិតនៅលើអេក្រង់ មានទិសដៅផ្ទុយពីវត្ថុ និងមានទំហំប៉ុននឹងវត្ថុ។
- បើសិនវត្ថុឋិតនៅត្រង់កំណុំ F គេទទួលបានរូបភាពមិនពិតឋិតនៅឯអនន្ត។

# ៦. អនុវត្តន៍កញ្ចក់ស្វ៊ែ

## ៦.១. កញ្ចក់ស្វ៊ែផត

កញ្ចក់ស្វ៊ែផតមិនត្រឹមតែគេយកវាទៅប្រើសម្រាប់បំផ្លាតពន្លឺ(រេផ្លិចទ័រ)ពីប្រភពមួយទៅរកទិសដែលគេចង់បានប៉ុណ្ណោះទេ ប៉ុន្តែគេក៏អាចយកវាទៅប្រើសម្រាប់បំផ្លាត សូរ កម្ដៅ និងសញ្ញារលកវិទ្យុ ទូរទស្សន៍ ថែមទៀតផង។

*ឧទាហរណ៍ :* ចង្កៀងហ្វាររថយន្ត ចង្កៀងពិល ប្រដាប់បញ្ចាំងហ្វា រ៉ាដា។ល។

## ៦.២. កញ្ចក់ស្វ៊ែប៉ោង

ដោយសារកញ្ចក់ស្វ៊ែប៉ោងផ្ដល់រូបភាពតូចជាងវត្ថុនិងមានដែនគំហើញធំ គេយកវាទៅប្រើក្នុងកញ្ចក់រថយន្ត ក្នុងហាងលក់ទំនិញ នៅត្រង់ភ្លើងស្តុបផ្លូវកែង ។



ស្វ៊ែផត



កញ្ចក់ស្វ៊ែប៉ោង

## មេរៀនសង្ខេប

- ចំណាំងផ្លាតនៃពន្លឺ ជាដំណាលនៃពន្លឺទាំងប៉ះនឹងវត្ថុអ្វីមួយហើយផ្លាតចូលមជ្ឈដ្ឋានដើមវិញ ។
- កញ្ចក់ប្លង់ ជាបន្ទះកែវសំប៉ែតស្មើងដែលផ្ទៃម្ខាងពាសទឹកប្រាក់ រឺទឹកអាលុយមីញ៉ូម ។ កញ្ចក់ប្លង់ជាវត្ថុបំផ្លាតពន្លឺបានយ៉ាងល្អ ។
- រូបភាពឱ្យដោយកញ្ចក់ប្លង់ ជារូបភាពមិនពិត ចំពោះវត្ថុពិត ។
- កញ្ចក់ស្វ៊ែ ជាផ្ទៃស្វ៊ែ(កំណាត់ស្វ៊ែឬកន្ទិបស្វ៊ែ) ដែលមានមុខផតឬប៉ោងរលោងហើយបំផ្លាតពន្លឺបានល្អ ។ ផ្ទៃកញ្ចក់ស្វ៊ែដែលមានមុខផតហៅថា កញ្ចក់ស្វ៊ែផត ។ រីឯផ្ទៃកញ្ចក់ស្វ៊ែដែលមានមុខប៉ោងហៅថា កញ្ចក់ស្វ៊ែប៉ោង ។
- កញ្ចក់ស្វ៊ែប៉ោងផ្តល់រូបភាពតែមួយប្រភេទគត់គឺ រូបភាពមិនពិត មានទិសដៅដូចវត្ថុ និងមានទំហំតូចជាងវត្ថុ ។
- កញ្ចក់ស្វ៊ែផតផ្តល់រូបភាពពីរប្រភេទគឺរូបភាពពិតនិងរូបភាពមិនពិតដែលអាស្រ័យនឹងទីតាំងវត្ថុឋិតនៅ ។

## សំណួរនិងលំហាត់

1. ដូចម្តេចហៅថា ចំណាំងផ្លាតនៃពន្លឺ ?
2. ដូចម្តេចហៅថា កញ្ចក់ប្លង់ ? កញ្ចក់ស្វ៊ែផត ? កញ្ចក់ស្វ៊ែប៉ោង ?
3. ចូររៀបរាប់អំពីរូបភាពឱ្យដោយកញ្ចក់ប្លង់ កញ្ចក់ស្វ៊ែផត និងកញ្ចក់ស្វ៊ែប៉ោង ។
4. ចូររកឧទាហរណ៍អំពីការអនុវត្តកញ្ចក់ប្លង់ កញ្ចក់ស្វ៊ែផត និងកញ្ចក់ស្វ៊ែប៉ោងក្នុងជីវភាពរស់នៅ ។
5. ចូរគូសកាំចាំងផ្លាត IR និងមុំចាំងប៉ះឱ្យបានត្រឹមត្រូវតាមរូបខាងក្រោម ។




6. ខាងក្រោមនេះគឺជាគំនូសបំប្រួញចង្កៀងកង់មួយ ។ តើគេត្រូវដាក់អំពូលនៅទីតាំង A ឬ B ឬC នៃចង្កៀង ដើម្បីឱ្យបាច់ពន្លឺចេញពីអំពូលជាបាច់ពន្លឺស្រប? តើគំនូសបំប្រួញចង្កៀងកង់នេះជាកញ្ចក់ស្វ៊ែផតឬកញ្ចក់ស្វ៊ែប៉ោង ?



# 3 ចំណាំងបែរនៃពន្លឺ

**ចប់មេរៀននេះ សិស្សអាច**

- ❑ បង្ហាញពីបាតុភូតចំណាំងបែរនៃពន្លឺ
- ❑ ពន្យល់ពីបាតុភូតចំណាំងបែរនៃពន្លឺ ព្រមទាំងធ្វើពិសោធន៍បញ្ជាក់
- ❑ ធ្វើពិសោធន៍ងាយៗដើម្បីបញ្ជាក់ពីចំណាំងបែរនៃពន្លឺ
- ❑ បកស្រាយបានត្រឹមត្រូវពីច្បាប់ចំណាំងបែរនៃពន្លឺ ។

## 1. ចំណាំងបែរនៃពន្លឺ



ចូរអ្នកសង្កេតមើលរូបភាពនេះ តើហេតុអ្វីបានជាអ្នកមើលឃើញខ្មៅដៃហាក់ដូចជាដាច់ពីរកំណាត់នៅត្រង់ផ្ទៃទឹក ។

យើងបានសិក្សារួចមកហើយថា ពន្លឺដាលជាបន្ទាត់ត្រង់ ។ ប៉ុន្តែនៅពេលវាដាលឆ្លងកាត់មជ្ឈដ្ឋានមួយ(ខ្យល់)ទៅមជ្ឈដ្ឋានមួយទៀត(ទឹក) វាប្តូរទិសដំណាល(ប្តូរទិសល្បឿនដំណាល) ។ ហេតុនេះហើយទើបយើងមើលឃើញខ្មៅដៃហាក់ដូចជាបែរហើយងាកចេញពីគ្នា ។

**ចំណាំងបែរនៃពន្លឺ** គឺជាបណ្តូរទិសនៃកាំពន្លឺ(ប្តូរល្បឿនដំណាល)កាលណាវាដាលឆ្លងកាត់មជ្ឈដ្ឋានមួយទៅមជ្ឈដ្ឋានមួយផ្សេងទៀត ។

### 1.1. ច្បាប់ចំណាំងបែរ




*កាំពន្លឺដាលកាត់ផ្ទៃនៃបន្ទះកែវ*

គេបញ្ចាំងកាំពន្លឺ AI ទៅប៉ះផ្ទៃនៃបន្ទះកែវត្រង់ចំណុច I កាំពន្លឺចាំងចូលទៅក្នុងកែវដោយងាកចេញពីទិសដើមតាមទិស IR គេបាន :




- កាំពន្លឺ AI ហៅថាកាំចាំងប៉ះ
- កាំពន្លឺ IR ហៅថាកាំចាំងបែរ
- ខ្សែឈរ NIN' ហៅថាខ្សែកែង
- មុំ i ហៅថាមុំចំណាំងប៉ះ
- មុំ r ហៅថាមុំចំណាំងបែរ
- នៅត្រង់ផ្ទៃញែកនៃមជ្ឈដ្ឋានថ្លាពីរដែលមានលក្ខណៈបំបែរខុសគ្នា កាំពន្លឺប្តូរទិសដំណាល ។
- កាលណាកាំពន្លឺចាំងចូលក្នុងមជ្ឈដ្ឋានបំបែរខ្លាំង មុំចំណាំងបែរតូចជាងមុំចំណាំងប៉ះ ។

តាមពិសោធន៍នេះ គេឃើញកាំចាំងបែរងាកចូលរកខ្សែកែង NIN' ជាងកាំចាំងប៉ះ ដូចនេះមុំចំណាំងបែរ r តូចជាងមុំចំណាំងប៉ះ i ។ ក្នុងករណីនេះ គេថាកែវមានលក្ខណៈបំបែរខ្លាំងជាងខ្យល់ ពីព្រោះនៅក្នុងខ្យល់ល្បឿនដំណាលនៃពន្លឺដាលលឿនជាងនៅក្នុងកែវ ។ បើកាំពន្លឺចាំងប៉ះស្ថិតក្នុងកែវឆ្លងចូលក្នុងខ្យល់ នោះកាំចាំងបែរងាកចេញពីខ្សែកែង គេថាខ្យល់មានលក្ខណៈបំបែរខ្សោយជាងកែវ ពីព្រោះនៅក្នុងកែវល្បឿនដំណាលនៃពន្លឺដាលយឺតជាងនៅក្នុងខ្យល់ ។ ដូចនេះចំណាំងបែរនៃពន្លឺកើតឡើងដោយសារពន្លឺដាលដោយល្បឿនខុសៗគ្នា កាលណាវាដាលឆ្លងកាត់មជ្ឈដ្ឋានមួយទៅមជ្ឈដ្ឋានមួយផ្សេងទៀត ។

ម្យ៉ាងវិញទៀត បើគេជំនួសបន្ទះកែវថ្លានេះដោយទឹកឬមជ្ឈដ្ឋានថ្លាផ្សេងទៀត គេសង្កេតឃើញថា ចំពោះមុំចំណាំងប៉ះ i ប៉ុនគ្នា គេបានមុំចំណាំងបែរ r មានតម្លៃខុសៗគ្នា ។




*ចំណាំងបែរនៃពន្លឺឆ្លងកាត់ផ្ទៃញែក*

បើគេធ្វើផលធៀបល្បឿនដំណាលនៃពន្លឺដែលដាលឆ្លងកាត់មជ្ឈដ្ឋានមួយធៀបនឹងមជ្ឈដ្ឋានខ្យល់ គេបានទំហំមួយហៅថា សន្ទស្សន៍ចំណាំងបែរ ។

$$\text{សន្ទស្សន៍ចំណាំងបែរ} = \frac{\text{ល្បឿនពន្លឺដាលក្នុងខ្យល់}}{\text{ល្បឿនពន្លឺដាលក្នុងមជ្ឈដ្ឋានផ្សេងៗ}}$$

ឬ $\boxed{n = \frac{c}{v}}$ n សន្ទស្សន៍ចំណាំងបែរ c ល្បឿនដំណាលនៃពន្លឺក្នុងខ្យល់និង v ល្បឿនដំណាលនៃពន្លឺក្នុងមជ្ឈដ្ឋានផ្សេងៗ ។

តារាងខាងក្រោមនេះជាតម្លៃប្រហែលនៃសន្ទស្សន៍ចំណាំងបែរនៃមជ្ឈដ្ឋានថ្លាមួយចំនួន

| អង្គធាតុថ្លា | សន្ទស្សន៍ | ល្បឿនដំណាលនៃពន្លឺ (m/s) |
|---|---|---|
| ខ្យល់ | 1.00 | 300 000 000= $300 \times 10^6$ |
| ទឹក | 1.33 | 225 000 000= $225 \times 10^6$ |
| កែវ | 1.50 | 200 000 000= $200 \times 10^6$ |
| ពេជ្រ | 2.50 | 120 000 000= $120 \times 10^6$ |

*ឧទាហរណ៍ :* សន្ទស្សន៍ចំណាំងបែរទឹកប្រហែល 1.33 មានន័យថា ល្បឿនពន្លឺដាលក្នុងទឹកយឺតជាងល្បឿនដាលក្នុងខ្យល់ 1.33 ដង ។ តម្លៃនៃសន្ទស្សន៍នេះបានមកពីផលធៀបនៃដំណាលល្បឿនពន្លឺក្នុងខ្យល់ធៀបនិងដំណាលល្បឿនពន្លឺក្នុងទឹក ។

### 1.2. ផលចំណាំងបែរនៃពន្លឺ



*ផលចំណាំងបែរនៃពន្លឺ*

យើងយកកាក់មួយដាក់ចូលទៅក្នុងកែវ រួចដៅចំណុច A (វត្ថុ) នៅលើកែវដែលជាទីតាំងនៃកាក់ ។ បន្ទាប់មក យើងចាក់ទឹកថ្លាចូលទៅក្នុងកែវឱ្យបានជិតពេញ ហើយសង្កេតមើលកាក់ម្តងទៀត រួចដៅចំណុច A' (រូបភាពនៃវត្ថុ) ដែលជាទីតាំងនៃកាក់ ។ តាមការសង្កេតយើងឃើញកាក់ហាក់ដូចជាខិតមកជិតផ្ទៃញែក(ទឹកនិងខ្យល់) ។ នេះបណ្តាលមកពីកាំពន្លឺដែលដាលចេញពីកាក់ឆ្លងកាត់មជ្ឈដ្ឋានបំបែរខ្លាំង(ទឹក)ទៅមជ្ឈដ្ឋានខ្សោយ(ខ្យល់)កាំពន្លឺងាកចេញពីខ្សែកែង ។ ដូចនេះ ចំណុចដែលភ្នែកយើងមើលឃើញរូបភាពហាក់ដូចជានៅជិតផ្ទៃបំបែរជាងទីតាំងពិតរបស់វា ។ យើងអាចគណនាចម្ងាយទីតាំងរូបភាពតាមរូបមន្ត :

$$\text{សន្ទស្សន៍ចំណាំងបែរ} = \frac{\text{ចម្ងាយទីតាំងវត្ថុ}}{\text{ចម្ងាយទីតាំងរូបភាព}} \quad \text{ឬ } n = \frac{d}{d'} \quad \text{ឬ } d' = \frac{d}{n}$$

## 2. សំខាកនិងរបាយពន្លឺស

បាច់ពន្លឺដែលចេញមកពីព្រះអាទិត្យនិងអំពូលចង្កៀងអគ្គិសនីធម្មតាជាពន្លឺស ។ បាច់ពន្លឺសនេះផ្គុំឡើងពីពន្លឺ 7 ពណ៌គឺ ស្វាយ ខៀវចួះ(indigo) ខៀវ បៃតង លឿង លឿងទុំ និងក្រហម ។



លំងាកនិងរបាយពន្លឺស

កាលណាពន្លឺសចាំងមកលើព្រីស P ដែលមានទ្រនុង A (ដូចរូប) ។ បាច់ពន្លឺដែលចេញពីព្រីសមិនត្រឹមតែមានលំងាកទេ ថែមទាំងពង្រាយពណ៌ពន្លឺថែមទៀតផង ។ ប្រសិនបើគេទទួលបាច់ចេញនេះលើអេក្រង់ E មួយគេនឹងបានស្នាមពណ៌ដូចឥន្ទធនូនៅលើអេក្រង់នោះ ។ ស្នាមនោះមានពណ៌រាយរៀងពីលើទៅក្រោម ចាប់ពីក្រហមទៅលឿងទុំ(ទឹកក្រូច) រួចលឿង បៃតង ខៀវ និងទីបញ្ចប់ពណ៌ស្វាយ ។ស្នាមនេះហៅថា ស្ប៉ិចពន្លឺ ។ លំងាកនេះកើតឡើងដោយសារល្បឿននៃដំណាលពន្លឺប្រែប្រួលតាមពណ៌ កាលណាវាឆ្លងកាត់ព្រីស ។ ពន្លឺពណ៌ក្រហមមានលំងាកខ្សោយជាងពណ៌ស្វាយ ពីព្រោះពន្លឺពណ៌ក្រហមដាលឆ្លងកាត់ព្រីសមានល្បឿនលឿនជាងពន្លឺពណ៌ស្វាយ ។

## មេរៀនសង្ខេប

- ចំណាំងបែរនៃពន្លឺ គឺជាបណ្តូរទិសនៃកាំពន្លឺ កាលណាវាដាលឆ្លងកាត់មជ្ឈដ្ឋានមួយទៅមជ្ឈដ្ឋានមួយផ្សេងទៀត ។
- ច្បាប់ចំណាំងបែរ : នៅត្រង់ផ្ទៃញែកនៃមជ្ឈដ្ឋានថ្លាពីរដែលមានលក្ខណៈបំបែរខុសគ្នា កាំពន្លឺប្តូរទិសដំណាល ។ កាលណាកាំពន្លឺចាំងចូលក្នុងមជ្ឈដ្ឋានបំបែរខ្លាំងមុំចំណាំងបែរតូចជាងមុំចំណាំងប៉ះ ។ បើកាំពន្លឺចាំងចូលក្នុងមជ្ឈដ្ឋានបំបែរខ្សោយមុំចំណាំងបែរធំជាងមុំចំណាំងប៉ះ ។

## ? សំណួរនិងលំហាត់

1. ដូចម្តេចហៅថា ចំណាំងបែរនៃពន្លឺ ? តើនៅក្នុងករណីណាដែលកាំចាំងបែរងាកចូលមកជិតខ្សែកែង ? ហើយករណីណាដែលកាំចាំងបែរងាកចេញពីខ្សែកែង ?
2. ដូចម្តេចហៅថា សន្ទស្សន៍ចំណាំងបែរ ?
3. នៅពេលពន្លឺសឆ្លងកាត់ព្រីស តើពន្លឺពណ៌ណាដែលលំងាកខ្លាំងជាងគេ ? ខ្សោយជាងគេ ? ព្រោះហេតុអ្វី ?
4. អាងទឹកមួយមានបាតជាប្លង់ដេក បាតនេះមានជម្រៅ 2m ពីផ្ទៃទឹក ។ អ្នកសង្កេតមើលបាតអាងទឹកនេះតាមបណ្តោយខ្សែឈរ ។ តើអ្នកសង្កេតឃើញបាតអាងទឹកនៅជម្រៅប៉ុន្មាន ?
ទឹកមានសន្ទស្សន៍ 1.33

# 4 ឡង់ទី

**ចប់មេរៀននេះ សិស្សអាច**

- កំណត់និយមន័យឡង់ទី
- រៀបរាប់អំពីប្រភេទឡង់ទី
- បង្ហាញពីលក្ខណៈកាំពន្លឺឆ្លងកាត់ឡង់ទី
- កំណត់ចម្ងាយវត្ថុ ចម្ងាយរូប និងចម្ងាយកំណុំ ។

តើអ្នកធ្លាប់បានប្រើឧបករណ៍កែវពង្រីក ម៉ាស៊ីនថតរូប មីក្រូទស្សន៍ កែវឆ្លុះផ្កាយ... ដែរឬទេ ? ប្រសិនបើអ្នកកំពុងប្រើឧបករណ៍ទាំងនេះ គឺអ្នកកំពុងប្រើប្រាស់ឡង់ទី ដើម្បីបង្កើតរូបភាពនៃវត្ថុ ។

## 1. និយមន័យ

ឡង់ទីជាអង្គធាតុថ្លា ធ្វើអំពីកែវ ឬប្លាស្ទិចកម្រិតដោយកន្ទិបស្វ៊ែពីរ ឬដោយកន្ទិបស្វ៊ែមួយនិងប្លង់មួយ ។ កាំទាំងពីររបស់ស្វ៊ែជាកាំកំណោងរបស់ឡង់ទី ។

## 2. ប្រភេទឡង់ទីនិងគំនូសបំព្រួញ




ឡង់ទីពោងឬឡង់ទីបង្រួម

ឡង់ទីផតឬឡង់ទីពង្រីក

គំនូសបំព្រួញឡង់ទីពោងឬឡង់ទីបង្រួម

គំនូសបំព្រួញឡង់ទីផតឬឡង់ទីពង្រីក

## 2.1. ប្រភេទឡង់ទី

ឡង់ទីមានពីរប្រភេទ គឺឡង់ទីប៉ោងឬឡង់ទីបង្រួម និងឡង់ទីផតឬឡង់ទីពង្រីក ។

- ឡង់ទីប៉ោងឬឡង់ទីបង្រួម គឺជាឡង់ទីដែលមានគែមខាងស្ដើងជាងផ្នែកផ្ចិត ។
- ឡង់ទីផតឬឡង់ទីពង្រីក គឺជាឡង់ទីដែលមានគែមខាងក្រាស់ជាងផ្នែកផ្ចិត ។

## 2.2. លក្ខណៈឡង់ទី

- ផ្ចិត $C_1$ និង $C_2$ ជាផ្ចិតកំណោងនៃឡង់ទី ។
- បន្ទាត់កាត់តាមផ្ចិត $C_1$ និង $C_2$ ហៅថា អ័ក្សមេឬអ័ក្សអុបទិច ។
- ចំណុច O ហៅថាផ្ចិតអុបទិច ។

## 2.3. ដំណើរកាំពន្លឺឆ្លងកាត់ឡង់ទី

កាលណាគេបញ្ជាំងបាច់ពន្លឺស្របនឹងអ័ក្សអុបទិចឱ្យឆ្លងកាត់ឡង់ទី គេសង្កេតឃើញ :



*ដំណើរកាំពន្លឺឆ្លងកាត់ឡង់ទីបង្រួម*



*ដំណើរកាំពន្លឺឆ្លងកាត់ឡង់ទីពង្រីក*

### ក. ដំណើរកាំពន្លឺឆ្លងកាត់ឡង់ទីបង្រួម

- កាំពន្លឺដែលស្របនឹងអ័ក្សអុបទិច ចេញពីឡង់ទីងាកចូលកាត់ត្រង់ចំណុចមួយឋិតនៅលើអ័ក្សអុបទិចហៅថាកំណុំមេ ។ ចម្ងាយពីចំណុចផ្ចិតអុបទិចទៅចំណុចកំណុំមេហៅថាចម្ងាយកំណុំ ។
- កាំពន្លឺដែលឆ្លងកាត់តាមផ្ចិតអុបទិច ចេញពីឡង់ទីដោយគ្មានលំងាក ។

### ខ. ដំណើរកាំពន្លឺឆ្លងកាត់ឡង់ទីពង្រីក

- កាំពន្លឺដែលស្របនឹងអ័ក្សអុបទិច ចេញពីឡង់ទីងាកចេញពីអ័ក្សមេហើយបន្លាយនៃកាំពន្លឺដែលងាកនោះ មករួមប្រសព្វគ្នាត្រង់ចំណុចមួយហៅថា កំណុំមេ ។ ចម្ងាយពីចំណុចផ្ចិតអុបទិចទៅចំណុចកំណុំមេហៅថា ចម្ងាយកំណុំ ។
- កាំពន្លឺដែលឆ្លងកាត់តាមផ្ចិតអុបទិច ចេញពីឡង់ទីដោយគ្មានលំងាក ។

## 2.4. រូបភាពឱ្យដោយឡង់ទីបង្រួម

ឡង់ទីបង្រួមផ្តល់រូបភាពពីរប្រភេទ គឺរូបភាពពិតនិងរូបភាពមិនពិតដែលអាស្រ័យនឹងទីតាំងវត្ថុឋិតនៅ។ ដើម្បីសង់រូបភាពឱ្យដោយឡង់ទីបង្រួម គេគ្រាន់តែគូសកាំពន្លឺមេពីរគឺ គូសកាំពន្លឺ (1) និងគូសកាំពន្លឺ (2) ដូចរូប ដែលបង្ហាញក្នុងតារាងខាងក្រោម ។




- រូបភាព : ពិត
- ទិសដៅ : ឈរបញ្ច្រាស
- ទំហំ : តូចជាងវត្ថុ
- ទីតាំងរូបភាព : $d' < 2f$
- ប្រើក្នុងម៉ាស៊ីនថតរូប(ភ្នែក)

- រូបភាព : ពិត
- ទិសដៅ : ឈរបញ្ច្រាស
- ទំហំ : ធំជាងវត្ថុ
- ទីតាំងរូបភាព : $d' > 2f$
- ប្រើក្នុងម៉ាស៊ីនបញ្ចាំងកុន

- រូបភាព : មិនពិត
- ទិសដៅ : ឈរត្រង់
- ទំហំ : ធំជាងវត្ថុ
- ទីតាំងរូបភាព : $d' < f$
- ប្រើក្នុងកែវពង្រីក

*រូបភាពឱ្យដោយឡង់ទីបង្រួម*

## 2.5. រូបភាពឱ្យដោយឡង់ទីពង្រីក

ជាទូទៅឡង់ទីពង្រីកផ្តល់រូបភាពតែមួយប្រភេទគត់ គឺរូបភាពមិនពិត មានទិសដៅដូចវត្ថុ និងមានទំហំតូចជាងវត្ថុ ។




- រូបភាព : មិនពិត
- ទិសដៅ : ឈរត្រង់
- ទំហំ : តូចជាងវត្ថុ
- ទីតាំងរូបភាព : $d' < f$

*រូបភាពឱ្យដោយឡង់ទីពង្រីក*

*សំគាល់ :* ឡង់ទីពង្រីកមួយអាចផ្តល់រូបភាពពិត លុះត្រាតែគេប្រើវត្ថុមិនពិតដែលស្ថិតនៅចន្លោះឡង់ទីនិងប្លង់កំណុំវត្ថុ ។

## មេរៀនសង្ខេប

- ឡង់ទីជាអង្គធាតុថ្លាមួយ កម្រិតដោយកន្ទិបស្វ៊ែពីរ រឺដោយកន្ទិបស្វ៊ែមួយនិងប្លង់មួយ ។
- ឡង់ទីមានពីរប្រភេទ គឺឡង់ទីប៉ោងឬឡង់ទីបង្រួមនិងឡង់ទីផតឬឡង់ទីពង្រីក ។
- ឡង់ទីបង្រួមផ្តល់រូបភាពពីរប្រភេទ គឺរូបភាពពិតនិងរូបភាពមិនពិតដែលអាស្រ័យនឹងទីតាំងវត្ថុឋិតនៅ ។
- ជាទូទៅឡង់ទីពង្រីកផ្តល់រូបភាពតែមួយប្រភេទគត់ គឺរូបភាពមិនពិត មានទិសដៅដូចវត្ថុ និងមានទំហំតូចជាងវត្ថុ ។

## ? សំណួរនិងលំហាត់

1. ដូចម្តេចហៅថា ឡង់ទី? តើឡង់ទីមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
2. ដូចម្តេចហៅថា អ័ក្សអុបទិច ? កំណុំមេ ? ចម្ងាយកំណុំ ? ចម្ងាយរូបភាព ? ចម្ងាយវត្ថុ ?
3. ចូរសង់រូបភាពឱ្យដោយឡង់ទីបង្រួម ក្នុងករណី (ក)វត្ថុឋិតនៅចម្ងាយធំជាងពីរដងចម្ងាយកំណុំ (ខ)ស្មើពីរដងចម្ងាយកំណុំ តូចជាងពីរដងចម្ងាយកំណុំ (គ)វត្ថុឋិតនៅចន្លោះកំណុំនិងឡង់ទី ។




4. វត្ថុភ្លឺ AB មានកម្ពស់ 10cm ស្ថិតនៅចម្ងាយ 60cm ពីផ្ចិតកែងនិងអ័ក្សមេនៃឡង់ទីបង្រួមមួយដែលមានចម្ងាយកំណុំ 50cm ពីឡង់ទី ។ ចូរកំណត់ចម្ងាយ ប្រភេទ និងទំហំរូបភាពដែលបានមកដោយគូសរូបបញ្ជាក់ ។
5. ចូរសង់រូបភាពឱ្យដោយឡង់ទីពង្រីក ក្នុងករណី (ក) វត្ថុឋិតនៅចម្ងាយធំជាងពីរដងចម្ងាយកំណុំ (ខ) វត្ថុឋិតនៅចម្ងាយស្មើពីរដងចម្ងាយកំណុំ (គ)វត្ថុឋិតនៅចម្ងាយតូចជាងពីរដងចម្ងាយកំណុំ (ឃ)វត្ថុឋិតនៅចន្លោះកំណុំនិងឡង់ទី ។




6. ឡង់ទីពង្រីកមួយមានចម្ងាយកំណុំ 12cm ។ គេដាក់វត្ថុឈរមួយដែលកម្ពស់ 4cm នៅចម្ងាយ 4cm ពីមុខឡង់ទីនេះ ។ កំណត់ចម្ងាយ ប្រភេទ និងទំហំរូបភាពដែលបានមកដោយគូសរូបបញ្ជាក់ ។

## ? សំណួរបញ្ចប់ជំពូកទី៥

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវមានតែមួយគត់ :

1. បណ្ដារូបខាងក្រោម តើរូបមួយណាជាឡង់ទីបង្រួម ?

☐ ក.  ☐ ខ.  ☐ គ.  ☐ ឃ. 

2. រូបភាពឱ្យដោយបន្ទប់ងងឹតជា

☐ ក. រូបភាពមិនពិតមានទិសដៅផ្ទុយពីវត្ថុ ☐ ខ. រូបភាពពិតមានទិសដៅផ្ទុយពីវត្ថុ

☐ គ. រូបភាពមិនពិតមានទិសដៅដូចវត្ថុ ☐ ឃ. រូបភាពពិតមានទិសដៅដូចវត្ថុ

3. ដើម្បីបំបែកពណ៌នៃពន្លឺស គេត្រូវប្រើ

☐ ក. កញ្ចក់ប្លង់ ☐ ខ. ឡង់ទីបង្រួម ☐ គ. ព្រីស ☐ ឃ. ឡង់ទីពង្រីក

4. គេអាចគណនាចម្ងាយទីតាំងរូបភាពតាមរូបមន្ត

☐ ក $d' = nd$ ☐ ខ $d' = \frac{n}{d}$ ☐ គ $d' = \frac{d}{n}$ ☐ ឃ. $d' = n - d$

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ :

1. បណ្ដូរទិសនៃកាំពន្លឺ កាលណាវាឆ្លងកាត់ផ្ទៃញែកនៃមជ្ឈដ្ឋានថ្លាពីរហៅថា ........................ ។
2. មុំដែលបង្កើតឡើងដោយកាំចាំងផ្លាតជាមួយនិងខ្សែកែងហៅថា ........................ ។
3. កញ្ចក់ស្វ៊ែដែលផ្នែកកញ្ចក់មានមុខផតហៅថា ........................ ។

III. លំហាត់

1 គេដាក់វត្ថុភ្លឺ AB កម្ពស់ 4cm កែងនិងអ័ក្សមេឋិតនៅចម្ងាយ 20cm ពីមុខឡង់ទីបង្រួមមួយ ។ ដោយបង្ខិតអេក្រង់កែងនឹងអ័ក្សមេ គេទទួលបានរូបភាពមួយនៅលើអេក្រង់ចម្ងាយ 15cm ពីឡង់ទីនោះ ។ កំណត់ប្រភេទនិងទំហំរូបភាពដែលឋិតនៅលើអេក្រង់នោះ ។ (ដោយគូររូបបញ្ជាក់ផង) ។

2. គេដាក់វត្ថុពន្លឺមួយចម្ងាយ 21cm ពីមុខឡង់ទីបង្រួមមួយ រូបភាពដែលផ្ដល់ដោយឡង់ទីមានចម្ងាយ 7cm ។ គណនាចម្ងាយកំណុំនៃឡង់ទី ។